# លទ្ធផលនៃការសង្កេតដោយសង្ខេប

តាមការសង្កេតឃ្លាំមើលពីដំណើរការរបស់រដ្ឋសភា និងតំណាងរាស្ត្រក្នុងនីតិកាលទី៤នេះ គណៈកម្មាធិការខុមហ្វ្រែល(COMFREL)បានសង្កេតឃើញថា ក្នុងរយៈពេល៥ឆ្នាំ (កញ្ញា២០០៨-មិថុនា២០១៣) រដ្ឋសភាជាតិមានសកម្មភាពក្នុងការបើកអង្គប្រជុំពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់/ស្នើច្បាប់ ការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តជូនដល់រាជរដ្ឋាភិបាល ការបោះឆ្នោតជ្រើសតាំងថ្នាក់ដឹកនាំរដ្ឋសភាជាតិ និងការបោះឆ្នោតការដក ឬក៏ប្រគល់អភ័យឯកសិទ្ធិសភាដល់អ្នកតំណាងរាស្ត្រ។ ចំពោះក្នុងការបើកអង្គប្រជុំរដ្ឋសភាជាតិ មិនដែលមានការជួបបញ្ហាជាឧបសគ្គក្នុងការខ្វះកូរ៉ុមប្រជុំ ដើម្បីពិភាក្សា និងអនុម័តលើសេចក្តីព្រាងច្បាប់/ស្នើច្បាប់លើការផ្តល់អនុសញ្ញា/សន្ធិសញ្ញា និងកិច្ចព្រមព្រៀងនោះទេ។

លទ្ធផលរបស់ខុមហ្វ្រែលដែលបានអង្កេតពីដំណើរការសភាអ្នកតំណាងរាស្ត្រ ក្នុងរយៈពេលមួយអាណត្តិក្នុងនីតិកាលទី៤ (កញ្ញា២០០៨-មិថុនា២០១៣) បានបង្ហាញឱ្យឃើញថា ក្នុងនីតិកាលទី៤ ខុមហ្វ្រែលបានសង្កេតឃើញថា តួនាទីសំខាន់ៗក្នុងស្ថាប័នសភាប្រធាន អនុប្រធានទាំងពីរនៃរដ្ឋសភា រួមទាំងប្រធាន និងអនុប្រធានគណៈកម្មការជំនាញទាំង៩របស់រដ្ឋសភា ត្រូវបានកាន់កាប់ ក្តោបក្តាប់ដោយកណ្តាប់ដៃរបស់សមាជិកសភាមកពីគណបក្សប្រជាជនកម្ពុជាតែមួយប៉ុណ្ណោះ។

អភ័យឯកសិទ្ធិសភារបស់អ្នកតំណាងរាស្ត្រនៅក្នុងនីតិកាលទី៤នេះ ជាពិសេសអភ័យឯកសិទ្ធិសភាតំណាងរាស្ត្រគណបក្សប្រឆាំងងាយស្រួលនឹងត្រូវបានព្យួរ ឬក៏ដកជាទីបំផុត ឱ្យតែមានការស្នើសុំពីតុលាការ តាមរយៈក្រសួងយុត្តិធម៌ សភានីតិកាលទី៤ ដែលគ្របដណ្តប់ដោយតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា ដែលជាគណបក្សកាន់អំណាច ដោយមានសម្លេងលើសលប់នៅក្នុងរដ្ឋសភា(៩០អាសនៈ)។

**ការប្រជុំពេញអង្គ៖** នៅក្នុងនីតិកាលទី៤នេះ រដ្ឋសភាបានដំណើរការបើកសម័យប្រជុំចំនួន៩លើក ដោយប្រជុំពេញអង្គសាមញ្ញសរុបចំនួន៩២កិច្ចប្រជុំ ប្រជុំជាសាមញ្ញសម្ងាត់ចំនួន២កិច្ចប្រជុំ និងប្រជុំជាវិសាមញ្ញចំនួន៦កិច្ចប្រជុំ ក្នុងនោះមានសេចក្តីព្រាងច្បាប់/ស្នើច្បាប់ចំនួន៤៩ច្បាប់ ច្បាប់ស្តីពីវិសោធនកម្មចំនួន៧ច្បាប់ កិច្ចព្រមព្រៀងអន្តរជាតិនានាចំនួន២១ច្បាប់ ច្បាប់ស្តីពីការផ្តល់សន្ធិសញ្ញាចំនួន១ច្បាប់ អនុសញ្ញាចំនួន៦ច្បាប់ ពិធីសារចំនួន៣ និងអនុស្សរណៈចំនួន១ច្បាប់ រួមទាំងរបៀបវារៈផ្សេងៗទៀត មាន៤២របៀបវារៈ ដូចជាបើកសម័យប្រជុំពេញអង្គក្នុងរបាយការណ៍និមួយៗ ស្តីពីសកម្មភាពសភាចន្លោះសម័យប្រជុំក្នុងមួយលើកៗ ការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តសមាជិករាជរដ្ឋាភិបាល ការបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មការជំនាញ ការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តអ្នកតំណាងរាស្ត្រ ការប្រគល់ ឬដកអភ័យឯកសិទ្ធិសភាតំណាងរាស្ត្រ ការឆ្លើយមកបំភ្លឺក្នុងសភា។

ក្នុងនីតិកាលទី៤ មានតំណាងរាស្ត្រចំនួន៦០រូប បានចំណាយពេលបញ្ចេញមតិ ក្នុងន័យអព្យាក្រឹត្យ វិជ្ជមាន និងអវិជ្ជមានអស់រយៈពេលសរុបចំនួន៧៩៤៧នាទី(ស្មើនឹង១៣២ម៉ោង២៧នាទី)។ តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា ដែលជាគណបក្សកាន់អំណាចមានចំនួន៣៨រូប បានចំណាយពេលឡើងបញ្ចេញមតិសរុបចំនួន

៣២៩៧នាទី តំណាងរាស្ត្រគណបក្សសម រង្ស៊ីមានចំនួន១៨រូប បានឡើងបញ្ចេញមតិសរុបចំនួន៤៤១៩នាទី (ស្មើនឹង៧៣ម៉ោង៣៩នាទី) ចំពោះគណបក្សជាតិនិយមមានតំណាងរាស្ត្រចំនួន២រូបនៅក្នុងរដ្ឋសភា មានតំណាងរាស្ត្រចំនួន១រូបបានឡើងបញ្ចេញមតិចំនួន១៧៣នាទី(ស្មើនឹង២ម៉ោង៥២នាទី) និងគណបក្សហ៊្វុនស៊ិនប៉ិចមានអ្នកតំណាងរាស្ត្រចំនួន១រូប បានចំណាយពេលឡើងបញ្ចេញមតិសរុបចំនួន១៤នាទី ចំណែកគណបក្សសិទ្ធិមនុស្សដែលមាន៣អាសនៈក្នុងរដ្ឋសភា មានតំណាងរាស្ត្រចំនួន២រូប បានចំណាយពេលឡើងបញ្ចេញមតិសរុបចំនួន៤៤នាទី។

**ការចុះមូលដ្ឋានៈ** ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រនៅក្នុងនីតិកាលទី៤នេះ តាមទិន្នន័យដែលខុមហ្វ្រែលបានប្រមូលព័ត៌មាន ក្នុងរយៈពេលមួយអាណត្តិបានបង្ហាញឱ្យឃើញថា មានតំណាងរាស្ត្រចំនួន១៣៣រូប បានធ្វើសកម្មភាពចុះមូលដ្ឋាន ក្នុងគោលបំណងចុះសួរសុខទុក្ខចែកអំណោយ សម្ពោធសមិទ្ធផលនានា ចុះពង្រឹងបណ្តាញផ្ទៃក្នុងបក្សរបស់ខ្លួន អមដំណើរថ្នាក់ដឹកនាំ ចូលរួមវេទិកាសាធារណៈ រួមទាំងចុះជួយអន្តរាគមន៍ ឬដោះស្រាយបញ្ហានានាជូនប្រជាពលរដ្ឋបានចំនួន៨៧២៦លើក។ ការចុះមូលដ្ឋាននេះ ខុមហ្វ្រែលសង្កេតឃើញថា មានតំណាងរាស្ត្រចំនួន ៥ គណបក្ស ដែលមានអាសនៈនៅក្នុងរដ្ឋសភារួមមានៈ គណបក្សប្រជាជនកម្ពុជា គណបក្សសម រង្ស៊ី គណបក្សជាតិនិយម គណបក្សសិទ្ធិមនុស្ស និងគណបក្សហ៊្វុនស៊ិនប៉ិច សុទ្ធតែបានចុះធ្វើសកម្មភាពតាមមូលដ្ឋានរបស់ខ្លួនទាំងអស់។

ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា បានចំនួន៥០៨០លើក ចំពោះតំណាងរាស្ត្រគណបក្សសម រង្ស៊ី បានចុះមូលដ្ឋានសរុបចំនួន១៩៩៩លើក ចំណែកឯតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស បានចុះធ្វើសកម្មភាពនៅមូលដ្ឋានបានចំនួន១៤៤០លើក ចំពោះតំណាងរាស្ត្រគណបក្សជាតិនិយម ចុះមូលដ្ឋានបានចំនួនសរុប៧២លើក និងតំណាងរាស្ត្រហ៊្វុនស៊ិនប៉ិច បានចុះធ្វើសកម្មភាពនៅមូលដ្ឋានសរុបចំនួន១៣៥លើក។

ការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រនៅក្នុងអាណត្តិនីតិកាលទី៤នេះ ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រ គឺផ្តោតទៅលើការចុះមូលដ្ឋាននៅក្នុងមណ្ឌលរបស់ខ្លួន ដែលចុះបានចំនួន៦០១៤លើក និងការចុះមូលដ្ឋាននៅក្រៅមណ្ឌលមានចំនួន២៧១១លើក។ ក្នុងគោលបំណងចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ បានផ្តោតទៅលើគោលបំណងចុះសំណេះសំណាល សួរសុខទុក្ខ ចែកអំណោយដល់ប្រជាពលរដ្ឋតាមមូលដ្ឋាន រួមទាំងសម្ពោធសមិទ្ធផលនានា។

**ការចេញលិខិតៈ** ការចេញលិខិតរបស់អ្នកតំណាងរាស្ត្រនៅក្នុងនីតិកាលទី៤នេះ គណៈកម្មាធិការខុមហ្វ្រែលបានទទួលទិន្នន័យពីការចេញលិខិតរបស់អ្នកតំណាងរាស្ត្រ មានតំណាងរាស្ត្រចំនួន២៦រូប មកពីគណបក្សចំនួន៤ដែលមានអាសនៈនៅក្នុងរដ្ឋសភាជាតិ ក្នុងនោះ មានតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាចំនួន២រូប តំណាងរាស្ត្រគណបក្សសម រង្ស៊ីចំនួន២០រូប តំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សចំនួន៣រូប និងតំណាងរាស្ត្រជាតិនិយមចំនួន១រូប បានចេញលិខិតចំនួន២១១ច្បាប់ជូនទៅរាជរដ្ឋាភិបាល និងជូនស្ថាប័នពាក់ព័ន្ធនានា។

ក្នុងនីតិកាលទី៤នេះ រាល់លិខិតដែលតំណាងរាស្ត្រចេញនោះ ភាគច្រើន គឺក្នុងគោលបំណងស្នើរិធានការ/

អំពាវនាវឲ្យស្ថាប័នរាជរដ្ឋាភិបាល ដើម្បីចាត់វិធានការអន្តរាគមន៍ទៅបញ្ហានានា ដែលអ្នកតំណាងរាស្ត្របានប្រមូលព័ត៌មានបាន រួមទាំងបានទទួលពីម្ចាស់ឆ្នោត។

## សភា និងតំណាងរាស្ត្រ នីតិកាលទី៤
## កញ្ញា ២០០៨-មិថុនា ២០១៣

### ១.ដំណើរការសម័យប្រជុំពេញអង្គរដ្ឋសភា

**ចំនួនកិច្ចប្រជុំក្នុងសម័យប្រជុំពេញអង្គ៖** ក្នុងអំឡុងពេលសម័យប្រជុំនីតិកាលទី៤ (កញ្ញា ២០០៨ - មិថុនា ២០១៣)នៃការសង្កេតរបស់ខុមហ្វ្រែលបានបង្ហាញថា រដ្ឋសភាបានបើកសម័យប្រជុំពេញអង្គរបស់ខ្លួនបានចំនួន៩លើក ដោយមានកិច្ចប្រជុំចំនួន១០០កិច្ចប្រជុំ។ ក្នុងសម័យប្រជុំទាំង៩លើកក្នុងនីតិកាលទី៤នេះ រដ្ឋសភាមានកិច្ចប្រជុំពេញជាសាមញ្ញសរុបចំនួន៩២កិច្ចប្រជុំ ប្រជុំជាសាមញ្ញសម្ងាត់ចំនួន២កិច្ចប្រជុំ និងប្រជុំជាវិសាមញ្ញចំនួន៦កិច្ចប្រជុំ ដោយកិច្ចប្រជុំនិមួយៗធ្វើឡើងជាមធ្យមតែរយៈពេល១ព្រឹកប៉ុណ្ណោះ។

រដ្ឋសភានីតិកាលទី៤នេះ បើកសម័យប្រជុំសាមញ្ញពេញអង្គ និងសម័យប្រជុំវិសាមញ្ញរបស់ខ្លួនសរុបចំនួន ១០០កិច្ចប្រជុំ ត្រូវបានពិភាក្សា និងអនុម័តលើរបៀបវារៈសរុបចំនួន១៣០ ដោយក្នុងនោះមាន សេចក្តីព្រាងច្បាប់/ស្នើច្បាប់ចំនួន៤៩ច្បាប់ ច្បាប់ស្តីពីវិសោធនកម្មចំនួន៧ច្បាប់ កិច្ចព្រមព្រៀងអន្តរជាតិនានាចំនួន២១ច្បាប់ និងច្បាប់ស្តីពីការផ្តល់សន្និសញ្ញាចំនួន១ច្បាប់ អនុសញ្ញាចំនួន៦ច្បាប់ ពិធីសារចំនួន៣ និងអនុស្សរណៈចំនួន១ច្បាប់ រួមទាំងមានរបៀបវារៈផ្សេងទៀត ដូចជាការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តសមាជិករាជរដ្ឋាភិបាល ការបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មការជំនាញ។

*តួលេខ 1៖ ប្រៀបធៀបចំនួនកិច្ចប្រជុំ និងចំនួនអ្នកតំណាងរាស្ត្រជាមធ្យមចូលរួមក្នុង១កិច្ចប្រជុំ*




ក្នុងនីតិកាលទី៤នេះ ចំនួនកិច្ចប្រជុំ និងចំនួនអ្នកតំណាងរាស្ត្រជាមធ្យមក្នុង១កិច្ចប្រជុំ តាមទិន្នន័យរបស់ខុមហ្វ្រែលបានបង្ហាញពី ចំនួនកិច្ចប្រជុំក្នុងនីតិកាលទី៤ មានការថយចុះជាងនីតិកាល៣ ដែលក្នុងនីតិកាលទី៤នេះ មានចំនួន១០០កិច្ចប្រជុំដែលធៀបនឹងកិច្ចប្រជុំនីតិកាលទី៣ មានចំនួន១៦៨កិច្ចប្រជុំ។ បើមើលពីចំនួនអ្នកតំណាងរាស្ត្រជាមធ្យម ក្នុង១កិច្ចប្រជុំឃើញថា ក្នុងនីតិកាលទី៤ជាមធ្យម មានតំណាងរាស្ត្រចំនួន៨៤រូបដែលប្រៀបធៀបទៅនីតិកាលទី៣ មានចំនួនប្រហាក់ប្រហែលនឹងគ្នា ដែលក្នុងនីតិកាលទី៣ (កក្កដា២០០៤ ដល់កញ្ញា២០០៨) មានចំនួនអ្នកតំណាងរាស្ត្រចំនួន៨៩រូប។

## ១.១. ការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រក្នុងសម័យប្រជុំរដ្ឋសភា

ការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រ ក្នុងសម័យប្រជុំរដ្ឋសភានីតិកាលទី៤ (កញ្ញា២០០៨ -មិថុនា២០១៣) នេះ តាមទិន្នន័យរបស់ខុមហ្វ្រែលបានបង្ហាញឱ្យឃើញថា ក្នុងនីតិកាលនេះ មានគណបក្សចំនួន៥ ដែលមានអាសនៈនៅក្នុងរដ្ឋសភាដែលមានតំណាងរាស្ត្រចំនួន៦០រូប ដែលបានចំណាយពេលឡើងបញ្ចេញមតិយោបល់ពាក់ព័ន្ធបញ្ហាមួយចំនួនទៅលើសេចក្តីព្រាងច្បាប់/ស្នើច្បាប់ និងបញ្ហាផ្សេងៗ អស់រយៈពេលសរុបចំនួន៧៩៤៧នាទី(ស្មើនឹង១៣២ម៉ោង២៧នាទី)។ ក្នុងការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រ ខុមហ្វ្រែលបានសង្កេតឃើញថា មានតំណាងរាស្ត្រចំនួន២គណបក្ស បានចំណាយពេលឡើងបញ្ចេញមតិច្រើនជាងគេ ក្នុងចំណោមតំណាងរាស្ត្រទាំង៥គណបក្សដែលមានអាសនៈនៅក្នុងរដ្ឋសភា។

ក្នុងការបញ្ចេញមតិរបស់តំណាងរាស្ត្រក្នុងនីតិកាលទី៤នេះ តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាមានចំនួន៣៨រូប ដោយតំណាងរាស្ត្រគណបក្សនេះ មានអាសនៈនៅក្នុងរដ្ឋសភាចំនួន៩០អាសនៈ បានចំណាយពេលឡើងបញ្ចេញមតិទៅលើខ្លឹមសារបែបន័យអព្យាក្រឹត្យ វិជ្ជមាន អវិជ្ជមាន ចំណាយពេលវេលាសរុបអស់៣២៩៧នាទី(ស្មើនឹង៥៤ម៉ោង៥៧នាទី)។

តំណាងរាស្ត្រគណបក្សសម រង្ស៊ី ដែលមានអាសនៈក្នុងសភាចំនួន២៦រូប ក្នុងនោះមានតំណាងរាស្ត្រចំនួន១៨រូប បានចំណាយពេលក្នុងការបញ្ចេញមតិរបស់ខ្លួនទៅលើខ្លឹមសារបែបន័យអព្យាក្រឹត្យ វិជ្ជមាន អវិជ្ជមាន បានចំណាយរយៈពេលសរុបចំនួន៤៤១៩នាទី (ស្មើនឹង៧៣ម៉ោង៣៩នាទី)នៃរយៈពេលបញ្ចេញមតិសរុប។

ចំពោះតំណាងរាស្ត្រគណបក្សជាតិនិយម មានតំណាងរាស្ត្រចំនួន១រូប បានឡើងបញ្ចេញមតិ ខណៈដែលគណបក្សនេះមានអាសនៈនៅក្នុងរដ្ឋសភាចំនួន២អាសនៈ បានចំណាយពេលបញ្ចេញមតិសរុបអស់រយៈពេល១៧៣នាទី(ស្មើនឹង២ម៉ោង៥២នាទី)។

ចំណែកតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស និងតំណាងរាស្ត្រគណបក្សហ្វ៊ុនស៊ិនប៉ិច បានចំណាយពេលក្នុងបញ្ចេញមតិបានតិចតួចជាងគេបំផុត ដោយតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស ដែលមានអាសនៈនៅក្នុងសភាចំនួន៣រូបមានតំណាងរាស្ត្រចំនួន២រូប បានចំណាយពេលឡើងបញ្ចេញមតិ អស់រយៈពេលសរុបតែ៤៤នាទីប៉ុណ្ណោះ រីឯតំណាងរាស្ត្រគណបក្សហ្វ៊ុនស៊ិនប៉ិចវិញ មានតំណាងរាស្ត្រចំនួន១រូប ដែលគណបក្សនេះមានអាសនៈនៅក្នុងសភាចំនួន២រូបបានចំណាយពេលឡើងបញ្ចេញមតិសរុបចំនួន១៤នាទី។

*តួលេខ៤៖ ភាគរយតំណាងរាស្ត្រឡើងបញ្ចេញមតិធៀបនឹងតំណាងរាស្ត្រសរុបក្នុងបក្សខ្លួន*




ក្នុងការបញ្ចេញមតិ របស់តំណាងរាស្ត្របើគិតជាភាគរយ តំណាងរាស្ត្រដែលបានឡើងបញ្ចេញមតិ ធៀបទៅនឹងចំនួន តំណាងរាស្ត្រសរុប ក្នុងបក្សរបស់ខ្លួន ខុមហ្វ្រែលឃើញថា តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា មានចំនួន៣៨រូប (ស្មើនឹង៤២%នៃតំណាងរាស្ត្ររបស់បក្ស ដែលមានអាសនៈនៅក្នុងសភា៩០អាសនៈ) ចំណែកតំណាងរាស្ត្រគណបក្សសមរង្ស៊ី បានឡើងបញ្ចេញមតិចំនួន១៨រូប(ស្មើនឹង៦៩%) នៃអាសនៈរបស់ខ្លួនក្នុងសភាចំនួន២៦រូប។ ចំពោះតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស

ដែលមានអាសនៈនៅក្នុងរដ្ឋសភាចំនួន៣រូប បានឡើងបញ្ចេញមតិចំនួន២រូប(ស្មើនឹង៦៧%)នៃចំនួនតំណាងរាស្ត្រនៅក្នុងគណបក្សខ្លួន ដោយឡែក តំណាងរាស្ត្រគណបក្សហ្វ៊ុនស៊ិនប៉ិច និងតំណាងរាស្ត្រជាតិនិយមដែលសុទ្ធតែមានអាសនៈសភាចំនួន២រូប និងតំណាងរាស្ត្រគណបក្សហ្វ៊ុនស៊ិនប៉ិចចំនួន១រូប(ស្មើនឹង៥០%) និងតំណាងរាស្ត្រជាតិនិយមចំនួន១រូប ស្មើនឹង៥០%នៃចំនួនអាសនៈរបស់គណបក្សខ្លួន។

### ១.២.ការបញ្ចេញមតិជាបរិមាណរបស់អ្នកតំណាងរាស្ត្រក្នុងសម័យប្រជុំពេញអង្គរដ្ឋសភា

ការបញ្ចេញមតិរបស់តំណាងរាស្ត្រ គិតជាបរិមាណរបស់តំណាងរាស្ត្រ ក្នុងសម័យប្រជុំពេញអង្គរដ្ឋសភាក្នុងនីតិកាលទី៤នេះ មានតំណាងរាស្ត្រចំនួន៦០រូប បានចំណាយពេលឡើងបញ្ចេញមតិ ដោយផ្តោតលើខ្លឹមសារបែបន័យអព្យាក្រឹត្យ វិជ្ជមាន អវិជ្ជមាន អស់រយៈពេលសរុបចំនួន៧៩៤៧នាទី(ស្មើនឹង១៣២ម៉ោង២៧នាទី)។

*តួលេខ ៥៖ចំនួនតំណាងរាស្ត្រ និងរយៈពេលបញ្ចេញមតិតាមគណបក្ស*




បើមើលពី ចំនួនតំណាងរាស្ត្រ និងចំនួនរយៈពេលបញ្ចេញមតិ របស់តំណាងរាស្ត្រ គណបក្សប្រជាជនកម្ពុជាមានចំនួន៣៨រូប បានបញ្ចេញមតិសរុបចំនួន៣២៩៧នាទី (ស្មើនឹង៥៤ម៉ោង៥៩នាទី) តំណាងរាស្ត្រគណបក្សសម រង្ស៊ី១៨រូប បានបញ្ចេញមតិសរុប៤៤១៩នាទី (ឬ៧៣ម៉ោង៣៩នាទី) និងតំណាងរាស្ត្រជាតិនិយមមាន១រូប បានបញ្ចេញមតិសរុប១៧៣នាទី ស្មើនឹង(២ម៉ោង៥២)។ តំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សចំនួន២រូប បានបញ្ចេញមតិសរុប៤៤នាទី និងតំណាងរាស្ត្រហ្វ៊ុនស៊ិនប៉ិចចំនួន១រូបបានបញ្ចេញមតិសរុប១៤នាទី។

ក្នុងនីតិកាលទី៤(កញ្ញា២០០៨-មិថុនា២០១៣)នេះ ការបញ្ចេញមតិរបស់តំណាងរាស្ត្រគណបក្សសម រង្ស៊ី បានបញ្ចេញមតិច្រើនជាង តំណាងរាស្ត្រគណបក្សដ៏ទៃទៀតដែលមានអាសនៈនៅក្នុងរដ្ឋសភា។ ចំនួនតំណាងរាស្ត្រដែលបានបញ្ចេញមតិក្នុងនីតិកាលនេះ បែរជាមានការថយចុះជាងនីតិកាលមុន(កញ្ញា២០០៤-កក្កដា២០០៨) ដែលមានអ្នកតំណាងរាស្ត្រចំនួន៧៨រូប ដែលបានចំណាយពេលបញ្ចេញមតិ។

បើគិតជាមធ្យម តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា១រូប ជាមធ្យមបញ្ចេញមតិបានចំនួន៨៧នាទី(ស្មើនឹង១ម៉ោង២៧នាទី) ក្នុងចំណោមតំណាងរាស្ត្រទាំង៣៨រូប ដែលបានឡើងបញ្ចេញមតិតំណាងរាស្ត្រគណបក្សសម រង្ស៊ី ជាមធ្យមក្នុងតំណាងរាស្ត្រ១រូប បានចំណាយពេលបញ្ចេញមតិជាមធ្យមបានចំនួន២៤៦នាទី (ស្មើនឹង៤ម៉ោង៦នាទី) តំណាងរាស្ត្រគណបក្សជាតិនិយម គិតជាមធ្យមក្នុងតំណាងរាស្ត្រ១រូប បានបញ្ចេញមតិ១៧៣នាទី(ស្មើនឹង២ម៉ោង៥៣នាទី) ចំពោះតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស ជាមធ្យមតំណាងរាស្ត្រ១រូប បញ្ចេញមតិបានចំនួន២២នាទី ចំណែកតំណាងរាស្ត្រគណបក្សហ្វ៊ុនស៊ិនប៉ិច ជាមធ្យមក្នុងតំណាងរាស្ត្រ១រូប បើគិតជាមធ្យមបានចំណាយបញ្ចេញមតិអស់រយៈពេល១៤នាទី ។

### ១.៣. ខ្លឹមសារនៃការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រធៀបនឹងរយៈពេលសរុប

ការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រ ត្រូវបានរាប់ជាលើក និងវាស់រយៈពេលដែលគិតជានាទី ខ្លឹមសារនៃការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រក្នុងអំឡុងសម័យប្រជុំពេញអង្គ គឺត្រូវបានបែងចែកជាបីសូរ(Tone) អព្យាក្រឹត្យ វិជ្ជមាន និងអវិជ្ជមាន។

*តួលេខ២៦៖ ចំនួននាទី និងភាគរយខ្លឹមសារព្យាក្រឹត្យតាមគណបក្សនៃការបញ្ចេញមតិ (អព្យាក្រឹត្យ វិជ្ជមាន និងអវិជ្ជមាន) របស់អ្នកតំណាងរាស្ត្រ*




បើមើលពីចំនួននាទី និងភាគរយនៃខ្លឹមសារបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រ បានបង្ហាញឱ្យឃើញថា ក្នុងនីតិកាលនេះទី៤នេះ ក្នុងការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រ បានផ្តោតទៅលើខ្លឹមសារបែបន័យអព្យាក្រឹត្យ ដែលចំណាយពេលវេលាឡើងបញ្ចេញមតិ ទៅលើខ្លឹមសារបែបអព្យាក្រឹត្យអស់រយៈពេលសរុប៤៩០៩នាទី ស្មើនឹង៦១%នៃចំនួនបញ្ចេញមតិសរុប។ ចំណែកខ្លឹមសារដែលតំណាងរាស្ត្រផ្តោតទីពីរនោះ គឺក្នុងន័យខ្លឹមសារបែបអវិជ្ជមានដែលចំណាយពេលបញ្ចេញមតិបានចំនួន១៨៦៨នាទី ស្មើនឹង២៤%នៃចំនួនតំណាងរាស្ត្របញ្ចេញមតិសរុប។ ចំពោះក្នុងខ្លឹមសារបែបន័យវិជ្ជមាន ត្រូវបានតំណាងរាស្ត្រចំណាយពេលឡើងបញ្ចេញមតិសរុប១១៧០នាទី ស្មើនឹង១៥%នៃរយៈពេលបញ្ចេញមតិសរុប។

*តួលេខ ៨៖ ចំនួននាទី និងភាគរយនៃខ្លឹមសារនៃការបញ្ចេញមតិបែបអព្យាក្រឹត្យតាមគណបក្ស*

គិតពីចំនួននាទី និងភាគរយនៃខ្លឹមសារនៃការបញ្ចេញមតិបែបអព្យាក្រឹត្យទៅតាមគណបក្សនិមួយៗឃើញថា ការ




បញ្ចេញមតិរបស់តំណាងរាស្ត្រគណបក្សសម រង្ស៊ី បានចំណាយពេលបញ្ចេញមតិច្រើនជាងគេ ក្នុងចំណោមតំណាងរាស្ត្រទាំង៥គណបក្ស ដែលបានឡើងបញ្ចេញមតិ។ ការបញ្ចេញមតិរបស់តំណាងរាស្ត្រគណបក្សសម រង្ស៊ី បានចំណាយពេលឡើងបញ្ចេញមតិ ទៅលើខ្លឹមសារបែបន័យអព្យាក្រឹត្យអស់រយៈពេលចំនួន២៧០៣នាទី ស្មើនឹង៥៥%នៃការបញ្ចេញមតិលើខ្លឹមសារនេះសរុប។ ការបញ្ចេញមតិរបស់តំណាងរាស្ត្រ គណបក្សប្រជាជនកម្ពុជា ក្នុងការបញ្ចេញមតិទៅលើខ្លឹមសារបែបអព្យាក្រឹត្យ ត្រូវបានចំណាយពេលអស់២០៥៤នាទី ស្មើនឹង៤២%នៃចំនួនរយៈពេលបញ្ចេញមតិលើខ្លឹមសារនេះសរុប។ តំណាងរាស្ត្រគណបក្សជាតិនិយម បានចំណាយពេលបញ្ចេញមតិសរុបចំនួន១១៤នាទី ស្មើនឹង២%នៃការបញ្ចេញមតិលើខ្លឹមសារនេះសរុប។ ចំពោះការបញ្ចេញមតិរបស់តំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស ទៅលើខ្លឹមសារបែបអព្យាក្រឹត្យ ចំណាយពេលឡើងបញ្ចេញមតិអស់រយៈពេល៣០នាទី ស្មើនឹង១%នៃការបញ្ចេញមតិលើខ្លឹមសារអព្យាក្រឹត្យសរុប។ ចំណែកតំណាងរាស្ត្រគណបក្សហ៊្វុនស៊ិនប៉ិច ក៏បានចំណាយពេលក្នុងការបញ្ចេញមតិ ទៅលើខ្លឹមសារអព្យាក្រឹត្យរបស់គណបក្សខ្លួនចំនួន៨នាទី វាមិនស្មើនឹង១%នៃការបញ្ចេញមតិទៅលើខ្លឹមសារអព្យាក្រឹត្យសរុប។

*តួលេខ 2៖ ចំនួននាទី និងភាគរយនៃខ្លឹមសារនៃការបញ្ចេញមតិបែបវិជ្ជមានតាមគណបក្ស*




ការបញ្ចេញមតិ របស់តំណាងរាស្ត្រក្នុងខ្លឹមសារបែបវិជ្ជមាន ទៅតាមគណបក្សរបស់ខ្លួន ខុមហ្វ្រែលឃើញថា ការបញ្ចេញមតិ របស់តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាបានបញ្ចេញមតិ ក្នុងខ្លឹមសារវិជ្ជមានច្រើនជាងគេក្នុងចំណោមតំណាងរាស្ត្រ ដែលបានចំណាយពេលបញ្ចេញមតិលើខ្លឹមសារបែបន័យវិជ្ជមាន ចំណាយពេលបញ្ចេញមតិសរុបចំនួន៨៤២នាទី ស្មើនឹង៧១%នៃការបញ្ចេញលើខ្លឹមសារបែបវិជ្ជមានសរុប។ តំណាងរាស្ត្រគណបក្សសម រង្ស៊ី បានចំណាយពេលឡើងបញ្ចេញមតិទៅលើខ្លឹមសារបែបន័យវិជ្ជមាន បានចំណាយពេលបញ្ចេញមតិសរុបចំនួន២៨៨នាទី ស្មើនឹង២៥%នៃការបញ្ចេញមតិលើខ្លឹមសារវិជ្ជមានសរុប។ ចំពោះការបញ្ចេញមតិរបស់តំណាងរាស្ត្រគណបក្សជាតិនិយម បានចំណាយពេលទៅលើខ្លឹមសារបែបវិជ្ជមានបានចំនួន៣៥នាទី ស្មើនឹង៣%។ ចំណែកតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស និងតំណាងរាស្ត្រគណបក្សហ៊្វុនស៊ិនប៊ិច គឺបានចំណាយពេលបញ្ចេញមតិលើខ្លឹមសារនេះ ប្រហាក់ប្រហែលនឹងគ្នា ដោយគណបក្សទាំង២នេះ បូកបញ្ចូលគ្នាបានចំនួន៥នាទី ស្មើនឹង១%នៃការបញ្ចេញមតិលើខ្លឹមសារនេះ។

*តួលេខ 3៖ ចំនួននាទី និងភាគរយនៃខ្លឹមសារនៃការបញ្ចេញមតិបែបអវិជ្ជមានតាមគណបក្ស*




ខ្លឹមសារបែបអវិជ្ជមាន ត្រូវបានតំណាងរាស្ត្រគណបក្សសម រង្ស៊ី ដែលជាគណបក្សជំទាស់ បានចំណាយពេលបញ្ចេញមតិច្រើនជាងគេ ក្នុងចំណោមតំណាងរាស្ត្រទាំង៥គណបក្ស ដែលមានអាសនៈនៅក្នុងរដ្ឋសភា។ តំណាងរាស្ត្រគណបក្សសម រង្ស៊ី បានបញ្ចេញមតិទៅលើខ្លឹមសារបែបន័យអវិជ្ជមាន១៤២៨នាទី ស្មើនឹង៧៧%នៃចំនួនការបញ្ចេញមតិលើខ្លឹមសារបែបអវិជ្ជមានសរុប។ តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា បានចំណាយពេលបញ្ចេញមតិលើខ្លឹមសារន័យអវិជ្ជមានបានចំនួន៤០១នាទី ស្មើនឹង២១%នៃការបញ្ចេញមតិសរុបលើខ្លឹមសារបែបអវិជ្ជមាន។ ចំពោះតំណាងរាស្ត្រគណបក្សជាតិនិយម បានចំណាយពេលបញ្ចេញមតិលើខ្លឹមសារបែបនេះ អវិជ្ជមានបានចំនួន២៤នាទីស្មើនឹង១% និងតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស បានបញ្ចេញមតិសរុបលើខ្លឹមសារនេះបានចំនួន១១នាទី ស្មើនឹង១%។ ចំណែកតំណាងរាស្ត្រគណបក្សហ៊្វុនស៊ិនប៊ិច បានបញ្ចេញមតិសរុបចំនួន៤នាទីលើខ្លឹមសារបែបន័យអវិជ្ជមាន។

**១.៤. ខ្លឹមសារការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រធៀបនឹងរយៈពេលសរុបតាមគណបក្ស**

មតិខ្លឹមសារនៃការបញ្ចេញមតិរបស់តំណាងរាស្ត្រ ទៅតាមគណបក្សនីមួយៗ ធៀបនឹងរយៈពេលដែលគណបក្សរបស់ខ្លួនបានបង្ហាញឱ្យឃើញថា ការបញ្ចេញមតិរបស់តំណាងរាស្ត្រភាគច្រើន សុទ្ធតែបានបញ្ចេញមតិផ្តោតទៅតាមគោលបំណងរបស់គណបក្សរបស់ខ្លួន។

*<u>តួលេខ4៖ ចំនួននាទី និងភាគរយការបញ្ចេញមតិ អព្យាក្រឹត្យ វិជ្ជមាន អវិជ្ជមានរបស់អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា</u>*

ការបញ្ចេញមតិរបស់តំណាងរាស្ត្រ គណបក្សប្រជាជនកម្ពុជា នៅក្នុងនីតិកាលទី៤នេះ តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា បានបញ្ចេញមតិសរុបចំនួន៣២៩៧នាទី ស្មើនឹង(៥៤ម៉ោង៥៩នាទី) ដោយការបញ្ចេញមតិផ្តោតទៅលើខ្លឹមសារអព្យាក្រឹត្យច្រើនជាងគេ ដែលចំណាយពេលអស់(៣៤ម៉ោង១៤នាទី) ស្មើនឹង៦២%នៃរយៈពេលបញ្ចេញមតិសរុបរបស់គណបក្សនេះ។ ក្នុងខ្លឹមសារន័យវិជ្ជមាន ត្រូវបានតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា ចំណាយពេលបញ្ចេញមតិ(១៤ម៉ោង២០នាទី) ស្មើនឹង២៦%នៃរយៈពេលបញ្ចេញមតិសរុបរបស់គណបក្សខ្លួន។




ចំពោះក្នុងន័យអវិជ្ជមាន តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា បានប្រើរយៈពេល៤០១នាទី(៦ម៉ោង៣៨នាទី) ស្មើនឹង១៣%នៃរយៈពេលបញ្ចេញមតិសរុបគណបក្សរបស់ខ្លួន។

*<u>តួលេខ 5៖ ចំនួននាទី និងភាគរយការបញ្ចេញមតិ អព្យាក្រឹត្យ វិជ្ជមាន អវិជ្ជមាន របស់អ្នកតំណាងរាស្ត្រគណបក្សសម រង្ស៊ី</u>*




ក្នុងការបញ្ចេញមតិ របស់តំណាងរាស្ត្រគណបក្សសម រង្ស៊ី ទៅលើខ្លឹមសារអព្យាក្រឹត្យ វិជ្ជមាន អវិជ្ជមាន។ តំណាងរាស្ត្រគណបក្សសម រង្ស៊ី បានបញ្ចេញមតិផ្តោតច្រើនជាងគេក្នុងន័យអព្យាក្រឹត្យ ដែលអស់រយៈពេល(៤៥ម៉ោង៣នាទី) ស្មើនឹង៦១%នៃរយៈពេលបញ្ចេញមតិសរុបរបស់គណបក្សខ្លួន។ ក្នុងន័យខ្លឹមសារអវិជ្ជមានអស់រយៈពេល(២៣ម៉ោង៤៨នាទី) ស្មើនឹង៣២%នៃរយៈពេលបញ្ចេញមតិសរុបរបស់គណបក្សខ្លួន។ ចំពោះក្នុងខ្លឹមសារវិជ្ជមាន តំណាងរាស្ត្រគណបក្សនេះ ភាគច្រើនលើកសរសើរដល់សេចក្តីព្រាងច្បាប់ ដែលអស់រយៈពេល(៤ម៉ោង៤៨នាទី) ស្មើនឹង៧%នៃរយៈពេលដែលគណបក្សរបស់ខ្លួនបញ្ចេញមតិសរុប។

*<u>តួលេខ 6៖ ចំនួននាទី និងភាគរយការបញ្ចេញមតិ អព្យាក្រឹត្យ វិជ្ជមាន អវិជ្ជមានរបស់អ្នកតំណាងរាស្ត្រគណបក្សជាតិនិយម</u>*

ចំពោះការបញ្ចេញមតិ របស់តំណាងរាស្ត្រគណបក្សជាតិនិយម បានបញ្ចេញមតិក្នុងនីតិកាលនេះ បានបញ្ចេញមតិទៅលើខ្លឹមសារអព្យាក្រឹត្យ១១៤នាទី ស្មើនឹង៦៦%នៃរយៈពេលសរុបរបស់គណបក្ស បានបញ្ចេញមតិ។ ក្នុងខ្លឹមសារអវិជ្ជមាន២៤នាទី ស្មើនឹង១៤% នៃរយៈពេលបញ្ចេញមតិសរុបរបស់គណបក្សនេះ។ ចំណែកក្នុងខ្លឹមសារវិជ្ជមាន តំណាងរាស្ត្រគណបក្សនេះ បានចំណាយពេលឡើងបញ្ចេញមតិសរុបចំនួន៣៥នាទី ស្មើនឹង២០%។



*តួលេខ ១៧៖ ចំនួននាទី និងភាគរយការបញ្ចេញមតិ អព្យាក្រឹត្យ វិជ្ជមាន អវិជ្ជមានរបស់អ្នកតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស*




ការបញ្ចេញមតិរបស់តំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស គឺផ្តោតទៅលើខ្លឹមសារបែបន័យអព្យាក្រឹត្យ ដែលចំណាយពេលឡើងបញ្ចេញមតិច្រើនជាងគេ ដែលប្រើពេលអស់៣០នាទី ស្មើនឹង៦៨%នៃការបញ្ចេញមតិលើខ្លឹមសារនេះសរុប។ ក្នុងខ្លឹមសារបែបន័យវិជ្ជមាន តំណាងរាស្ត្រគណបក្សនេះបានចំណាយពេលបញ្ចេញមតិអស់រយៈពេល៣នាទី ស្មើនឹង ៧% និងខ្លឹមសារបញ្ចេញមតិទៅលើខ្លឹមសារ អវិជ្ជមាន បានចំណាយពេលបញ្ចេញមតិអស់រយៈពេល១១នាទី ស្មើនឹង២៥%នៃចំនួនបញ្ចេញមតិរបស់បក្សខ្លួនសរុប។

*តួលេខ ១៨៖ ចំនួននាទី និងភាគរយការបញ្ចេញមតិ អព្យាក្រឹត្យ វិជ្ជមាន អវិជ្ជមានរបស់អ្នកតំណាងរាស្ត្រគណបក្សហ៊្វុនស៊ិនប៉ិច*

ការបញ្ចេញមតិរបស់តំណាងរាស្ត្រ គណបក្សហ៊្វុនស៊ិនប៉ិចនៅក្នុងនីតិកាលទី៤នេះ តំណាងរាស្ត្រគណបក្សហ៊្វុនស៊ិនប៉ិច បានបញ្ចេញមតិ ផ្តោតទៅលើខ្លឹមសារអព្យាក្រឹត្យច្រើនជាងគេ ដែលចំណាយពេលអស់៨នាទី ស្មើនឹង៥៧%នៃរយៈពេលបញ្ចេញមតិសរុប របស់គណបក្សនេះ។ ក្នុងខ្លឹមសារន័យវិជ្ជមាន ត្រូវបានតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា ចំណាយពេលបញ្ចេញមតិ២នាទី ស្មើនឹង១៤%នៃរយៈពេលបញ្ចេញមតិសរុបរបស់គណបក្សខ្លួន។ ចំពោះក្នុងន័យអវិជ្ជមាន តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា បានប្រើរយៈពេល៤នាទីស្មើនឹង២៩%នៃរយៈពេលបញ្ចេញមតិសរុបគណបក្សរបស់ខ្លួន។




## ១.៥. ខ្លឹមសារបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រតាមគណបក្សទៅលើតួអង្គស្ថាប័ន និងចំណុចផ្សេងៗ

តារាងខាងក្រោមនេះ បានបង្ហាញពីខ្លឹមសារនៃការបញ្ចេញមតិរបស់តំណាងរាស្ត្រតាមគណបក្ស សំដៅទៅលើតួអង្គ ឬស្ថាប័ននៅក្នុងសម័យប្រជុំពេញអង្គទាំង៩លើកក្នុងនីតិកាលទី៤នេះ ដែលអ្នកតំណាងរាស្ត្របានបញ្ចេញមតិបែបខ្លឹមសារន័យអព្យាក្រឹត្យ អវិជ្ជមាន និងវិជ្ជមាន។

*តារាងទី១៖គុណភាពការបញ្ចេញមតិរបស់សមាជិកសភាតាមគណបក្សនយោបាយទាំងប្រាំទៅលើចំណុចសំខាន់ៗមួយចំនួន (គិតជានាទី)*

សំគាល់៖ អ.ក្រឹត=អព្យាក្រឹត វ.មាន=វិជ្ជមាន អ.មាន=អវិជ្ជមាន

| លរ | ចំណុចពាក់ព័ន្ធ | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | អ.ក្រ | វ.មាន | អ.មាន | អ.ក្រ | វ.មាន | អ.មាន | អ.ក្រ | វ.មាន | អ.មាន | អ.ក្រ | វ.មាន | អ.មាន | អ.ក្រ | វ.មាន | អ.មាន |
| | | | | | | | | | | | | | | | | |

| | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១ | **របៀបវារៈកំពុងពិភាក្សា** | **៣៥៥** | **២២៧** | **០** | **៥៤១** | **៩៥** | **២២១** | **១៩** | **៧** | **១២** | **០** | **១** | **០** | **៣** | **២** | |
| ២ | នាយករដ្ឋមន្ត្រី | ៨៥ | ១២៤ | ០ | ៣០ | ៧ | ១២ | ៣ | ៣ | | ០ | ០ | ០ | | | |
| ៣ | **រាជរដ្ឋាភិបាល** | **២៩៩** | **២៧៧** | **១០** | **៥៦៥** | **៧៦** | **៥៦២** | **២៦** | **១៥** | | **៤** | **០** | **៧** | | | |
| ៤ | ប្រធានរដ្ឋសភា | ៣៦ | ១៤ | ០ | ២៤ | ០ | ១ | | | | ១ | ០ | ០ | | | |
| ៥ | រដ្ឋសភា | ១១៩ | ១៤ | ១៨ | ១២០ | ៣ | ១៣ | ៨ | | ៣ | ៤ | ០ | ១ | | | |
| ៦ | គណៈកម្មកានានារបស់រដ្ឋសភា | ៩២ | ១២ | ២ | ២៣ | ២ | ២ | | | | ០ | ០ | ០ | | | |
| ៧ | ប្រធានព្រឹទ្ធសភា | ៥ | ០ | ០ | ២ | ០ | ០ | ១ | | | ០ | ០ | ០ | | | |
| ៨ | ស្ថាប័នព្រឹទ្ធសភានិងសមាជិក | ៦ | ៥ | ០ | ១១ | ០ | ១ | ២ | | | ០ | ០ | ០ | | | |
| ៩ | គណបក្សខ្លួនគាត់ | ១៣៧ | ៥៤ | ១ | ១៣៨ | ១៦ | ១ | | | | ៣ | ១ | ០ | | | |
| ១០ | គណបក្សដទៃទៀត | ៧៤ | ០ | ៦៦ | ១៩ | ៦ | ១៩ | | | | ២ | ០ | ០ | | | |
| ១១ | តំណាងរាស្ត្រខ្លួនឯង | ១០០ | ៣០ | ០ | ៨៨ | ៨ | ៤ | | | | ៥ | ០ | ០ | | | |
| ១២ | តំណាងរាស្ត្រដទៃទៀត | ២៩០ | ១០ | ២៩០ | ៦២ | ១៧ | ៣១ | ២ | | | ៥ | ០ | ០ | | | ៤ |
| ១៣ | មណ្ឌលរបស់គាត់ | ៣៤ | ១ | ០ | ២៦ | ៣ | ៣៩ | | | | ០ | ០ | ០ | | | |
| ១៤ | មណ្ឌលផ្សេងទៀត | ៤ | ០ | ០ | ៥២ | ៥ | ៤៣ | | | | ០ | ០ | ០ | | | |
| ១៥ | តុលាការ | ៣២ | ០ | ២ | ៥៦ | ៧ | ១០៥ | ១ | | | ០ | ០ | ០ | | | |
| ១៦ | បញ្ហាស្ត្រី | ២ | ៥ | ០ | ២៥ | ១ | ២១ | | | | ០ | ០ | ០ | | | |
| ១៧ | **អនុសាសន៍លើច្បាប់** | **២៨១** | **៦៩** | **១២** | **៧០៤** | **២៧** | **៤២៧** | **២៨** | **១០** | **៩** | **៣** | **១** | **៣** | | | |

| | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | កំពុងពិភាក្សា | | | | | | | | | | | | | | | |
| ១៨ | សំណួរ/សុំការបំភ្លឺច្បាប់កំពុងពិភាក្សា | ៦០ | ០ | ០ | ២៨៦ | ១៥ | ២៥ | ២៤ | | | ៣ | ០ | ០ | ៥ | | |
| ១៩ | យុវជន | ០ | ០ | ០ | ១ | ០ | ០ | | | | ០ | ០ | ០ | | | |
| ២០ | ផ្សេងៗ | ៤៣ | ០ | ០ | ៤០ | ០ | ១ | | | | ០ | ០ | ០ | | | |
| សរុប | | ៣២៩៧ | | | ៤៤១៩ | | | ១៧៣ | | | ៤៤ | | | ១៩ | | |

ក្នុងនីតិកាលទី៤នេះ អ្នកតំណាងរាស្ត្របានបញ្ចេញមតិផ្តោតខ្លាំងលើចំណុចពាក់ព័ន្ធចំនួន៣ច្រើនជាងគេ ក្នុងចំណោម២០ចំណុច គឺរាជរដ្ឋាភិបាលលើរបៀបវារៈកំពុងពិភាក្សា និងអនុសាសន៍លើច្បាប់កំពុងពិភាក្សា ដែលមានរយៈពេលសរុបចំនួន៤៦៩៦នាទី (៧៨ម៉ោង១៦នាទី) នៃរយៈពេលបញ្ចេញមតិសរុបរបស់អ្នកតំណាងរាស្ត្រ។ ក្នុងគោលបំណងទាំង៣ចំណុច ដែលតំណាងរាស្ត្របានបញ្ចេញមតិផ្តោតច្រើននោះ ខុមហ្វ្រែលសង្កេតឃើញថា ការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រ គឺបានផ្តោតទៅលើរដ្ឋាភិបាលច្រើនជាងគេ ដែលអ្នកតំណាងរាស្ត្រចំណាយពេលបញ្ចេញមតិសរុបចំនួន១៦៤១នាទី (២៧ម៉ោង២១នាទី) នៃរយៈពេលសរុបរបស់អ្នកតំណាងរាស្ត្រ។ ការផ្តល់ជាអនុសាសន៍ដែលកំពុងពិភាក្សា ត្រូវបានតំណាងរាស្ត្រផ្តោតលំដាប់ទី២ ដោយតំណាងរាស្ត្របានបញ្ចេញមតិរយៈពេលចំនួន១៥៧២នាទី (២៦ម៉ោង១២នាទី) នៃរយៈពេលសរុបរបស់អ្នកតំណាងរាស្ត្រ។ ចំពោះរបៀបវារៈកំពុងពិភាក្សាអ្នកតំណាងរាស្ត្របានបញ្ចេញមតិ១៤៨៣នាទី (២៤ម៉ោង៤៣នាទី) នៃរយៈពេលសរុបរបស់អ្នកតំណាងរាស្ត្រ។

## ការបញ្ចេញមតិលើរាជរដ្ឋាភិបាល រួមទាំងនាយករដ្ឋមន្ត្រី

ក្នុងនីតិកាលទី៤នេះ ការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រ ភាគច្រើនបញ្ចេញមតិផ្តោតទៅលើរាជរដ្ឋាភិបាល ដែលមានរយៈពេល១៦៤១នាទី (ស្មើនឹង២៧ម៉ោង២១នាទី) នៃរយៈពេលតំណាងរាស្ត្រទាំងអស់។

*តួលេខ 18៖ចំនួននាទី និងភាគរយនៃការបញ្ចេញមតិទៅលើរាជរដ្ឋាភិបាលតាមគណបក្ស*




ក្នុងនីតិកាលទី៤នេះ ការបញ្ចេញមតិរបស់តំណាងរាស្ត្រទៅលើចំណុចពាក់ព័ន្ធរាជរដ្ឋាភិបាល ខុមហ្វ្រែលឃើញថា មានតំណាងរាស្ត្រចំនួន៤គណបក្ស បានបញ្ចេញមតិទៅលើរាជរដ្ឋាភិបាល។ ការបញ្ចេញមតិរបស់តំណាងរាស្ត្រលើរាជរដ្ឋាភិបាលឃើញថា តំណាងរាស្ត្រគណបក្សសម រង្ស៊ី បានចំណាយពេលឡើងបញ្ចេញមតិ ទៅលើរាជរដ្ឋាភិបាលចំនួន១០០៣នាទី ស្មើនឹង៦១% នៃរយៈពេលសរុបទៅលើរដ្ឋាភិបាល។ តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាក្នុងនីតិកាលនេះ បានបញ្ចេញមតិទៅលើចំណុចពាក់ព័ន្ធរាជរដ្ឋាភិបាលបានចំនួន៥៨៦នាទី ស្មើនឹង៣៦%នៃរយៈពេលសរុបទៅលើរដ្ឋាភិបាល។ ចំណែកតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស

និងតំណាងរាស្ត្រគណបក្សជាតិនិយម ក្នុងការបញ្ចេញមតិទៅលើរាជរដ្ឋាភិបាលបានចំនួនតិចតួចប៉ុណ្ណោះ ដោយតំណាងរាស្ត្រគណបក្សជាតិនិយម បានបញ្ចេញមតិលើខ្លឹមសារពាក់ព័ន្ធនឹងរាជរដ្ឋាភិបាលបានចំនួន៤១នាទី ស្មើនឹង២% និងតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សបានបញ្ចេញមតិ១១នាទី ស្មើនឹង១%នៃរយៈពេលសរុបទៅលើរដ្ឋាភិបាល។

*<u>តួលេខ 19៖ ភាគរយនៃខ្លឹមសារបញ្ចេញមតិ (អព្យាក្រឹត្យ វិជ្ជមាន អវិជ្ជមាន) របស់អ្នកតំណាងរាស្ត្រធៀបនឹងរយៈពេលសរុបតាមគណបក្សទៅលើរាជរដ្ឋាភិបាល</u>*




មើលភាគរយនៃការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រ ទៅរាជរដ្ឋាភិបាលតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា បានបញ្ចេញមតិផ្តោតលើខ្លឹមសារវិជ្ជមានបានចំនួន៥១% និងបញ្ចេញមតិ លើខ្លឹមសារអព្យាក្រឹត្យចំនួន ៤៩% នៃរយៈពេលបញ្ចេញមតិសរុបរបស់គណបក្សខ្លួនទៅលើរាជរដ្ឋាភិបាល។ ចំពោះតំណាងរាស្ត្រសម រង្ស៊ី ដែលជាតំណាងរាស្ត្រគណបក្សជំទាស់ ការបញ្ចេញមតិទៅចំណុចពាក់ព័ន្ធនឹងរាជរដ្ឋាភិបាល បានបញ្ចេញមតិលើខ្លឹមសារបែបអវិជ្ជមាន៤៦% និងខ្លឹមសារន័យអព្យាក្រឹត្យ៤៦% ចំណែកខ្លឹមសារវិជ្ជមាន៨% នៃរយៈពេលបញ្ចេញមតិសរុបរបស់គណបក្សខ្លួនទៅលើរាជរដ្ឋាភិបាល។ តំណាងរាស្ត្រគណបក្សជាតិនិយម បានបញ្ចេញមតិបែបខ្លឹមសារអព្យាក្រឹត្យបានចំនួន៦៣% និងបែបខ្លឹមសារវិជ្ជមានបានចំនួន៣៧% នៃរយៈពេលបញ្ចេញមតិសរុបរបស់គណបក្សខ្លួនទៅលើរាជរដ្ឋាភិបាល។ ចំណែកតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស បានបញ្ចេញមតិទៅលើរាជរដ្ឋាភិបាល ក្នុងន័យអវិជ្ជមានបានចំនួន៦៣% និងខ្លឹមសារបែបអព្យាក្រឹត្យបានចំនួន៣៧% នៃរយៈពេលបញ្ចេញមតិសរុបរបស់គណបក្សខ្លួនទៅលើរាជរដ្ឋាភិបាល។

## ការបញ្ចេញមតិលើអនុសាសន៍កំពុងពិភាក្សា៖

ក្នុងការបញ្ចេញមតិរបស់តំណាងរាស្ត្រ ទៅលើការផ្តល់ជាអនុសាសន៍កំពុងពិភាក្សា ត្រូវបានអ្នកតំណាងរាស្ត្របានផ្តោតសំខាន់លំដាប់ទី២ ក្នុងការបញ្ចេញមតិច្រើនជាងគេក្នុងនីតិកាលទី៤នេះ៖ រយៈពេលនៃការបញ្ចេញមតិរបស់តំណាងរាស្ត្រទៅលើចំណុច ការផ្តល់ជាអនុសាសន៍ដែលកំពុងពិភាក្សា ត្រូវបានអ្នកតំណាងរាស្ត្រចំណាយពេលក្នុងការបញ្ចេញមតិអស់រយៈពេល១៥៧៤នាទី (ស្មើនឹង២៦ម៉ោង១៤នាទី)នៃការបញ្ចេញមតិសរុបរបស់អ្នកតំណាងរាស្ត្រ។

*<u>តួលេខ 20៖ចំនួននាទី និងភាគរយនៃការបញ្ចេញមតិទៅលើអនុសាសន៍លើច្បាប់កំពុងពិភាក្សាតាមគណបក្ស</u>*




ការបញ្ចេញមតិរបស់តំណាងរាស្ត្រ ក្នុងការផ្តល់ជាអនុសាសន៍លើច្បាប់កំពុងពិភាក្សា តាមគណបក្សឃើញថា ការបញ្ចេញមតិរបស់តំណាងរាស្ត្រគណបក្សសម រង្ស៊ី ដែលបានបញ្ចេញមតិទៅលើខ្លឹមសារ ការផ្តល់ជាអនុសាសន៍លើច្បាប់ កំពុង

ពិភាក្សា តំណាងរាស្ត្រគណបក្សនេះបានចំណាយពេលឡើងបញ្ចេញមតិច្រើនជាងគេ។ តំណាងរាស្ត្រគណបក្សសម រង្ស៊ី បានចំណាយពេលក្នុងការបញ្ចេញមតិ ក្នុងការផ្តល់ជាអនុសាសន៍បានចំនួន១១៥៨នាទី ស្មើនឹង៧៤%នៃរយៈពេលសរុបរបស់គណបក្សខ្លួនបញ្ចេញមតិលើចំណុចនេះ។ តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា បញ្ចេញមតិចំនួន៣៦២នាទី ស្មើនឹង២៣% នៃរយៈពេលសរុបរបស់គណបក្សខ្លួន បញ្ចេញមតិលើចំណុចនេះ។ ចំណែកតំណាងរាស្ត្រគណបក្សជាតិនិយម បញ្ចេញមតិ៤៧នាទី និងតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស បានចំណាយពេលបញ្ចេញមតិចំនួន៧នាទី នៃរយៈពេលសរុបរបស់គណបក្សខ្លួន បញ្ចេញមតិលើចំណុចនេះ។

*តួលេខ 21៖ភាគរយនៃខ្លឹមសារបញ្ចេញមតិ(អព្យាក្រឹត្យ វិជ្ជមាន អវិជ្ជមាន)របស់អ្នកតំណាងរាស្ត្រធៀបនឹងរយៈពេលសរុបតាមគណបក្សទៅលើអនុសាសន៍លើច្បាប់កំពុងពិភាក្សា(សេចក្តីព្រាងច្បាប់)*




បើមើលពី ភាគរយនៃខ្លឹមសារបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រ ធៀបនឹងរយៈពេលសរុបតាមគណបក្ស ទៅលើការផ្តល់ជាអនុសាសន៍លើច្បាប់កំពុងពិភាក្សាឃើញថា ការបញ្ចេញមតិរបស់តំណាងរាស្ត្រ គឺភាគច្រើនបញ្ចេញមតិលើខ្លឹមសារ បែបន័យអព្យាក្រឹត្យ។ តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា បានបញ្ចេញមតិខ្លឹមសារ បែបន័យអព្យាក្រឹត្យបាន ៧៨% វិជ្ជមាន១៩% និងអវិជ្ជមាន៣%នៃរយៈពេលសរុបរបស់គណបក្សខ្លួនបញ្ចេញមតិលើចំណុចនេះ។ ចំណែកតំណាងរាស្ត្រគណបក្សសម រង្ស៊ី ការបញ្ចេញមតិភាគច្រើន ផ្តោតទៅលើខ្លឹមសារបែបអព្យាក្រឹត្យដោយប្រើអស់៦១% បែបអវិជ្ជមាន៣៧% និងវិជ្ជមានចំនួន២%នៃរយៈពេលសរុបរបស់គណបក្សខ្លួន បញ្ចេញមតិលើចំណុចនេះ។ តំណាងរាស្ត្រគណបក្សជាតិនិយម បានចំណាយពេលបញ្ចេញមតិលើខ្លឹមសារ ន័យអព្យាក្រឹត្យចំនួន៦០% អវិជ្ជមាន១៩% និងវិជ្ជមាន២១%នៃរយៈពេលសរុបរបស់គណបក្សខ្លួនបញ្ចេញមតិលើចំណុចនេះ។ ចំពោះតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស បានបញ្ចេញមតិលើខ្លឹមសារបែបអព្យាក្រឹត្យចំនួន៤៣% អវិជ្ជមាន៤៣% និងវិជ្ជមាន១៤%នៃរយៈពេលសរុបរបស់គណបក្សខ្លួនបញ្ចេញមតិលើការផ្តល់ជាអនុសាសន៍លើច្បាប់ដែលកំពុងពិភាក្សា។

## ការបញ្ចេញមតិលើរបៀបវារៈកំពុងពិភាក្សា

រយៈពេលបញ្ចេញមតិ ភាគច្រើនលំដាប់ទី៣របស់អ្នកតំណាងរាស្ត្រ គឺផ្តោតទៅលើការបញ្ចេញមតិយោបល់ទៅលើអត្ថបទច្បាប់ និងបញ្ហានានាដែលទាក់ទងនឹងសេចក្តីព្រាងច្បាប់ ជារបៀបវារៈកំពុងពិភាក្សាចំនួន១៤៨៣នាទី(២៤ម៉ោង៤៣នាទី)។




*តួលេខ 22៖ចំនួននាទី និងភាគរយនៃការបញ្ចេញមតិទៅលើរបៀបវារៈកំពុងពិភាក្សាតាមគណបក្ស*

ក្នុងការបញ្ចេញមតិរបស់តំណាងរាស្ត្រទៅលើរបៀបវារៈកំពុងពិភាក្សាទៅតាមគណបក្ស ខាងខុមហ្វ្រែលសង្កេតឃើញថា មានអ្នកតំណាងរាស្ត្រចំនួន៥គណបក្ស សុទ្ធ

តែបានបញ្ចេញមតិទាក់ទងនឹងរបៀបវារៈពិភាក្សា (សេចក្តីព្រាងច្បាប់)នេះ។ ក្នុងនោះ តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា បានបញ្ចេញមតិសរុបទៅលើសេចក្តីព្រាងច្បាប់៥៨២នាទី (ស្មើនឹង៣៩%)។ ចំពោះតំណាងរាស្ត្រគណបក្សសម រង្ស៊ី បានចំណាយពេលបញ្ចេញមតិអស់៨៥៧នាទី (ស្មើនឹង៥៨%)។ ចំណែកតំណាងរាស្ត្រគណបក្សជាតិនិយម បានចំណាយពេលបញ្ចេញមតិអស់៣៨នាទី (ស្មើនឹង៣%%)ទៅលើរបៀបវារៈកំពុងពិភាក្សា។ ដោយឡែក តំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស និងតំណាងរាស្ត្រគណបក្សហ៊្វុនស៊ិនប៉ិច បានចំណាយពេលបញ្ចេញមតិទៅលើរបៀបវារៈកំពុងពិភាក្សានេះបានតិចតួចប៉ុណ្ណោះ។ តំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស១នាទី និងតំណាងរាស្ត្រគណបក្សហ៊្វុនស៊ិនប៉ិចបានចំនួន៥នាទី។

*តួលេខ 23៖ភាគរយនៃខ្លឹមសារបញ្ចេញមតិ (អព្យាក្រឹត្យ វិជ្ជមាន អវិជ្ជមាន) របស់អ្នកតំណាងរាស្ត្រធៀបនឹងរយៈពេលសរុបតាមគណបក្សទៅលើរបៀបវារៈពិភាក្សា(សេចក្តីព្រាងច្បាប់)*




បើមើលខ្លឹមសារ នៃការបញ្ចេញមតិរបស់តំណាងរាស្ត្រក្នុងន័យ (អព្យាក្រឹត្យ វិជ្ជមាន អវិជ្ជមាន) ខុមប្រ៊្វែលឃើញថា ការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រ តាមគណបក្សធៀបទៅនឹងរយៈពេលសរុប តំណាងរាស្ត្រតាមគណបក្សនីមួយៗ បានបញ្ចេញមតិទៅលើសេចក្តីព្រាងច្បាប់បង្ហាញថា ក្នុងចំណោមតំណាងរាស្ត្រទាំង៥គណបក្ស ការបញ្ចេញមតិរបស់តំណាងរាស្ត្រភាគច្រើនបានបញ្ចេញមតិផ្តោតក្នុងន័យអព្យាក្រឹត្យច្រើនជាងគេ។ ការបញ្ចេញមតិរបស់តំណាងរាស្ត្រ គណបក្សប្រជាជនកម្ពុជា បានបញ្ចេញមតិលើរបៀបវារៈកំពុងពិភាក្សាក្នុងន័យសូរ (Tone) វិជ្ជមាន៣៩% ស្មើនឹង២២៧នាទី(នៃរយៈពេលសរុបរបស់គណបក្សខ្លួន បានបញ្ចេញមតិលើចំណុចនេះ) ចំណែកក្នុងន័យអព្យាក្រឹត្យ បានបញ្ចេញមតិចំនួន៦១% ស្មើនឹង៣៥៥នាទី។ ចំពោះការបញ្ចេញមតិរបស់តំណាងរាស្ត្រគណបក្សសម រង្ស៊ី ភាគច្រើនបញ្ចេញមតិផ្តោតទៅលើខ្លឹមសារបែបអព្យាក្រឹត្យ៦៣% ស្មើនឹង៥៤១នាទី (នៃរយៈពេលសរុបរបស់គណបក្សខ្លួន បានបញ្ចេញមតិលើចំណុចនេះ) ក្នុងខ្លឹមសារបែបន័យអវិជ្ជមាន តំណាងរាស្ត្រគណបក្សសម រង្ស៊ី បានបញ្ចេញមតិសរុប២៦% (ស្មើនឹង២២១នាទី) និងក្នុងន័យបែបវិជ្ជមានបាន១១% (ស្មើនឹង៩៥នាទី) នៃរយៈពេលសរុបរបស់គណបក្សខ្លួន បានបញ្ចេញមតិលើចំណុចនេះ។ ចំណែកការបញ្ចេញមតិរបស់តំណាងរាស្ត្រ គណបក្សជាតិនិយមវិញ បានបញ្ចេញមតិក្នុងន័យអព្យាក្រឹត្យ១៩នាទី ស្មើនឹង៥០% អវិជ្ជមាន១២នាទី ស្មើនឹង៣២% និងវិជ្ជមាន៧នាទី ស្មើនឹង១៨%ទៅលើរបៀបវារៈ ដែលកំពុងពិភាក្សាមានខ្លឹមសារប្រហាក់ប្រហែលនឹងតំណាងរាស្ត្រគណបក្សសម រង្ស៊ី។ តំណាងរាស្ត្រគណបក្សហ៊្វុនស៊ិនប៉ិច បញ្ចេញមតិក្នុងខ្លឹមសារអព្យាក្រឹត្យ៣នាទី ស្មើនឹង៦០% និងវិជ្ជមាន២នាទី ស្មើនឹង៤០% នៃរយៈពេលសរុបរបស់គណបក្សខ្លួន បានបញ្ចេញមតិលើចំណុចនេះ។

*តារាង 1៖ ការប៉ាន់ប្រមាណគុណភាពការបញ្ចេញមតិរបស់តំណាងរាស្ត្រ ១០រូប ដែលឈានមុខគេក្នុង ការបញ្ចេញមតិ តាមលំដាប់ពីច្រើនទៅតិច (រយៈពេលជានាទី)( សូមមើលបន្ថែមនៅឧបសម្ព័ន្ធទី ២ )*

-សំគាល់:ឯ.ឧ. = ឯកឧត្តម, ល.ជ. = លោកជំទាវ

| ល.រ | ឈ្មោះតំណាងរាស្ត្រ | គណបក្ស | ចំនួនដងឡើងនិយាយ | អព្យាក្រឹត | វិជ្ជមាន | អវិជ្ជមាន | សរុប |
|---|---|---|---|---|---|---|---|
| ១ | ឯ.ឧ. យឹម សុវណ្ណ | | ៩២ | ៦៤៤ | ១១៥ | ៥២២ | **១២៨១** |
| ២ | ឯ.ឧ. សុន ឆ័យ | | ៨៥ | ៨២១ | ៥៥ | ៣០៥ | **១១៨១** |
| ៣ | ឯ.ឧ. ជាម យៀប | | ៧៨ | ៥៦១ | ១៣៦ | ៧០ | **៧៦៧** |
| ៤ | ឯ.ឧ. ឈាង វុន | | ៧១ | ៣១១ | ១៤៨ | ៨៥ | **៥៤៤** |
| ៥ | ល.ជ. មួរ សុខហួរ | | ៤៧ | ៣៥៦ | ៤០ | ១៤៣ | **៥៣៩** |
| ៦ | ឯ.ឧ. គឹមសួរ ភីរិទ្ធិ | | ២៥ | ១៧០ | ១៧ | ១២៧ | **៣១៤** |
| ៧ | ឯ.ឧ. ប៉ែន បញ្ញា | | ៣៧ | ១៥៤ | ១៤៣ | ១៣ | **៣១០** |
| ៨ | ឯ.ឧ. ជាម ច័ន្ទនី | | ១៧ | ១៧៨ | ២៨ | ៥១ | **២៥៧** |
| ៩ | ឯ.ឧ. ងួន ញ៉ិល | | ៤៥ | ១៦៤ | ២៥ | ៣៦ | **២២៥** |
| ១០ | ឯ.ឧ. ហែម ខន | | ១៩ | ១៧០ | ១៨ | ៧ | **១៩៥** |

ក្នុងនីតិកាលទី៤នេះ ខុមហ្វ្រែលសង្កេតឃើញថា មានអ្នកតំណាងរាស្ត្រចំនួន១០រូប ដែលបានឡើងបញ្ចេញមតិច្រើនជាងគេ ក្នុងចំណោមតំណាងរាស្ត្រដែលបានឡើងបញ្ចេញមតិសរុប ក្នុងនោះមានតំណាងរាស្ត្រ៥រូប មកពីគណបក្សសម រង្ស៊ី និង៥រូបទៀត មកពីគណបក្សប្រជាជនកម្ពុជា។ ក្នុងចំណោមតំណាងរាស្ត្រទាំង១០រូបនេះ មានតំណាងរាស្ត្រ៥រូប បានបញ្ចេញមតិច្រើនជាងគេ ក្នុងនោះមានតំណាងរាស្ត្រគណបក្សសម រង្ស៊ី៣រូប និងតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា២រូប។ តំណាងរាស្ត្រគណបក្សសម រង្ស៊ីភាគច្រើន បញ្ចេញមតិក្នុងខ្លឹមសារន័យអព្យាក្រឹត្យ និងន័យអវិជ្ជមានចំពោះតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាទាំង៥រូប ក្នុងចំណោមតំណាងរាស្ត្រទាំង១០រូប ដែលបានឡើងបញ្ចេញមតិច្រើនជាងគេ ក្នុងឆ្នាំសង្កេតនេះ ភាគច្រើនបញ្ចេញមតិក្នុងន័យអព្យាក្រឹត្យ និងន័យវិជ្ជមាន។

អ្នកតំណាងរាស្ត្រ យឹម សុវណ្ណ មណ្ឌលភ្នំពេញមកពីគណបក្សសម រង្ស៊ី ដែលបានឡើងបញ្ចេញមតិច្រើនជាងគេ ដោយបានឡើងចំនួន៩២លើក និងប្រើរយៈពេលអស់១២៨១នាទី (ស្មើនឹង២១ម៉ោង២១នាទី) ដែលក្នុងនោះខ្លឹមសារក្នុងន័យអព្យាក្រឹត្យ រយៈពេល(១០ម៉ោង៤៤នាទី) វិជ្ជមាន១ម៉ោង៥៥នាទី និងអវិជ្ជមាន៨ម៉ោង៤២នាទី។

អ្នកតំណាងរាស្ត្រ សុន ឆ័យ មណ្ឌលភ្នំពេញមកពីគណបក្សសមរង្ស៊ី បានឡើងបញ្ចេញមតិលំដាប់ទី២ ដោយប្រើរយៈពេលបាន៨៥លើក ដែលប្រើពេលអស់១១៨១នាទី(ស្មើនឹ១៩ម៉ោង៤១នាទី) ដោយបញ្ចេញមតិក្នុងន័យអព្យាក្រឹត្យ (១៣ម៉ោង៤១នាទី) វិជ្ជមាន៥៥នាទី និងអវិជ្ជមាន៥ម៉ោង០៥នាទី។

អ្នកតំណាងរាស្ត្រ ជាម យៀប មណ្ឌលព្រៃវែង មកពីគណបក្សប្រជាជនកម្ពុជា បានឡើងបញ្ចេញមតិច្រើនលំដាប់ទី៣ ដោយបានឡើងចំនួន៧៨លើក ដោយប្រើរយៈពេលអស់៧៦៧នាទី (ស្មើនឹង១២ម៉ោង៤៧នាទី) ដែលក្នុងនោះ ខ្លឹមសារក្នុងន័យអព្យាក្រឹត្យអស់រយៈពេល៩ម៉ោង២១នាទី វិជ្ជមាន២ម៉ោង១៦នាទី និងអវិជ្ជមាន១ម៉ោង១០នាទី។

អ្នកតំណាងរាស្ត្រ ឈាង វុន មណ្ឌលបាត់ដំបង មកពីគណបក្សប្រជាជនកម្ពុជា បានឡើងបញ្ចេញមតិច្រើនលំដាប់ទី៤ ដោយបានឡើងចំនួន៧១លើក និងប្រើរយៈពេលអស់៥៤៤នាទី (ស្មើនឹង៩ម៉ោង៤នាទី) បានបញ្ចេញមតិក្នុងខ្លឹមសារន័យអព្យាក្រឹត្យ រយៈពេល៥ម៉ោង១១នាទី វិជ្ជមាន២ម៉ោង២៨នាទី និងអវិជ្ជមាន១ម៉ោង២៥នាទី។

អ្នកតំណាងរាស្ត្រ មួរ សុខហួរ មណ្ឌលកំពត មកពីគណបក្សសម រង្ស៊ី បានឡើងបញ្ចេញមតិច្រើនលំដាប់ទី៥ ដោយបានឡើងបញ្ចេញមតិចំនួន៤៧លើក និងប្រើរយៈពេលអស់៥៣៩នាទី (ស្មើនឹង៨ម៉ោង៥៩នាទី) ដោយបានបញ្ចេញមតិ ក្នុងខ្លឹមសារន័យអព្យាក្រឹត្យរយៈពេល៥ម៉ោង៥៦នាទី វិជ្ជមាន៤០នាទី និងអវិជ្ជមាន២ម៉ោង២៣នាទី។

## ២. ការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ

រដ្ឋធម្មនុញ្ញមាត្រា៧៧បានកំណត់ថា តំណាងរាស្ត្រក្នុងរដ្ឋសភា ជាតំណាងប្រជាជាតិខ្មែរទាំងមូល ពុំមែនគ្រាន់តែជាតំណាងប្រជាពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួននោះទេ។ មាត្រា៨៣ ក៏បានកំណត់ដែរថា រដ្ឋសភាប្រជុំជាសមញ្ញពីរដងក្នុងមួយឆ្នាំ ដោយសម័យប្រជុំមួយដងមានថិរៈវេលាយ៉ាងតិចបីខែ។

សមាជិកសភា អាចមានពេលសម្រាកពីការប្រជុំពេញអង្គចំនួន៦ខែ ក្នុងរយៈពេលមួយឆ្នាំ សម្រាប់សកម្មភាពការងារផ្សេងៗ ក្នុងនាមជាតំណាងប្រជាពលរដ្ឋ ទោះបីជានៅក្នុងរយៈពេលសម័យប្រជុំ៣ខែក៏ដោយ ក៏ការសង្កេតរបស់ខុមហ្វ្រែលបានបង្ហាញថា រដ្ឋសភាមិនមែនប្រជុំពេញរយៈពេល៣ខែនោះដែរ។ ដូចនេះតំណាងរាស្ត្រក្រៅពីការប្រជុំពិភាក្សានៅវិមានរដ្ឋសភា ក៏អាចចំណាយពេលវេលារបស់ខ្លួនក្នុងការចុះទៅតាមមូលដ្ឋាន ដើម្បីជួបម្ចាស់ឆ្នោតផងដែរ។

ចំពោះការចុះមូលដ្ឋានរបស់តំណាងរាស្ត្រ គណៈកម្មាធិការខុមហ្វ្រែល ត្រូវបានកំណត់រាប់ជាចំនួនដង។ ទោះជាយ៉ាងណាក៏ដោយ ខុមហ្វ្រែលនៅតែមានការជួបបញ្ហាឧបសគ្គមួយចំនួន ក្នុងការប្រមូលព័ត៌មានទាក់ទងនឹងការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ លើសពីនេះចំពោះការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ ក៏អាចមានការចុះមូលដ្ឋាន ច្រើនជាងទិន្នន័យដែលខុមហ្វ្រែលប្រមូលបានផងដែរ។

### ២.១. ចំនួនដង និងចំនួនអ្នកតំណាងរាស្ត្រចុះមូលដ្ឋាន

ក្នុងនីតិកាលទី៤នេះ តាមការប្រមូលព័ត៌មានរបស់ខុមហ្វ្រែលបានទទួលទិន្នន័យបង្ហាញថា ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រក្នុងអាណត្តិទី៤នេះបានសង្កេតឃើញថា ចំនួនការចុះមូលដ្ឋានរបស់តំណាងរាស្ត្រមានការថយចុះជាងនីតិកាលទី៣ (២០០៤- ២០០៨) ដែលមានអ្នកតំណាងរាស្ត្រ។ ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រក្នុងនីតិកាលទី៤នេះ មានអ្នកតំណាងរាស្ត្រសរុបចំនួន១៣៣រូប (ក្នុងរបាយការណ៍របស់ខុមហ្វ្រែល ដែលបានបង្ហាញពីចំនួនអ្នកតំណាងរាស្ត្រដែលមានការលើសទៅដល់ចំនួន១៣៣រូបនោះ ក្នុងចន្លោះនីតិកាលទី៤ រដ្ឋសភាមានការផ្លាស់ប្តូរអ្នកតំណាងរាស្ត្រថ្មីចំនួន១០រូប ដែលបណ្តាលនាំឱ្យចំនួនអ្នកតំណាងរាស្ត្រចុះមូលដ្ឋាន នៅក្នុងរបាយការណ៍របស់ខុមហ្វ្រែលមានការកើនដល់ទៅ១៣៣រូប ដោយក្នុងរដ្ឋសភាមានចំនួន១២៣រូប) បានចុះធ្វើសកម្មភាពនៅក្នុងមូលដ្ឋានបានចំនួនសរុប៨៧២៥លើក ដោយគិតជាមធ្យមក្នុងមួយឆ្នាំ មានអ្នកតំណាងរាស្ត្រចុះមូលដ្ឋានសរុបចំនួន១៧៤៥លើក ឬក្នុងមួយខែមានអ្នកតំណាងរាស្ត្រចុះមូលដ្ឋានបានប្រមាណ៧២៧លើក។ បើគិតជាមធ្យមក្នុងមួយថ្ងៃ មានអ្នកតំណាងរាស្ត្រចុះមូលដ្ឋានបានចំនួន២៤លើក។

*<u>តួលេខ 7៖ កំណើនចំនួនអ្នកតំណាងរាស្ត្រចុះមូលដ្ឋាន និងចំនួនចុះមូលដ្ឋានជា% ធៀបនឹងនីតិកាលទី៣ (កក្កដា ២០០៤-កញ្ញា២០០៨)</u>*

បើមើលពីចំនួនអ្នកតំណាងរាស្ត្រចុះមូលដ្ឋាននៅក្នុងនីតិកាលទី៤នេះ ធៀបនឹងនីតិកាលទី៣ (កក្កដា២០០៤-

កញ្ញា២០០៨) តាមទិន្នន័យរបស់ខុមហ្វ្រែលបានបង្ហាញថា ចំនួនអ្នកតំណាងរាស្ត្រចុះមូលដ្ឋាននៅក្នុងនីតិកាលទី៤នេះ មានការកើនឡើងជាងនីតិកាលមុនចំនួន១៣% ដែលនីតិកាលនេះ មានអ្នកតំណាងរាស្ត្រចុះចំនួន១៣៣រូប ធៀបនឹងចំនួនអ្នកតំណាងរាស្ត្រចុះមូលដ្ឋាននៅក្នុងនីតិកាលទី៣ ចុះបានចំនួន១១៤រូប។ បើមើលពីចំនួនចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រវិញ ខុមហ្វ្រែលឃើញថា ចំនួនចុះមូលដ្ឋានរបស់តំណាងរាស្ត្រក្នុងនីតិកាលទី៤នេះ មានការថយចុះជាងការចុះមូលដ្ឋានក្នុងនីតិកាលទីមុន (នីតិកាលទី៣៖ កក្កដា ឆ្នាំ២០០៤-កញ្ញា ឆ្នាំ២០០៨) ដែលចុះបានដល់ទៅ៩៦១៩លើក។

*<u>តួលេខ៨៖ ចំនួន និងភាគរយតំណាងរាស្ត្រតាមគណបក្សចុះមូលដ្ឋានធៀបនឹងចំនួនតំណាងចុះមូលដ្ឋានសរុប</u>*




ក្នុងការចុះមូលដ្ឋានរបស់តំណាងរាស្ត្រ តាមគណបក្សធៀបនឹងចំនួនតំណាងរាស្ត្រចុះមូលដ្ឋានសរុប ឃើញថាក្នុងអាណត្តិទី៤នេះ ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាចុះមូលដ្ឋានបាន៩៥[1]រូប ស្មើនឹង៧១% នៃចំនួនតំណាងរាស្ត្រចុះមូលដ្ឋានសរុប។ តំណាងរាស្ត្រគណបក្សសម រង្ស៊ី៣១[២]រូប ស្មើនឹង២៣%នៃចំនួនអ្នកតំណាងរាស្ត្រចុះមូលដ្ឋានសរុប។ តំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សចុះមូលដ្ឋាន៣រូប ស្មើនឹង២%នៃចំនួនអ្នកតំណាងរាស្ត្រចុះមូលដ្ឋានសរុប។ ចំពោះតំណាងរាស្ត្រគណបក្សហ្វ៊ុនស៊ិនប៉ិច២រូប(២%) និងតំណាងរាស្ត្រគណបក្សជាតិនិយម២រូប ស្មើនឹង២%។

*<u>តួលេខ ៩៖ភាគរយនៃអាសនៈរដ្ឋសភា និងចំនួនអ្នកតំណាងរាស្ត្រចុះមូលដ្ឋានសរុបតាមគណបក្ស</u>*




ភាគរយនៃអាសនៈរដ្ឋសភា និងចំនួនអ្នកតំណាងរាស្ត្រ ចុះមូលដ្ឋាន សរុបតាមគណបក្សនីមួយៗ បានបង្ហាញឱ្យឃើញថា មានតំណាងរាស្ត្រចំនួន២គណបក្សដែលមានអាសនៈ នៅក្នុងរដ្ឋសភាបានចុះមូលដ្ឋានមានការសមាមាត្រគ្នា ក្នុងចំណោមតំណាងរាស្ត្រដែលចុះមូលដ្ឋាន សរុបមានតំណាងរាស្ត្រគណបក្សជាតិនិយម បានចុះមូលដ្ឋានចំនួន១%នៃចំនួនការចុះមូលដ្ឋានសរុប ខណៈដែលគណបក្សនេះមានអាសនៈក្នុងរដ្ឋសភាចំនួន២%នៃអាសនៈសភាសរុប ចំពោះតំណាងរាស្ត្រគណបក្សសម រង្ស៊ី ចុះមូលដ្ឋានបាន២៣%នៃការចុះមូលដ្ឋានសរុប ខណៈដែលគណបក្សនេះមានអាសនៈនៅក្នុងសភាចំនួន២១%នៃចំនួនអាសនៈសភាសរុប។ តំណាងរាស្ត្រគណបក្សហ្វ៊ុនស៊ិនប៉ិច ដែលមាន

(1) ជាក់ស្តែងតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា គឺមានសមាជិកនៅក្នុងសភាសរុបចំនួន៩០រូប ដោយចំនួននៅក្នុងរបាយការណ៍បានបង្ហាញដល់ទៅ៩៥រូប ដោយសារក្នុងអាណត្តិទី៤នេះ សមាជិកសភាតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា មានការផ្លាស់ប្តូរមួយចំនួនដែលបណ្តាលឱ្យចំនួនសមាជិកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាមានការកើនឡើងលើសពីចំនួនអាសនៈសភាជាក់ស្តែង។

(២) តំណារាស្ត្រគណបក្សសម រង្ស៊ី ក្នុងនីតិកាលទី៤នេះមានការផ្លាស់ប្តូរដូចនឹងករណីតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាផងដែរ។

អាសនៈនៅក្នុងរដ្ឋសភា២%នៃអាសនៈសភាសរុប បានចុះធ្វើសកម្មភាពក្នុងមូលដ្ឋានបានចំនួន២%នៃការចុះមូលដ្ឋានសរុប។ ចំណែកតំណាងរាស្ត្រចំនួន២ គណបក្សដែលមានអាសនៈនៅក្នុងរដ្ឋសភា ដូចជាតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា ដែលមានអាសនៈនៅក្នុងរដ្ឋសភាចំនួន៧១%នៃអាសនៈសភាសរុប បានចុះធ្វើសកម្មភាពក្នុងមូលដ្ឋានបានចំនួនតែ៥៨%នៃចំនួនចុះមូលដ្ឋានសរុប។ តំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស ចុះមូលដ្ឋាន១៧% ខណៈអាសនៈក្នុងសភាមាន៣%នៃចំនួនអាសនៈសភាសរុប។

*តួលេខ 10៖ភាគរយតំណាងរាស្ត្រចុះមូលដ្ឋានធៀបទៅនឹងចំនួនតំណាងរាស្ត្រសរុបក្នុងគណបក្សរបស់ខ្លួន*

ភាគរយការចុះមូលដ្ឋានរបស់តំណាងរាស្ត្រ ដែលបានចុះមូលដ្ឋានធៀបទៅនឹងចំនួនតំណាងរាស្ត្រសរុបក្នុងគណបក្សរបស់ខ្លួន នៅក្នុងនីតិកាលទី៤ តាមទិន្នន័យរបស់ខុមហ្វ្រែលបានបង្ហាញថា តំណាងរាស្ត្រទាំង៥គណបក្ស ដែលមានអាសនៈនៅក្នុងរដ្ឋសភាសុទ្ធតែបានចុះមូលដ្ឋានរបស់ខ្លួន ទាំងអស់ ដូចជាគណបក្សប្រជាជនកម្ពុជា ចុះមូលដ្ឋាន១០០% (នៃចំនួនតំណាងរាស្ត្រ គណបក្សរបស់ខ្លួន៩០រូប)។ តំណាងរាស្ត្រគណបក្សសម រង្ស៊ី បានចុះមូលដ្ឋាន១០០% (នៃចំនួនតំណាងរាស្ត្រគណបក្សរបស់ខ្លួន២៦រូប)។ ចំពោះតំណាងរាស្ត្រ៣គណបក្ស ដូចជាតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស(៣រូប) តំណាងរាស្ត្រគណបក្សហ្វ៊ុនស៊ិនប៉ិច(២រូប) និងតំណាងរាស្ត្រគណបក្សជាតិនិយម(២រូប) ។




*តួលេខ229៖ ចំនួននៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រសរុបតាមគណបក្ស*

បើមើលពីចំនួននៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រសរុប តាមគណបក្សនៅក្នុងនីតិកាលទី៤នេះ ក៏បានបង្ហាញឱ្យឃើញថា ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រ គណបក្សប្រជាជនកម្ពុជាមានការចុះច្រើនជាងគេ ដោយតំណាងរាស្ត្រ គណបក្សប្រជាជនកម្ពុជា មានចំនួន៩៥រូប បានចុះធ្វើសកម្មភាព នៅមូលដ្ឋានចំនួន៥០៨០លើក។ ចំពោះការចុះមូលដ្ឋាន របស់តំណាងរាស្ត្រគណបក្សសម រង្ស៊ី មានអ្នកតំណាងរាស្ត្រចំនួន៣១រូប បានចុះធ្វើសកម្មភាពនៅក្នុងមូលដ្ឋាន ច្រើនលំដាប់ទី២ ដោយបានចុះមូលដ្ឋានសរុប



ចំនួន១៩៩៩លើក។ ចំណែកការចុះមូលដ្ឋានរបស់តំណាងរាស្ត្រ គណបក្សសិទ្ធិមនុស្សចំនួន៣រូប ចុះបានដល់ទៅ ១៤៤០លើក។ ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សហ៊្វុនស៊ិនប៉ិច ដែលមានសមាជិកចំនួន២រូបនៅក្នុងរដ្ឋសភា បានចុះមូលដ្ឋានតាមមណ្ឌលរបស់ខ្លួនបានចំនួន១៣៥លើក និងតំណាងរាស្ត្រគណបក្សជាតិនិយមមាន២រូប ចុះមូលដ្ឋានបាន៧២លើក។

ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រតាមគណបក្សនីមួយៗ តាមទិន្នន័យរបស់ខុមហ្វ្រែល ក្នុងអំឡុងពេលមួយអាណត្តិ ក្នុងនីតិកាលទី៤ បានបង្ហាញឱ្យឃើញថា បើពិនិត្យមើលពីការចុះមូលដ្ឋានរបស់តំណាងរាស្ត្រ គិតជាមធ្យមក្នុងតំណាងរាស្ត្រ១រូប បានឱ្យឃើញថា ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស បានចុះមូលដ្ឋានច្រើនជាគេ តំណាងរាស្ត្រគណបក្សសម រង្ស៊ី ច្រើនលំដាប់ទីពីរ និងតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាលំដាប់ទី៣។ ជាមធ្យមតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា ក្នុងម្នាក់បានចុះមូលដ្ឋាន៥៣លើក ចំណែកតំណាងរាស្ត្រគណបក្សសម រង្ស៊ី គិតជាមធ្យមក្នុងម្នាក់ ចុះមូលដ្ឋានបាន៦៤លើក។ ចំពោះតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស ដែលជាមធ្យមចុះមូលដ្ឋានបានចំនួន៤៨០លើក។ តំណាងរាស្ត្រហ៊្វុនស៊ិនប៉ិច ជាមធ្យមតំណាងរាស្ត្រ១រូប ចុះបាន៦៧លើក និងតំណាងរាស្ត្រគណបក្សជាតិនិយមចុះមូលដ្ឋាន ដែលជាមធ្យមតំណាងរាស្ត្រ១រូបរបស់គណបក្សនេះចុះបាន៣៦លើក។

## ២.២. គោលបំណងចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ

ចំពោះក្នុងគោលបំណងចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ ខាងខុមហ្វ្រែល ត្រូវបានកំណត់បែងចែកយកជា ៥ចំណុច ដើម្បីអង្កេតទៅលើការចុះមូលដ្ឋានរបស់តំណាងរាស្ត្រ គឺ១. ចុះសួរសុខទុក្ខចែកអំណោយសម្ភោធសមិទ្ធិផលនានា (សួរសុខទុក្ខ) ២. ការចុះមូលដ្ឋានដើម្បីពង្រឹងបណ្តាញគណបក្សរបស់ខ្លួន (ពង្រឹងគណបក្ស) ៣. ការចុះអមដំណើរជាក្រុម ឬអមដំណើរថ្នាក់ដឹកនាំ(អមដំណើរ) ៤. ការចូលរួមវេទិកា/សិក្ខាសាលាសាធារណៈ (វេទិកា) និង ៥. ចុះជួយអន្តរាគមន៍ និងដោះស្រាយបញ្ហានានា(អន្តរាគមន៍)។

*តួលេខ 29៖ ភាគរយនៃគោលបំណងនីមួយៗរបស់អ្នកតំណាងរាស្ត្រតាមគណបក្សធៀបនឹងគោលបំណងសរុបតាមគណបក្ស*



តាមភាគរយនៃគោលបំណងនីមួយៗរបស់អ្នកតំណាងរាស្ត្រ តាមគណបក្សធៀបនឹងគោលបំណងសរុបតាមគណបក្សខ្លួនឃើញថា ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា គឺផ្តោតខ្លាំងលើគោលបំណងចុះសួរសុខទុក្ខ ចែកអំណោយសម្ពោធសមិទ្ធផលនានា៦៣% នៃចំនួនចុះមូលដ្ឋានសរុបរបស់គណបក្សខ្លួន ក្នុងគោលបំណងលំដាប់ទី២ ដែលគណបក្សនេះផ្តោតទៅលើគោលបំណងចុះពង្រឹងបណ្តាញផ្ទៃក្នុងបក្សរបសខ្លួនបាន ១៨% និងគោលបំណងអមដំណើរថ្នាក់ដឹកនាំ១៧% ចំណែកក្នុងគោលបំណងចូលរួមវេទិកា និងចុះអន្តរាគមន៍បាន១%នៃចំនួនចុះមូលដ្ឋានរបស់បក្សខ្លួនសរុប។

ចំពោះការចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សសម រង្ស៊ី ផ្តោតខ្លាំងក្នុងគោលបំណងចុះពង្រឹងបណ្តាញគណបក្សរបស់ខ្លួន៥០%នៃចំនួនចុះមូលដ្ឋានរបស់គណបក្សខ្លួន ក្នុងគោលបំណងចុះសួរសុខទុក្ខប្រជាពលរដ្ឋបានចំនួន៤២% គោលបំណងចុះអន្តរាគមន៍បានចំនួន៣% គោលបំណងចូលរួមវេទិកា៤% និងអមថ្នាក់ដឹកនាំ១%។

ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រ គណបក្សសិទ្ធិមនុស្ស បានផ្តោតខ្លាំងទៅលើក្នុងគោលបំណងចុះសួរសុខទុក្ខប្រជាពលរដ្ឋ៦០%នៃចំនួនចុះមូលដ្ឋានរបស់គណបក្សខ្លួន គោលបំណងទី២ដែលតំណាងរាស្ត្រគណបក្សនេះផ្តោតនោះ គឺក្នុងគោលបំណងចុះពង្រឹងបណ្តាញផ្ទៃក្នុងបក្សខ្លួនបាន៣៨% ក្នុងគោលបំណងចូលរួមវេទិកាបានចំនួន២%។

តំណាងរាស្ត្រគណបក្សហ៊្វុនស៊ិនប៉ិច ការចុះមូលដ្ឋានផ្តោតទៅលើគោលបំណងចុះពង្រឹងបណ្តាញផ្ទៃក្នុងបក្សខ្លួនបានចំនួន៤៧% គោលបំណងចុះអមដំណើរថ្នាក់ដឹកនាំតំណាងរាស្ត្រគណបក្សនេះ បានផ្តោតលំដាប់ទី២ដែលចុះបាន២៩% គោលបំណងចុះសួរសុខទុក្ខប្រជាពលរដ្ឋបាន១៨% និងគោលបំណងចូលរួមវេទិកាសាធារណៈចុះបានចំនួន៦%នៃចំនួនចុះមូលដ្ឋានរបស់បក្សខ្លួន។ ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សជាតិនិយម ផ្តោតតែ៤គោលបំណងប៉ុណ្ណោះ ក្នុងនោះមានក្នុងគោលបំណងចុះពង្រឹងបណ្តាញផ្ទៃក្នុងបក្សខ្លួន៤៥% និងគោលបំណងចុះសួរសុខទុក្ខប្រជាពលរដ្ឋ៤៥% ក្នុងគោលបំណងចូលរួមវេទិកាសាធារណៈបានចំនួន១៨ នៃចំនួនចុះមូលដ្ឋានសរុប និងក្នុងគោលបំណងចុះអមដំណើរថ្នាក់ដឹកនាំបានចំនួន៨%។

*<u>តារាងទី ៣ ៖ ចំនួនលើកនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រនៃគណបក្សនយោបាយនីមួយៗតាមគោលបំណង</u>*

| គោលបំណងនៃការចុះមូលដ្ឋានទាំង ៨៧២៥លើក របស់តំណាងរាស្ត្រទាំង ១៣៣រូប | គណបក្សនយោបាយ | | | | | សរុបនៃគោលបំណង |
|---|---|---|---|---|---|---|
| | ៩៥រូប | ៣១រូប | ៣រូប | ២រូប | ២រូប | |
| **សួរសុខទុក្ខ ចែកអំណោយ និងការសម្ពោធសមិទ្ធផលនានា** | ៣២១៣ | ៨៤៧ | ៨៥៨ | ២៤ | ២៣ | ៤៩៦៥ (៥៧%) |
| **ការចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្ស** | ៩៣៥ | ១០០៥ | ៥៤៣ | ៦៣ | ៣២ | ២៥៧៨ (៣០%) |
| **ការចុះអមដំណើរជាក្រុម ឬអមដំណើរថ្នាក់ដឹកនាំ** | ៨៣៩ | ៨ | ៦ | ៤០ | ៦ | ៨៩៩ (១០%) |
| **ការចូលរួមក្នុងវេទិកា/សិក្ខាសាលាសាធារណៈ** | ៤៨ | ៧៥ | ៣១ | ៨ | ១១ | ១៧៣ (២%) |

| | | | | | | |
|---|---|---|---|---|---|---|
| **ការអន្តរាគមន៍ និងដោះស្រាយបញ្ហានានា** | ៤៥ | ៦៤ | ២ | ០ | ០ | ១១១ (១%) |
| **សរុបជាភាគរយតាមគណបក្ស** | ៥០៨០ (៥៨%) | ១៩៩៩ (២៣%) | ១៤៤០ (១៦%) | ១៣៥ (២%) | ៧២ (១%) | ៨៧២៥ (១០០%) |

**ការចុះមូលដ្ឋានក្នុងគោលបំណងសួរសុខទុក្ខចែកអំណោយនិងការសម្ពោធសមិទ្ធផលនានាសរុប៤៩៦៥លើក៖** ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រភាគច្រើន ក្នុងគោលបំណងចុះសំណេះសំណាលសួរសុខទុក្ខចែកអំណោយប្រជាពលរដ្ឋរួមទាំងសម្ពោធសមិទ្ធផលនានា ដែលមានសាងសង់រួចមក ដែលមានរហូតមក៤៩៦៥លើកដោយក្នុងនោះតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាចុះក្នុងគោលបំណងនេះបានចំនួន៣២១៣លើក តំណាងរាស្ត្រគណបក្សសម រង្ស៊ី ចុះបានចំនួន៨៤៧លើក តំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សបានចំនួន៨៥៤លើក តំណាងរាស្ត្រគណបក្សជាតិនិយមបានចំនួន២៣លើក និងតំណាងរាស្ត្រគណបក្សហ្វ៊ុនស៊ិនប៉ិចបានចំនួន២៤លើក។

**ករណីខ្លះៗនៃការចុះមូលដ្ឋានរបស់តំណាងរាស្ត្រ ដើម្បីសួរសុខទុក្ខចែកអំណោយ និងសម្ពោធសមិទ្ធផលនានាតាមគណបក្សនីមួយៗ**

**- គណបក្សប្រជាជនកម្ពុជា៖** អ្នកតំណាងរាស្ត្រ ទេស ហ៊ាញ មណ្ឌលបាត់ដំបង បានអញ្ជើញចុះមូលដ្ឋានក្នុងគោលបំណងចុះសួរសុខទុក្ខប្រជាពលរដ្ឋ នៅក្នុងមណ្ឌលរបស់ខ្លួនបានចំនួន២១៥លើកច្រើនជាងគេ ក្នុងគោលបំណងនេះចំណោមគណបក្សរបស់ខ្លួន។ នៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១២ អ្នកតំណាងរាស្ត្រ ទេស ហ៊ាញ អញ្ជើញជួបសំណេះសំណាល សួរសុខទុក្ខក្រុមប្រឹក្សាឃុំ មេភូមិ និងប្រជាពលរដ្ឋចំនួន២៩៨នាក់នៅភូមិអណ្តូងនាង ឃុំតាគ្រាម ស្រុកបាណន់។

**- គណបក្សសមរង្ស៊ី៖** អ្នកតំណាងរាស្ត្រ សុវណ្ណា ពិសាខា មណ្ឌលកំពង់ចាម ចុះមូលដ្ឋានក្នុងគោលបំណងបានចំនួន១៣៨លើកច្រើនជាងគេ ក្នុងចំណោមតំណាងរាស្ត្រនៅក្នុងបក្សរបស់ខ្លួន។ នៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០១២ អ្នកតំណាងរាស្ត្របានអញ្ជើញចុះសួរសុខទុក្ខប្រជាពលរដ្ឋនៅក្នុងស្រុកថ្មគោល ខេត្តបាត់ដំបង ក្នុងនោះដែលមានអ្នកចូលរួម២៨៥នាក់។

**- គណបក្សសិទ្ធិមនុស្ស៖** អ្នកតំណាងរាស្ត្រ គឹម សុខា មណ្ឌលកំពង់ចាម បានចុះធ្វើសកម្មភាពនៅមូលដ្ឋានក្នុងគោលបំណងនេះបានចំនួនច្រើនជាងគេ បានចំនួនដល់៥៥៦លើក។ អ្នកតំណាងរាស្ត្រ គឹម សុខា នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៣ បានអញ្ជើញសំណេះសំណាល សួរសុខទុក្ខជាមួយបងប្អូនប្រជាពលរដ្ឋមកពីភូមិឃុំនានានៅភូមិវត្តថ្មី ឃុំតាម៉ឺន ស្រុកថ្មគោល ដែលមានវត្តមានសរុប៤១៧នាក់។

**- គណបក្សហ្វ៊ុនស៊ិនប៉ិច៖** អ្នកតំណាងរាស្ត្រ ញិក ប៊ុនឆៃ មណ្ឌលបន្ទាយមានជ័យ បានចុះធ្វើសកម្មភាពក្នុងគោលបំណងចុះសួរសុខទុក្ខប្រជាពលរដ្ឋក្នុងមូលដ្ឋានរបស់ខ្លួនបានចំនួន២១លើក។ អ្នកតំណាងរាស្ត្រ ញ៉ឹក ប៊ុនឆៃ នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១០ បានអញ្ជើញចុះសំណេះសំណាលជាមួយប្រជាពលរដ្ឋរស់នៅក្នុងខេត្តមណ្ឌលគិរី រួមទាំងមានការចែកអំណោយដល់ប្រជាពលរដ្ឋចំនួន១៣៥នាក់ ក្នុងម្នាក់ៗទទួលបានថវិកា៥ម៉ឺនរៀល។

**- គណបក្សជាតិនិយម៖** អ្នកតំណាងរាស្ត្រ សៅ រ៉ានី នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១០ បានអញ្ជើញចុះទៅសួរសុខទុក្ខប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ រួមទាំងបានចែកអំណោយដល់អ្នកចូលរួម ក្នុងម្នាក់ៗទទួលបានសារុង១ ថវិកា១០០០០រៀល ព្រមទាំងឧបត្ថម្ភថវិកា១០ម៉ឺនរៀលដល់រដ្ឋាភិបាលនៅឃុំទួលពង្រ រួមទាំងបានចុះទៅឃុំបឹងបេងស្រុកម៉ាឡៃ បានចុះទៅសួរសុខទុក្ខប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ ហើយបានចែកអំណោយដល់អ្នកចូលរួមក្នុងម្នាក់

សារុង១ ថវិកា១ម៉ឺនរៀល ព្រមទាំងឧបត្ថម្ភថវិកា១០ម៉ឺនរៀលដល់រដ្ឋាភិបាលនៅឃុំបឹងបេង។

**ការចុះមូលដ្ឋានដើម្បីពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្សមានចំនួន៧០៨លើកៈ**

ការចុះមូលដ្ឋាន ក្នុងគោលបំណងចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្សច្រើននៅលំដាប់ទី២។ ក្នុងគោលបំណងនេះ តំណាងរាស្ត្រគណបក្សសម រង្ស៊ី ចុះបានច្រើជាងគេ ក្នុងចំណោមគណបក្សទាំង៥ ដែលមានអាសនៈក្នុងរដ្ឋសភា។ តំណាងរាស្ត្រគណបក្សសម រង្ស៊ី ចុះក្នុងគោលបំណងនេះចំនួន១០០៥លើក តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា៩៣៥លើក តំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សចុះបាន៥៤៣លើក តំណាងរាស្ត្រគណបក្សហ្វ៊ុនស៊ិនប៉ិចចុះបាន៦៣លើក និងតំណាងរាស្ត្រគណបក្សជាតិនិយមចុះបាន៣២លើក។

**ករណីខ្លះៗនៃការចុះមូលដ្ឋានក្នុងគោលបំណងពង្រឹងបណ្តាញគណបក្សច្រើនជាងគេធៀបនឹងគណបក្សរបស់ខ្លួន**

- **គណបក្សប្រជាជនកម្ពុជាៈ** អ្នកតំណាងរាស្ត្រ ប៉ាល់ សំអឿន មណ្ឌលបន្ទាយមានជ័យ ក្នុងគោលបំណងនេះអ្នកតំណាងរាស្ត្របានអញ្ជើញធ្វើសកម្មភាពនៅក្នុងមូលដ្ឋានច្រើនជាងគេ ក្នុងចំណោមតំណាងរាស្ត្រក្នុងបក្សរបស់ខ្លួន ។ នៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០១១ អ្នកតំណាងរាស្ត្រប៉ាល់ សំអឿន បានអញ្ជើញជួបសំណេះសំណាលជាមួយមន្ត្រីគណបក្សភូមិមានចំនួន១១០នាក់ ក្នុងសង្កាត់និមិត្ត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ រួមទាំងបានឧបត្ថម្ភថវិកា១លាន៦សែនរៀល។

- **គណបក្សសម រង្ស៊ីៈ** អ្នកតំណាងរាស្ត្រ ពត ពៅ មណ្ឌលកណ្តាល បានចុះក្នុងគោលបំណងចុះពង្រឹងផ្ទៃក្នុងបក្សច្រើនជាងគេ ក្នុងចំណោមតំណាងរាស្ត្រក្នុងបក្សរបស់ខ្លួនបានចំនួន១៧០លើក។ នៅថ្ងៃទី០១ ខែមេសា ឆ្នាំ ២០១១ អ្នកតំណាងរាស្ត្រ ពត ពៅ បានអញ្ជើញចុះជួបសំណេះសំណាលសួរសុខទុក្ខសកម្មជនបក្សខ្លួន និងប្រជាពលរដ្ឋ ព្រមទាំងជួយពិនិត្យ និងបានផ្តល់ជាថ្នាំពេទ្យដល់ប្រជាពលរដ្ឋចំនួន២៧នាក់ស្ថិតនៅក្នុងឃុំប្រាសាទ ស្រុកស្អាង ខេត្តកណ្តាល។

- **គណបក្សសិទ្ធិមនុស្សៈ** អ្នកតំណាងរាស្ត្រ យ៉ែម បុញ្ញឫទ្ធិ មណ្ឌលព្រៃវែង បានចុះមូលដ្ឋាន ក្នុងគោលបំណងនេះបានចំនួន២១៣លើក។ នៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១០ អ្នកតំណាងរាស្ត្រ យ៉ែម បុញ្ញឫទ្ធិ បានអញ្ជើញចូលរួមប្រជុំនៅទីស្នាក់ការគណបក្សខេត្ត ក្នុងគោលបំណងសួរសុខទុក្ខ និងពង្រឹងសកម្មជនរៀបចំផែនការទិសដៅទៅខាងមុខ ដែលមានភ្ញៀវចូលរួមប្រហែលជា២៦នាក់ សកម្មជនបក្សមកគ្រប់ស្រុកទាំង១៣ក្នុងខេត្តព្រៃវែង។

- **គណបក្សហ្វ៊ុនស៊ិនប៉ិចៈ** អ្នកតំណាងរាស្ត្រ ញ៉ិក ប៊ុនឆៃ មណ្ឌលបន្ទាយមានជ័យ នៅថ្ងៃទី០១ ខែឧសភា ឆ្នាំ ២០១១ អ្នកតំណាងរាស្ត្រ ញ៉ិក ប៊ុនឆៃ បានអញ្ជើញចុះមកចូលរួមប្រជុំសំណេះសំណាលជាមួយថ្នាក់ដឹកនាំគណបក្ស សកម្មជនបក្ស និងអ្នកគាំទ្របក្សមានចំនួនប្រមាណ១០០នាក់នៅទីស្នាក់ការគណបក្សខេត្តកំពង់ឆ្នាំង។

- **គណបក្សជាតិនិយមៈ** អ្នកតំណាងរាស្ត្រ សៅ រ៉ានី មណ្ឌលព្រៃវែង នៅថ្ងៃទី០៩ ខែមករា ឆ្នាំ២០១២ អ្នកតំណាងរាស្ត្រ សៅ រ៉ានី បានអញ្ជើញចុះសំណេះសំណាល និងសួរសុខទុក្ខដល់ក្រុមប្រឹក្សាស្រុក ដែលមានភ្ញៀវចូលរួមប្រហែល៥៦នាក់ ស្ថិតនៅស្នាក់ការគណបក្ស ក្នុងឃុំកំពង់លាវ ស្រុកព្រៃវែង ខេត្តព្រៃវែង។

**ការចុះមូលដ្ឋានដើម្បីអមដំណើរជាក្រុម ឬអមដំណើរថ្នាក់ដឹកនាំមានចំនួនសរុប៨៩៩លើកៈ** ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រ នៅក្នុងគោលបំណងអមដំណើរជាក្រុម ឬក៏អមដំណើរថ្នាក់ដឹកនាំតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាបានធ្វើសកម្មភាពច្រើនជាងគេ ក្នុងចំណោមគណបក្សដែលមានអាសនៈនៅក្នុងរដ្ឋសភាចុះបាន៨៣៩លើក តំណាងរាស្ត្រគណបក្សសម រង្ស៊ី ចុះបានចំនួន៨លើក តំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សចុះបានចំនួន៦លើក តំណាងរាស្ត្រគណបក្សហ្វ៊ុនស៊ិនប៉ិចបានចុះមូលដ្ឋានបានចំនួន៤០លើក។

**ករណីខ្លះៗនៃការចុះមូលដ្ឋានដើម្បីក្នុងគោលបំណងអមដំណើរជាក្រុម ឬអមដំណើរថ្នាក់ដឹកនាំរបស់តំណាងរាស្ត្រច្រើនជាងគេធៀបនឹងគណបក្សរបស់ខ្លួន**

- **គណបក្សប្រជាជនកម្ពុជា៖** អ្នកតំណាងរាស្ត្រ ជួញ សុផៃ មណ្ឌលបាត់ដំបង បានអញ្ជើញចុះមូលដ្ឋាន ក្នុងគោលបំណងអមដំណើរថ្នាក់ដឹកនាំបានចំនួន៤៧លើកច្រើនជាងគេ ក្នុងចំណោមតំណាងរាស្ត្រក្នុងបក្សរបស់ខ្លួន។ នៅថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១២ អ្នកតំណាងរាស្ត្រ ជួញ សុផៃ បានអញ្ជើញចុះអមដំណើរឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អញ្ជើញជាអធិបតីភាពក្នុងពិធីជួបសំណេះសំណាលសួរសុខទុក្ខ និងចែកប័ណ្ណកម្មសិទ្ធដីធ្លីជូនប្រជាពលរដ្ឋចំនួន៨៣៤គ្រួសារ ស្មើប័ណ្ណកម្មសិទ្ធចំនួន៨៤០ប័ណ្ណ នៅក្នុងភូមិយុត្តិធម៌ ភូមិបឹងក្រឡ ភូមិបឹងប្រាំ ឃុំបឹងប្រាំ អង្គពិធីប្រារព្ធនៅវត្តអំពិលប្រាំដើម ឃុំអំពិលប្រាំដើម ស្រុកបវេល ខេត្តបាត់ដំបង។

- **គណបក្សសម រង្ស៊ី៖** អ្នកតំណាងរាស្ត្រ ម៉ែន សុថាវរិន្ទ្រ មណ្ឌលកំពង់ធំ នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៩ អ្នកតំណាងរាស្ត្រ ម៉ែន សុថាវរិន្ទ្រ បានអញ្ជើញចុះអមដំណើរ ឯកឧត្តម សម រង្ស៊ី ប្រធានគណបក្សចុះសួរសុខទុក្ខសកម្មជនគណបក្សនៅពន្ធនាគារ គឺលោកទួត សារ៉ន ជំទប់ទី១ ដែលជាប់ចោទពីបទឃុំឃាំងមនុស្សខុសច្បាប់ ស្ថិតនៅក្នុងឃុំកំពង់ធំ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ។

- **គណបក្សសិទ្ធិមនុស្ស៖** អ្នកតំណាងរាស្ត្រ យ៉ែម បុញ្ញឫទ្ធិ មណ្ឌលព្រៃវែង នៅថ្ងៃទី០៥ខែតុលាឆ្នាំ២០០៩ អ្នកតំណាងរាស្ត្រ យ៉ែម បុញ្ញឫទ្ធិ អញ្ជើញចុះអមដំណើរឯកឧត្តម កឹម សុខា អញ្ជើញជាអធិបតីក្នុងពិធីប្រជុំមួយក្នុងគោលបំណងសំណេះសំណាល ព្រមទាំងសួរសុខទុក្ខប្រជាពលរដ្ឋ ដោយមានចូលរួមមានប្រហែល២០០នាក់ ស្ថិតនៅក្នុងភូមិបឹងឡៃង ឃុំជ្រៃឃ្មុំ ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង។

- **គណបក្សហ៊្វុនស៊ិនប៉ិច៖** អ្នកតំណាងរាស្ត្រ ញិក ប៊ុនឆៃ មណ្ឌលបន្ទាយមានជ័យ នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១២ អ្នកតំណាងរាស្ត្រ ញិក ប៊ុនឆៃ បានអញ្ជើញអមដំណើរសម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីបានអញ្ជើញចូលរួមជាអធិបតីភាពដ៏ខ្ពង់ខ្ពស់នៅក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ផ្លូវជាតិលេខ៨ ផ្លូវជាតិលេខ៨,១ និងផ្លូវជាតិលេខ៨,២ ដែលមានប្រវែងសរុប១៣៣,២០គីឡូម៉ែត្រ ហើយរួមទាំងមានការចែកអំណោយដល់សិស្សានុសិស្ស ក្រុមកាកបាទក្រហម យាយជី តាជីដែលបានចូលរួមក្នុងពិធីនោះផងដែរ ដែលធ្វើឡើងនៅក្នុងឃុំក្រពៅ ស្រុកកំចាយមារ ខេត្តព្រៃវែង។

- **គណបក្សជាតិនិយម៖** អ្នកតំណាងរាស្ត្រ សៅ រ៉ានី មណ្ឌលព្រៃវែង នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១២ អ្នកតំណាងរាស្ត្រ សៅ រ៉ានី បានអញ្ជើញអមដំណើរសម្តេច ហេង សំរិន ប្រធានរដ្ឋសភាអញ្ជើញជាអធិបតីភាព ក្នុងការទទួលគ្រឿងចក្រ និងសម្ភារៈ បរិក្ខារកសិកម្មជាជំនួយរបស់ខេត្តស៊ីឈួន សាធារណរដ្ឋប្រជាមានិតចិន ស្ថិតនៅឃុំកក់ ស្រុកពញាក្រែក ខេត្តកំពង់ចាម។

**ការចុះមូលដ្ឋានដើម្បីចូលរួមវេទិកា/សិក្ខាសាលាសាធារណៈមានចំនួន១៧៣លើក៖** ក្នុងចុះមូលដ្ឋានរបស់តំណាងរាស្ត្រ តាមទិន្នន័យរបស់ខុមហ្វ្រែលបានបង្ហាញថា ចំនួនតំណាងរាស្ត្របានចុះមូលដ្ឋានដើម្បីចូលរួមវេទិកាជាសាធារណៈ ដែលអាចផ្តល់ឱកាសដល់ម្ចាស់ឆ្នោតជួបជាមួយតំណាងរាស្ត្ររបស់ខ្លួនចុះបានចំនួន១៧៣លើក ក្នុងនោះតំណាងរាស្ត្រនៅក្នុងគណបក្សប្រជាជនកម្ពុជា ចុះបាន៤៨លើក តំណាងរាស្ត្រគណបក្សសម រង្ស៊ី ចុះបានចំនួន៧២លើក តំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស ចុះក្នុងគោលបំណងនេះបានចំនួន៣១លើក តំណាងរាស្ត្រគណបក្ស

ហ៊្វុនស៊ិនប៉ិច ចុះបានចំនួន៨លើក និងតំណាងរាស្ត្រគណបក្សជាតិនិយមចុះមូលដ្ឋាន ក្នុងគោលបំណងនេះចំនួន ១១លើក។

**ករណីខ្លះៗនៃការចុះមូលដ្ឋានក្នុងគោលបំណងចូលរួមវេទិកាជាសាធារណៈរបស់តំណាងរាស្ត្រចុះច្រើនជាងគេធៀបនឹងគណបក្សរបស់ខ្លួន**

- **គណបក្សប្រជាជនកម្ពុជា៖** អ្នកតំណាងរាស្ត្រ ត្រឹង ថារី មណ្ឌលក្រចេះ បានអញ្ជើញចុះមូលដ្ឋាន ក្នុងគោលបំណងនេះបានច្រើនជាងគេ ក្នុងចំណោមគណបក្សរបស់ខ្លួន។ កាលពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១១ អ្នកតំណាងរាស្ត្រ ត្រឹង ថារី បានអញ្ជើញចុះមណ្ឌលរបស់ខ្លួនក្នុងឃុំស្វាយជ្រះ ស្រុកស្នួល ខេត្តក្រចេះ ដើម្បីចូលរួមប្រជុំវេទិកាសាធារណៈដែលរៀបចំឡើងដោយអង្គការ អ៊ិន ឌី អាយ ដែលមានប្រជាពលរដ្ឋចំនួន៧៧៥នាក់។

- **គណបក្សសមរង្ស៊ី៖** អ្នកតំណាងរាស្ត្រ ឡុង រី មណ្ឌលក្រចេះ បានចុះមូលដ្ឋាននាំមុខគេ ក្នុងចំណោមតំណាងរាស្ត្រគណបក្សរបស់ខ្លួនចុះបានចំនួន១២លើក។ ពីថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១១ អ្នកតំណាងរាស្ត្រ ឡុង រី បានអញ្ជើញចុះមូលដ្ឋាននៅក្នុងភូមិជួរក្រូច ឃុំថ្មអណ្តើក ស្រុកចិត្របុរី ដើម្បីចូលរួមនៅក្នុងកម្មវិធីវេទិកាសាធារណៈដែលរៀបចំឡើងដោយអង្គការ អ៊ិន ឌី អាយ មានប្រជាពលរដ្ឋប្រមាណ៣៨០នាក់។

- **គណបក្សសិទ្ធិមនុស្ស៖** អ្នកតំណាងរាស្ត្រ យ៉ែម បុញ្ញឫទ្ធិ មណ្ឌលព្រៃវែង បានចុះច្រើនជាងគេ ក្នុងគោលបំណងនេះចំណោមគណបក្សរបស់ខ្លួន។ កាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១២ អ្នកតំណាងរាស្ត្រ យ៉ែម បុញ្ញឫទ្ធិ បានអញ្ជើញចូលរួបវេទិកាសាធារណៈដែលរៀបចំដោយ អង្គការ អ៊ិន ឌី អាយ នៅក្នុងឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ដែលមានភ្ញៀវជាច្រើនចូលរួមផងដែរ។

- **គណបក្សហ៊្វុនស៊ិនប៉ិច៖** អ្នកតំណាងរាស្ត្រ គុជ ម៉ូលី មណ្ឌលកំពង់ធំ នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១០ អញ្ជើញចូលរួមជាវាគ្មិនវេទិកាសិទ្ធិមនុស្ស រៀបចំដោយអង្គការសិទ្ធិមនុស្ស ដែលទាក់ទងអាជ្ញាធរអប្សរា និងប្រជាពលរដ្ឋនៅវត្តអន្លង់ក្រមោល ឃុំលាងដៃ ស្រុកអង្គរធំ ខេត្តសៀមរាប។

- **គណបក្សជាតិនិយម៖** អ្នកតំណាងរាស្ត្រ សៅ រ៉ានី មណ្ឌលព្រៃវែងបានអញ្ជើញចុះមូលដ្ឋាន ក្នុងគោលបំណងនេះចំនួន១១លើក។ កាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១១ អ្នកតំណាងរាស្ត្រ សៅ រ៉ានី បានអញ្ជើញចូលរួមវេទិកាសាធារណៈ ដែលរៀបចំឡើងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ស្តីអំពីដំណោះស្រាយប្រជាពលរដ្ឋ និងអាជ្ញាធរអប្សរា នៅឃុំខ្នារសណ្តាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប។

**ការចុះមូលដ្ឋានដើម្បីអន្តរាគមន៍ និងដោះស្រាយបញ្ហានានាមានចំនួន១១១លើក៖** ក្នុងការចុះមូលដ្ឋានរបស់តំណាងរាស្ត្រទៅលើគោលបំណងចុះធ្វើអន្តរាគមន៍ និងដោះស្រាយបញ្ហានានាបានចំនួន១១១លើក ដោយក្នុងគោលបំណងតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា ចុះបានចំនួន៤៥លើក តំណាងរាស្ត្រសម រង្ស៊ី ចុះបានចំនួន៦២លើក និងតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស ចុះក្នុងគោលបំណងនេះបានចំនួន២លើក។ ចំណែកតំណាងរាស្ត្រគណបក្សហ៊្វុនស៊ិនប៉ិច និងតំណាងរាស្ត្រគណបក្សជាតិនិយម ខាងខុមប្រែ្វលមិនបានទទួលព័ត៌មានណាមួយពាក់ព័ន្ធនឹងអ្នកតំណាងរាស្ត្រមូលដ្ឋានក្នុងគោលបំណងនេះទេ។

**ករណីខ្លះៗនៃការចុះមូលដ្ឋានក្នុងគោលបំណងដោះស្រាយបញ្ហានានារបស់តំណាងរាស្ត្រចុះច្រើនជាងគេ ធៀបនឹងគណបក្សរបស់ខ្លួន**

- **គណបក្សប្រជាជនកម្ពុជា៖** អ្នកតំណាងរាស្ត្រ សួស កាណាន មណ្ឌលព្រះសីហនុ នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ

២០១២ អ្នកតំណាងរាស្ត្របានអញ្ជើញជួយធ្វើអន្តរាគមន៍ដោយផ្ទាល់ទៅមន្ទីរសាធារណការខេត្ត និងអាជ្ញាធរក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ដើម្បីជួយពិនិត្យដោះស្រាយ ចំពោះសំណូមពររបស់ប្រជារាស្ត្រដែលរស់នៅតាមដងផ្លូវលេខ២០៧ ស្ថិតក្នុងសង្កាត់លេខ២ ក្រុងព្រះសីហនុ ទាំងពីរចំណុចរួមមាន៖ សុំបើកផ្លូវនេះទទឹង ០៨ម៉ែត្រ និងរបងផ្ទះដែលធ្វើចូលមកលើផ្លូវ សុំឱ្យរុះរើទាំងអស់គ្នា។

- **គណបក្សសមរង្ស៊ី៖** អ្នកតំណាងរាស្ត្រ ហ៊ូ វ៉ាន់ មណ្ឌលភ្នំពេញ បានចុះមូលដ្ឋានក្នុងគោលបំណងជួយអន្តរាគមន៍ ដោះស្រាយបញ្ហានានាជូនប្រជាពលរដ្ឋបានចំនួន១៣លើក ច្រើនជាងគេ ក្នុងចំណោមតំណាងរាស្ត្រនៅក្នុងគណបក្សរបស់ខ្លួន។ អ្នកតំណាងរាស្ត្រនៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១១ បានអញ្ជើញចុះជួយធ្វើអន្តរាគមន៍ដល់ប្រជាពលរដ្ឋដែលរស់នៅផ្សារដើមថ្កូវ ដែលត្រូវបានអាជ្ញាធរធ្វើការឈូសឆាយ ដែលបណ្តាលឱ្យប៉ះពាល់ដីធ្លី និងផលដំណាំរបស់ពួកគាត់ស្ថិតនៅក្នុងខណ្ឌចំការមន រាជធានីភ្នំពេញ។

- **គណបក្សសិទ្ធិមនុស្ស៖** អ្នកតំណាងរាស្ត្រ អ៊ូ ច័ន្ទឫទ្ធិ មណ្ឌលកណ្តាល នៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០១០ អ្នកតំណាងរាស្ត្រ អ៊ូ ច័ន្ទឫទ្ធិ បានអញ្ជើញចុះធ្វើអន្តរាគមន៍លើការដាក់កុងត្រូលយកលុយក្នុងស្រុកស្អាង ខេត្តកណ្តាល។

*តួលេខ៣០៖កំណើនជាភាគរយចំនួនចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រតាមគោលបំណងធៀបនឹងនីតិកាលទី៣កក្កដា ២០០៤ ដល់ កញ្ញា២០០៨*




កំណើន ជាភាគរយចំនួនចុះមូលដ្ឋានរបស់តំណាងរាស្ត្រ តាមគោលបំណង ធៀបនឹងនីតិកាលទី៣ ខុមប្រែ្វលឃើញថា មានគោលបំណងចំនួន៤ មានការថយចុះ ជាងនីតិកាលទី៣។ ការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ ក្នុងគោលបំណងចុះសួរសុខទុក្ខប្រជាពលរដ្ឋមានការថយចុះចំនួន១% ដោយក្នុងនីតិកាលទី៤នេះ អ្នកតំណាងរាស្ត្រចុះបានចំនួន៤៩៦៥លើក ធៀបនឹងនីតិកាលមុន៤៩៧៤លើក។ ក្នុងគោលបំណងអមដំណើរថ្នាក់ដឹកនាំ មានការថយចុះចំនួន២៨% នៅក្នុងនីតិកាលមុន ដោយនីតិកាលនេះចុះបាន៨៩៩លើកធៀបនឹងនីតិកាលមុនចុះបាន១២៧២លើក។ ចំពោះគោលបំណងចូលរួមវេទិកាសាធារណៈ ចុះបានចំនួន១៧៣លើក មានការថយចុះជាងនីតិកាលមុន៧២% ដោយចុះបានចំនួន៦២៦លើក។ ចំណែកការចុះមូលដ្ឋានក្នុងគោលបំណងអន្តរាគមន៍ដោះស្រាយបញ្ហានានាវិញ ចុះបានចំនួន១១១លើក មានការថយចុះដល់ទៅ៨០% បើធៀបនឹងនីតិកាលមុនចុះបាន៥៦៦លើក។ ដោយឡែក ក្នុងគោលបំណងចុះពង្រឹងបណ្តាញផ្ទៃក្នុងបក្ស អ្នកតំណាងរាស្ត្រចុះបានចំនួន២៥៧៨លើក មានការកើនឡើងជាងនីតិកាលមុនចំនួន១៨% ដោយក្នុងនីតិកាលមុនចុះបានចំនួន២១៨១លើក។

*តារាងទី៤៖ រាយនាមអ្នកតំណាងរាស្ត្រសកម្មជាងគេ១០រូបដែលបានចុះមូលដ្ឋានច្រើនជាងគេ (រៀបតាមលំដាប់ពីច្រើនទៅតិចចាប់ពីថ្ងៃទី*

*កញ្ញា ២០០៨ ដល់ថ្ងៃទីមិថុនា២០១៣)*

| លរ | ឈ្មោះ តំណាងរាស្ត្រ | គណបក្ស | គោលបំណង | | | | | សរុប |
|---|---|---|---|---|---|---|---|---|
| | | | អន្តរាគមន៍ | សួរសុខទុក្ខ | ពង្រឹងគណបក្ស | វេទិកា | អមដំណើរ | |
| ១ | ឯ.ឧ គឹម សុខា | | ០ | ៥៥៦ | ២០២ | ២ | ០ | **៧៦០** |
| ២ | ឯ.ឧ យ៉ែម បុញ្ញឫទ្ធិ | | ០ | ១៤៦ | ២១៣ | ១៧ | ៤ | **៣៨០** |
| ៣ | ឯ.ឧ អ៊ូ ច័ន្ទឫទ្ធិ | | ២ | ១៥៦ | ១២៨ | ១២ | ២ | **៣០០** |
| ៤ | ឯ.ឧ ទេស ហ៊ាញ | | ០ | ២១៥ | ១២ | ៣ | ៤១ | **២៧១** |
| ៥ | ល.ជ ជួញ សុផៃ | | ០ | ១៩៩ | ៥ | ២ | ៤៧ | **២៥៣** |
| ៦ | ឯ.ឧ ស ខេង | | ០ | ១៧៥ | ១៨ | ០ | ៣៦ | **២២៩** |
| ៧ | ឯ.ឧ កាទើ តូយ៉េប | | ២ | ១៧១ | ៣៦ | ២ | ៨ | **២១៩** |
| ៨ | ល.ជ លី គឹមលៀង | | ០ | ១៤៨ | ១៣ | ០ | ៤៥ | **២០៦** |
| ៩ | ឯ.ឧ ចាន់ ចេង | | ៦ | ២២ | ១៥៧ | ៣ | ០ | **១៨៨** |
| ១០ | លៈជ ពត ពៅ | | ៥ | ១៩ | ១៦០ | ០ | ០ | **១៨៤** |

ក្នុងនីតិកាលទី៤នេះ តំណាងរាស្ត្រ១០រូប ដែលចុះមូលដ្ឋានបានច្រើនជាងគេ មានមកពីតំណាងរាស្ត្រចំនួន៣គណបក្ស ដែលមានអាសនៈនៅក្នុងរដ្ឋសភា។ ក្នុងចំណោមតំណាងរាស្ត្រ១០រូប ដែលបានចុះមូលដ្ឋានច្រើនជាងគេនោះ មានអ្នកតំណាងរាស្ត្រមកពីគណបក្សប្រជាជនកម្ពុជាចុះច្រើនជាងគេ។ តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាចំនួន៥រូប តំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សចំនួន៣រូប តំណាងរាស្ត្រគណបក្សសមរង្ស៊ីចំនួន២រូប។

បើមើលពីចំនួនការចុះមូលដ្ឋានរបស់តំណាងរាស្ត្រឃើញថា ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សបានចុះច្រើនជាងគេ ក្នុងតំណាងរាស្ត្រ១០រូប ដែលចុះបានច្រើនជាងគេក្នុងចំណោមតំណាងរាស្ត្រដែលបានចុះនៅក្នុងនីតិកាលទី៤។

តំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សចំនួន៣រូប បានចុះមូលដ្ឋានមានអ្នកតំណាងរាស្ត្រ គឹម សុខា ចុះបាន៧៦០លើក ចុះច្រើនជាងគេក្នុងចំណោមអ្នកតំណាងរាស្ត្រទាំង១០រូប ។ អ្នកតំណាងរាស្ត្រយ៉ែម បុញ្ញឫទ្ធិ ចុះបាន៣៨០លើក និងអ្នកតំណាងរាស្ត្រ អ៊ូ ច័ន្ទឫទ្ធិ ចុះបាន៣០០លើក។

ចំណែកអ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា៥រូប បានចុះមូលដ្ឋាន មានអ្នកតំណាងរាស្ត្រ ទេស ហ៊ាញ ចុះមូលដ្ឋានបាន២៧១លើក អ្នកតំណាងរាស្ត្រ ជួញ សុផៃ ចុះមូលដ្ឋានបាន២៥៣លើក អ្នកតំណាងរាស្ត្រ ស ខេង ចុះមូលដ្ឋានបានចំនួន២២៩លើក អ្នកតំណាងរាស្ត្រ កាទើ តូយ៉េប ចុះមូលដ្ឋានបានចំនួន២១៩លើក និងអ្នកតំណាងរាស្ត្រ លី គឹមលៀង ចុះមូលដ្ឋានបានចំនួន២០៦លើក។

ចំពោះការអ្នកតំណាងរាស្ត្រគណបក្សសម រង្ស៊ី ចុះបាន២រូប មានអ្នកតំណាងរាស្ត្រ ចាន់ ចេង ចុះបានចំនួន១៨៨លើក និងអ្នកតំណាងរាស្ត្រ ពត ពៅ ចុះមូលដ្ឋានបានចំនួន១៨៤លើក។

## ២.៣. គោលបំណងចុះមូលដ្ឋានរបស់តំណាងរាស្ត្រតាមគណបក្សនយោបាយនីមួយៗ

ក្នុងនីតិកាលទី៤ ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រ សុទ្ធតែផ្តោតទៅលើគោលបំណងនីមួយៗតាមគណបក្សរបស់ខ្លួន។ តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា ក្នុងនីតិកាលទី៤នេះបានចុះមូលដ្ឋាន ផ្តោតទៅលើគោលបំណងការចុះសួរសុខទុក្ខចែកអំណោយ រួមទាំងសម្ពោធសមិទ្ធផលនានាបានចំនួន៣២១៣លើកនៃចំនួនចុះមូលដ្ឋានរបស់គណបក្សខ្លួនសរុប។ តំណាងរាស្ត្រគណបក្សសម រង្ស៊ី ក្នុងនីតិកាលទី៤នេះ គឺចុះផ្តោតទៅលើគោលបំណងការចុះពង្រឹងបណ្តាញផ្ទៃក្នុងគណបក្សខ្លួន ដែលក្នុងគោលបំណងនេះចុះបានចំនួន១០០៥លើកនៃចំនួនការចុះមូលដ្ឋានរបស់បក្សខ្លួន។ តំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស បានចុះមូលដ្ឋានក្នុងគោលបំណងផ្តោតទៅលើការចុះសំណេះសំណាល សួរសុខទុក្ខប្រជាពលរដ្ឋបានចំនួន៨៥៨លើកនៃចំនួនចុះមូលដ្ឋានរបស់បក្សខ្លួនសរុប។

ចំណែកការចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សហ្វ៊ុនស៊ិនប៉ិច និងតំណាងរាស្ត្រគណបក្សជាតិនិយម គឺផ្តោតដូចនឹងគណបក្សសម រង្ស៊ី ផងដែរ ផ្តោតទៅលើការចុះពង្រឹងបណ្តាញផ្ទៃក្នុងរបស់បក្សខ្លួនតំណាងរាស្ត្រគណបក្សហ្វ៊ុនស៊ិនប៉ិច ចុះបានចំនួន៦៣លើក និងតំណាងរាស្ត្រគណបក្សជាតិនិយមចុះបានចំនួន៣២លើកនៃចំនួនការចុះមូលដ្ឋានរបស់បក្សខ្លួន។

*តួលេខ 31៖ចំនួនដងនិងភាគរយចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាតាមគោលបំណងនីមួយៗ*




ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រ គណបក្ស ប្រជាជនកម្ពុជា មានការកើនឡើងជាង ឆ្នាំសង្កេតមុន។ តំណាងរាស្ត្រ គណបក្ស ប្រជាជនកម្ពុជា គឺ ផ្តោតខ្លាំងទៅលើការចុះសំណេះ សំណាលសួរសុខទុក្ខចែកអំណោយប្រជាពលរដ្ឋ និងសម្ពោធសមិទ្ធិផលនានា បាន៣២១៣លើក ស្មើនឹង៦២%នៃចំនួនចុះមូលដ្ឋានសរុបរបស់គណបក្សខ្លួន។ ការចុះពង្រឹងផ្ទៃក្នុង និងបណ្តាញបក្សរបស់គណបក្សប្រជាជនកម្ពុជាបាន៩៣៥លើកស្មើនឹង១៨%។ គោលបំណងលំដាប់ទី៣របស់គណបក្សនេះ គឺការចុះអមដំណើរថ្នាក់នាំបាន ៨៣៩លើកស្មើនឹង១៧%។ ចំណែកការចុះអន្តរាគមន៍បាន៤៥លើក ស្មើនឹង១% និងចូលរួមវេទិកា និងសិក្ខាសាលាវិញ ចុះបាន៤៨លើកស្មើនឹង១%។




*តួលេខ 32៖ ចំនួនដងនិងភាគរយចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សសមរង្ស៊ីតាមគោលបំណងនីមួយៗ*

ចំនួនដង និងភាគរយការចុះមូលដ្ឋាន របស់

តំណាងរាស្ត្រ គណបក្សសម រង្ស៊ី ទៅតាមគោលបំណងនីមួយឃើញថា តំណាងរាស្ត្រគណបក្សសម រង្ស៊ី បានចុះមូលដ្ឋានផ្តោតលើគោលបំណងចុះពង្រឹងបណ្តាញផ្ទៃក្នុងបក្សខ្លួនបានចំនួន១០០៥លើក ស្មើនឹង៥០%នៃចំនួនចុះមូលដ្ឋានរបស់បក្សខ្លួន សរុប។ ចំពោះក្នុងគោលបំណងលំដាប់ទី២ តំណាងរាស្ត្រគណបក្សសម រង្ស៊ី បានចុះផ្តោតទៅលើគោលបំណងចុះសួរសុខទុក្ខប្រជាពលរដ្ឋបានចំនួន៨៤៧លើក ស្មើនឹង៤២%នៃចំនួនចុះមូលដ្ឋានរបស់បក្សខ្លួនសរុប។ ក្នុងគោលបំណងចុះអមដំណើរថ្នាក់ដឹកនាំ គោលបំណងវេទិកា និងគោលបំណងអន្តរាគមន៍ តំណាងរាស្ត្រគណបក្សសម រង្ស៊ីបានចុះធ្វើសកម្មភាពតិចតួចបំផុត ដោយក្នុងគោលបំណងអមដំណើរថ្នាក់ដឹកនាំចុះបានចំនួន៨លើក ស្មើនឹងតែ១% គោលបំណងចូលរួមវេទិកាសាធារណៈចុះបានចំនួន៧៥លើក ស្មើនឹង៤% និងគោលបំណងអន្តរាគមន៍ចុះបានចំនួន៦៤លើក ស្មើនឹង៣%នៃចំនួនចុះមូលដ្ឋានរបស់បក្សខ្លួនសរុប។

*<u>តួលេខ 33៖ ចំនួនដង និងភាគរយចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សតាមគោលបំណងនីមួយៗ</u>*




ការចុះមូលដ្ឋាន របស់តំណាងរាស្ត្រ គណបក្សសិទ្ធិមនុស្ស ក្នុងនីតិកាលទី៤នេះ គឺផ្តោតទៅលើតែគោលបំណងប៉ុណ្ណោះគោលបំណង ចុះសួរសុខទុក្ខប្រជាពលរដ្ឋ និង ចុះពង្រឹងបណ្តាញផ្ទៃក្នុងបក្ស។ តំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស បានចុះក្នុងគោលបំណងសួរសុខទុក្ខប្រជាពលរដ្ឋបានចំនួន៨៥៨លើក ស្មើនឹង៦០% នៃចំនួនចុះមូលដ្ឋានរបស់បក្សខ្លួនសរុប។ ក្នុងគោលបំណងចុះពង្រឹងបណ្តាញផ្ទៃក្នុងបក្ស ចុះបានចំនួន៥៤៣លើក ស្មើនឹង៣៨% ចំពោះក្នុងគោលបំណងចូលរួមវេទិកាសាធារណៈ តំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សចុះបានចំនួន៣១លើក ស្មើនឹង២% ចំណែកក្នុងគោលបំណងអមដំណើរថ្នាក់ដឹកនាំ និងគោលបំណងអន្តរាគមន៍ ត្រូវបានតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សចុះបានតិចតួចណាស់ ស្ទើរតែមិនបានចុះក្នុងគោលបំណងអមដំណើរថ្នាក់ដឹកនាំ ចុះបានចំនួន៦លើកមិនស្មើនឹង១%ផងនោះ និងគោលបំណងជួយអន្តរាគមន៍ និងដោះស្រាយបញ្ហានានា តំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សចុះបានចំនួន២លើក។




*<u>តួលេខ34៖ ចំនួនដង និងភាគរយចុះមូលដ្ឋានរបស់ តំណាងរាស្ត្រ គណបក្ស ហ៊្វុនស៊ិនប៉ិច តាមគោលបំណងនីមួយៗ</u>*

តំណាងរាស្ត្រគណបក្សហ៊្វុនស៊ិនប៉ិច ចុះមូលដ្ឋានផ្តោតទៅលើកការពង្រឹងបណ្តាញផ្ទៃក្នុងបក្សរបស់ខ្លួន។ ក្នុងគោលបំណងពង្រឹងបក្សចុះបាន៦៣លើក ស្មើនឹង៤៧%នៃចំនួនចុះមូលដ្ឋានរបស់បក្សខ្លួន។ ចំពោះគោលបំណងទី២របស់គណបក្សនេះ ផ្តោតទៅលើការចុះអមដំណើរថ្នាក់ដឹកនាំបានចំនួន៤០លើក ស្មើនឹង៤៧%នៃចំនួនចុះមូលដ្ឋានសរុបរបស់គណបក្សខ្លួន។ ចំណែកការចុះសួរសុខទុក្ខប្រជាពលរដ្ឋ ស្ថិតនៅក្នុងគោលបំណងទី៣របស់គណបក្សនេះ តំណាងរាស្ត្រចុះបាន២៤លើក ស្មើនឹង២៩%។ ការចូលរួមវេទិកា និងសិក្ខាសាលាសាធារណៈរបស់គណបក្សនេះបាន៨លើក ស្មើនឹង៦%នៃការចុះមូលដ្ឋានរបស់គណបក្សខ្លួន។

*តួលេខ 35៖ ចំនួនដង និងភាគរយចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សជាតិនិយមតាមគោលបំណងនីមួយៗ*

ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សនេះ គឺបានផ្តោតទៅលើការការចុះពង្រឹងបណ្តាញផ្ទៃក្នុងបក្សខ្លួនច្រើនជាងគេ។ ក្នុងគោលបំណងចុះពង្រឹងបណ្តាញផ្ទៃក្នុងបក្សរបស់ខ្លួននេះ ចុះបាន៣២លើក ស្មើនឹង៤៥%នៃចំនួនចុះ




មូលដ្ឋានសរុប របស់គណបក្សខ្លួន។ ចុះមូលដ្ឋាន គោលបំណងចុះសួរសុខទុក្ខ ប្រជាពលរដ្ឋ បាន២៣លើក ស្មើនឹង៣២% និងចុះចូលរួម វេទិកាសាធារណៈ បានចំនួន១១លើក ស្មើនឹង១៥%នៃចំនួនចុះមូលដ្ឋានសរុបគណបក្សខ្លួន។ ចំណែកក្នុងគោលបំណងអមដំណើរថ្នាក់ដឹកនាំ ចុះបាន៦លើក ស្មើនឹង៨%នៃចំនួនចុះមូលដ្ឋានសរុបរបស់គណបក្សខ្លួន។

## ២.៤. មណ្ឌលរាជធានី ខេត្តនានាដែលអ្នកតំណាងរាស្ត្របានចុះ

នៅក្នុងនីតិកាលទី៤នេះ ការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ ខុមហ្វ្រែលបានសង្កេតឃើញថា ការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ គឺសុទ្ធតែបានចុះមូលដ្ឋានក្នុងមណ្ឌលរបស់ខ្លួន និងក្រៅមណ្ឌលរបស់ខ្លួន។ នីតិកាលអាណត្តិទី៤នេះ អ្នកតំណាងរាស្ត្រភាគច្រើនចុះមូលដ្ឋាននៅក្នុងមណ្ឌលរបស់ខ្លួន ច្រើនជាងការចុះមូលដ្ឋាននៅក្រៅមណ្ឌលរបស់ខ្លួន។

នីតិកាលទី៤នេះ អ្នកតំណាងរាស្ត្រចុះមូលដ្ឋានសរុប៨៧២៥លើក ក្នុងនោះអ្នកតំណាងរាស្ត្របានចុះមូលដ្ឋាននៅក្នុងមណ្ឌលរបស់ខ្លួនបានចំនួន៦០១៤លើក។ ចំណែកការចុះមូលដ្ឋានរបស់តំណាងរាស្ត្រនៅក្រៅមណ្ឌលរបស់ខ្លួនមានចំនួន២៧១១លើក។

*តួលេខ 36៖ ភាគរយចុះមូលដ្ឋានក្នុង និងក្រៅមណ្ឌលធៀបនឹងចំនួនចុះមូលដ្ឋានសរុបតាមគណបក្ស*

បើពិនិត្យមើលពី ភាគរយនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រនៅក្នុងមណ្ឌលរបស់ខ្លួននិងក្រៅមណ្ឌល ធៀបនឹងចំនួនការចុះមូលដ្ឋានសរុបតាមគណបក្ស ខុមហ្វ្រែលឃើញថា ការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា និង អ្នកតំណាងរាស្ត្រគណបក្សសម រង្ស៊ី ភាគច្រើន គឺចុះមូលដ្ឋាននៅក្នុងមណ្ឌល របស់ខ្លួនច្រើនជាងការចុះមូលដ្ឋាន នៅក្រៅមណ្ឌល របស់ខ្លួន។ ចំពោះ តំណាងរាស្ត្រគណបក្ស សិទ្ធិមនុស្ស តំណាងរាស្ត្រ គណបក្សជាតិនិយម និង តំណាងរាស្ត្រគណបក្សហ្វ៊ុនស៊ិនប៉ិច គឺភាគច្រើនចុះមូលដ្ឋាននៅក្រៅមណ្ឌលរបស់ខ្លួន ច្រើនជាងនៅក្នុងមណ្ឌលរបស់ខ្លួន។ តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា ចុះមូលដ្ឋាននៅក្នុងមណ្ឌលរបស់ខ្លួនបាន៨២% និងចុះមូលដ្ឋាននៅក្រៅមណ្ឌលរបស់ខ្លួនបានតែ១៨% នៃចំនួនការចុះមូលដ្ឋានសរុបរបស់គណបក្សខ្លួន។ ចំណែកតំណាងរាស្ត្រគណបក្សសម រង្ស៊ី ចុះមូលដ្ឋាននៅក្នុងមណ្ឌលរបស់ខ្លួន៦៥% និងបានចុះមូលដ្ឋាននៅក្រៅមណ្ឌលរបស់ខ្លួន៣៥%។ ចំពោះតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស បានចុះមូលដ្ឋាននៅក្រៅមណ្ឌល៦៧% និងចុះក្នុងមណ្ឌល៣៣%នៃចំនួនចុះមូលដ្ឋានសរុបរបស់គណបក្សខ្លួន។ អ្នកតំណាងរាស្ត្រគណបក្សជាតិនិយម ចុះមូលដ្ឋាននៅក្រៅមណ្ឌល៥៤%ចុះនៅក្នុងមណ្ឌលរបស់ខ្លួន៤៦%។ អ្នកតំណាងរាស្ត្រគណបក្សហ្វ៊ុនស៊ិនប៉ិច ចុះនៅក្រៅមណ្ឌលរបស់ខ្លួនបាន៦៤% ចុះនៅក្នុងមណ្ឌលរបស់ខ្លួនបាន៤៦%។




*<u>តួលេខ237៖ មណ្ឌលរាជធានី-ខេត្តដែលតំណាងរាស្ត្របានចុះ</u>*

តាមការសង្កេតក្នុងនីតិកាលនេះ (កញ្ញា២០០៨-មិថុនា២០១៣) ខុមហ្វ្រែលបានឃើញថា មានមណ្ឌលចំនួន៣ដែលមានអ្នកតំណាងរាស្ត្រចុះច្រើនជាងគេគឺ មណ្ឌលបាត់ដំបង មណ្ឌលបន្ទាយព្រៃវែង និងមណ្ឌលកណ្ដាល។

មណ្ឌលចំនួន៣ ដែលមានតំណាងរាស្ត្រចុះច្រើនជាងគេនោះ មណ្ឌលបាត់ដំបង ដែលមានអាសនៈអ្នកតំណាងរាស្ត្រនៅក្នុងសភាចំនួន៨រូប ត្រូវបានតំណាងរាស្ត្រចុះច្រើនជាងគេបានចំនួន១៥៦៩លើក។ មណ្ឌលលំដាប់ទី២ ដែលត្រូវបានតំណាងរាស្ត្រចុះច្រើនជាងគេនោះ គឺមណ្ឌលព្រៃវែង ដែលមានអាសនៈតំណាងរាស្ត្រនៅក្នុងសភាចំនួន១១រូប មានតំណាងរាស្ត្រចុះបានចំនួន៨២៨លើក។ មណ្ឌលកណ្ដាលដែលមានអាសនៈចំនួន១១រូប ត្រូវបានតំណាងរាស្ត្រច្រើនលំដាប់ទី៣ចុះបានចំនួន៨០៩លើក។

ក្នុងការចុះមូលដ្ឋានរបស់តំណាងរាស្ត្រ ទៅតាមមណ្ឌលនីមួយៗនៅក្នុងនីតិកាលទី៤នេះ ខុមហ្វ្រែលសង្កេតឃើញថា មានមណ្ឌលចំនួន៣ ស្ថិតនៅក្នុងលំដាប់អ្នកតំណាងរាស្ត្របានតិចតួចជាងគេបំផុត ស្ទើរតែមិនមានអ្នកតំណាងរាស្ត្រចុះ ក្នុងនោះមានមណ្ឌលរតនគីរី មណ្ឌលកែប និងមណ្ឌលមណ្ឌលគីរី។

មណ្ឌលកែប ដែលមានអាសនៈនៅក្នុងសភាចំនួន១រូប មានតំណាងរាស្ត្រចុះមូលដ្ឋានក្នុងមណ្ឌលនេះ បានចំនួន៤លើក ចំពោះមណ្ឌលរតនគីរីដែលមានអាសនៈសភាចំនួន១រូប ត្រូវបានតំណាងរាស្ត្រចុះមូលដ្ឋានក្នុងមណ្ឌលនេះបានចំនួន៧លើក និងមណ្ឌលមណ្ឌលគីរីដែលមានអាសនៈសភា១រូប ដែលនោះមានតំណាងរាស្ត្រចុះបានចំនួន១៤លើក។




## ៣.ការចេញលិខិតរបស់អ្នកតំណាងរាស្ត្រ

នីតិកាលទី៤(កញ្ញា២០០៨-មិថុនា២០១៣) ខុមហ្វ្រែលបានសង្កេតឃើញថា មានអ្នកតំណាងរាស្ត្រចំនួន២៦រូបមកពីគណបក្សចំនួន៤ ដែលមានអាសនៈនៅក្នុងរដ្ឋសភាបានចេញលិខិតសរុបចំនួន២១១ច្បាប់ ដាក់ជូនទៅរាជ

រដ្ឋាភិបាល។

ការចេញលិខិតរបស់តំណាងរាស្ត្រទាំង៤គណបក្សនេះ ខុមហ្វ្រែលឃើញថា ចំនួនតំណាងរាស្ត្រដែលបានចេញលិខិតក្នុងនីតិកាលទី៤ តំណាងរាស្ត្រគណបក្សសម រង្ស៊ី មានចំនួនតំណាងរាស្ត្រ ដែលបានចេញលិខិតបានច្រើនជាងគេ និងតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា និងតំណាងរាស្ត្រគណបក្សជាតិនិយម។ ក្នុងចំណោមតំណាងរាស្ត្រ២៦រូប មានតំណាងរាស្ត្រគណបក្សសម រង្ស៊ី ចំនួន២០រូប តំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សមាន៣រូប តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាចំនួន២រូប និងតំណាងរាស្ត្រគណបក្សជាតិនិយមចំនួន១រូប។

ចំនួនចេញលិខិតរបស់តំណាងរាស្ត្រក្នុងនីតិកាលទី៤នេះ តំណាងរាស្ត្រគណបក្សសម រង្ស៊ី បានចេញលិខិតច្រើនជាងគេ ក្នុងចំណោមតំណាងរាស្ត្រទាំង៤គណបក្ស ដែលបានចេញលិខិត។ តំណាងរាស្ត្រគណបក្សសម រង្ស៊ី បានចេញលិខិតចំនួន១៩១លិខិត តំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស ចេញលិខិតបានចំនួន១២លិខិត តំណាងរាស្ត្រគណបក្សជាតិនិយមបានចេញលិខិត៦ និងតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាបានចេញលិខិតចំនួន៣លិខិត។

ការចេញលិខិតរបស់តំណាងរាស្ត្រក្នុងនីតិកាលនេះ ខុមហ្វ្រែលទទួលបានថា ការចេញលិខិតភាគច្រើនដាក់ក្នុងគោលបំណងស្នើសុំអំពាវនាវ ចាត់វិធានការដល់រាជរដ្ឋាភិបាល ដើម្បីជួយដោះស្រាយបញ្ហានានាដែលអ្នកតំណាងរាស្ត្រទទួលបានព័ត៌មានតាមមូលដ្ឋាន តាមរយៈម្ចាស់ឆ្នោត។ ក្នុងការចេញលិខិតសរុប ខុមហ្វ្រែលឃើញថាតំណាងរាស្ត្របានចេញលិខិតក្នុងគោលបំណងអន្តរាគមន៍២៣លិខិត ក្នុងគោលបំណងអំពាវនាវស្នើសុំចាត់វិធានការចំនួន១៦៣លិខិត គោលបំណងបញ្ចេញមតិបានចំនួន៣ ដាក់ជាសំណួរ៨លិខិត ឆ្លើយបំភ្លឺនៅសភា១៤លិខិត។ ក្នុងនីតិកាលនេះ ខុមហ្វ្រែលសង្កេតឃើញថាលិខិតដែលអ្នកតំណាងរាស្ត្រដាក់ទៅជូនរាជរដ្ឋាភិបាលឃើញថាមានលិខិតចំនួន៥៣ដែលរាជរដ្ឋាភិបាលបានឆ្លើយតបមកវិញ។

*<u>តារាង១៖ ឈ្មោះអ្នកតំណាងរាស្ត្រទាំង២៦រូបដែលបានចេញលិខិត និងគោលបំណងនៃលិខិត</u>*

សំគាល់: ឯ.ឧ. = ឯកឧត្តម, ល.ជ. = លោកជំទាវ

| លរ | គោត្តនាមនិងនាម | គណ | សរុ | គោលបំណងនៃលិខិត | | | | | ការឆ្លើយតម |
|---|---|---|---|---|---|---|---|---|---|
| | | | | អន្តរ | អំព | បញ្ | ដាក់ | បំភ្លឺនៅ | |
| ១ | ឯ.ឧ. ជា ប៉ូច | | ៤ | ០ | ៤ | ០ | ០ | ០ | ២ |
| ២ | ឯ.ឧ ជាម ច័ន្ទនី | | ២ | ០ | ២ | ០ | ០ | ០ | ០ |
| ៣ | ឯ.ឧ ជាម យៀប | | ១ | ១ | ០ | ០ | ០ | ០ | ០ |
| ៤ | ឯ.ឧ ចាន់ ចេង | | ៣ | ០ | ៣ | ០ | ០ | ០ | ០ |
| ៥ | ឯ.ឧ អេង ឆៃអ៊ាង | | ៣ | ១ | ២ | ០ | ០ | ០ | ០ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ៦ | ល.ជ កែ សុវណ្ណរតន៍ | | ៩ | ២ | ៦ | ០ | ១ | ០ | ១ |
| ៧ | ឯ.ឧ ម៉ៅ មុនីវណ្ណ | | ៤ | ០ | ៣ | ០ | ១ | ០ | ០ |
| ៨ | ឯ.ឧ ម៉ែន សុថាវរិន្ទ្រ | | ៥៣ | ៩ | ៤១ | ០ | ០ | ៣ | ២០ |
| ៩ | ឯ.ឧ សៅ រ៉ានី | | ៦ | ១ | ៥ | ០ | ០ | ០ | ០ |
| ១០ | ឯ.ឧ យ៉ែម បុញ្ញប្ញទ្ធិ | | ៦ | ០ | ៥ | ០ | ១ | ០ | ១ |
| ១១ | ឯ.ឧ អ៊ូ ច័ន្ទឫទ្ធិ | | ៤ | ០ | ៤ | ០ | ០ | ០ | ០ |
| ១២ | ឯ.ឧ ហូរ វ៉ាន់ | | ២៩ | ៣ | ២៦ | ០ | ០ | ០ | ១៤ |
| ១៣ | ឯ.ឧ គី វណ្ណដារ៉ា | | ១ | ០ | ១ | ០ | ០ | ០ | ០ |
| ១៤ | ឯ.ឧ គឹម សុខា | | ២ | ០ | ០ | ២ | ០ | ០ | ០ |
| ១៥ | ឯ.ឧ គួយ ប៊ុនរឿន | | ១ | ០ | ១ | ០ | ០ | ០ | ០ |
| ១៦ | ល.ជ លី ស្រីវីណា | | ១ | ០ | ១ | ០ | ០ | ០ | ១ |
| ១៧ | ឯ.ឧ ឡុង រី | | ៤ | ០ | ៤ | ០ | ០ | ០ | ១ |
| ១៨ | ល.ជ មូរ សុខហួរ | | ៧ | ២ | ៣ | ០ | ០ | ២ | ២ |
| ១៩ | ឯ.ឧ នុត រំដួល | | ១ | ០ | ១ | ០ | ០ | ០ | ១ |
| ២០ | ឯ.ឧ សម រង្ស៊ី | | ១០ | ០ | ៦ | ១ | ១ | ២ | ៣ |
| ២១ | ឯ.ឧ សុន ឆ័យ | | ៣៣ | ០ | ២៣ | ០ | ៣ | ៧ | ៥ |
| ២២ | ឯ.ឧ សុវណ្ណ ពិសាខា | | ១ | ០ | ១ | ០ | ០ | ០ | ០ |
| ២៣ | ឯ.ឧ យឹម ឡាគី | | ៩ | ១ | ៨ | ០ | ០ | ០ | ០ |
| ២៤ | ល.ជ ឃួន សុដារី | | ១ | ០ | ១ | ០ | ០ | ០ | ០ |
| ២៥ | ឯ.ឧ យន្ត ថារូ | | ១២ | ២ | ១០ | ០ | ០ | ០ | ០ |
| ២៦ | ឯ.ឧ យឹម សុវណ្ណ | | ៤ | ១ | ២ | ០ | ១ | ០ | ២ |
| សរុប | | | ២១១ | ២៣ | ១៦៣ | ៣ | ៨ | ១៤ | ៥៣ |

ការចេញលិខិតរបស់តំណាងរាស្ត្រទាំង២៦រូប ខុមហ្វ្រែលសង្កេតឃើញថា មានតំណាងរាស្ត្រ៣រូបបានចេញលិខិតច្រើនជាងគេ ក្នុងចំណោមតំណាងរាស្ត្រទាំង៤គណបក្សដែលនៅក្នុងរដ្ឋសភា។ ការចេញលិខិតភាគច្រើនសុទ្ធតែមកពីគណបក្សសម រង្ស៊ី ក្នុងនោះអ្នកតំណាងរាស្ត្រ ម៉ែន សុថាវរិន្ទ្រ មណ្ឌលកំពង់ធំ បានចេញលិខិតច្រើនជាងគេ នៅក្នុងចំណោមតំណាងរាស្ត្រដែលបានចេញលិខិតក្នុងនីតិកាលទី៤។ អ្នកតំណាងរាស្ត្រ ម៉ែន សុថាវរិន្ទ្រ បានចេញលិខិតចំនួន៥៣លិខិត(ស្មើនឹង២៥%នៃចំនួនលិខិតសរុប)។ អ្នកតំណាងរាស្ត្រ សុន ឆ័យ មណ្ឌលភ្នំពេញ បានចេញលិខិតច្រើនជាងគេ លំដាប់ទី២ក្នុងនីតិកាលនេះបានចេញលិខិតចំនួន៣៣លិខិត(ស្មើនឹង១៦%នៃចំនួនចេញលិខិតសរុប)។ អ្នកតំណាងរាស្ត្រ ហូរ វ៉ាន់ បានចេញលិខិតច្រើនជាងគេលំដាប់ទី៣ បានចេញលិខិតចំនួន២៩លិខិត(ស្មើនឹង១៤%នៃចំនួនចេញលិខិតសរុប)។

ក្នុងចំណោមតំណាងរាស្ត្រ៣រូប ដែលបានចេញលិខិតជូនរាជរដ្ឋាភិបាលច្រើនជាងគេក្នុងឆ្នាំនេះ យើងឃើញថា មានអ្នកតំណាងរាស្ត្រ២រូបទេ ដែលរាជរដ្ឋាភិបាលបានឆ្លើយតបមកវិញ។

ការចេញលិខិតរបស់អ្នកតំណាងរាស្ត្រនៅក្នុងនីតិកាលទី៤នេះ ខុមហ្វ្រែលបានទទួលទិន្នន័យពីការចេញលិខិតរបស់អ្នកតំណាងរាស្ត្រចំនួនទាំង២១១លិខិត ជូនទៅរាជរដ្ឋាភិបាល ឃើញមានការការឆ្លើយតបមកវិញបានតែ៥៣លិខិតប៉ុណ្ណោះ ស្មើនឹង២៥%នៃចំនួនលិខិតដែលអ្នកតំណាងរាស្ត្រដាក់ជូនរាជរដ្ឋាភិបាលសរុប។

អ្នកតំណាងរាស្ត្រ ម៉ែន សុថាវិរិន្ទ្រ មណ្ឌលកំពង់ធំ មកពីគណបក្សសម រង្ស៊ី បានចេញលិខិតចំនួន៥៣ច្បាប់ (ស្មើនឹង២៥%នៃចំនួនលិខិតសរុប) ត្រូវបានរាជរដ្ឋាភិបាលឆ្លើយតបមកវិញបានតែ២០លិខិតប៉ុណ្ណោះ។ អ្នកតំណាងរាស្ត្រ សុន ឆ័យ មណ្ឌលភ្នំពេញបានចេញលិខិតចំនួន៣៣ច្បាប់ ត្រូវបានរាជរដ្ឋាភិបាលបានឆ្លើយតបមកវិញចំនួន៩លិខិត។ ចំពោះអ្នកតំណាងរាស្ត្រ ហូរ វ៉ាន់ មណ្ឌលភ្នំពេញ មកពីគណបក្សសម រង្ស៊ី បានចេញលិខិត២៩ច្បាប់ ត្រូវបានរាជរដ្ឋាភិបាលឆ្លើយតបមកវិញចំនួន១៤ច្បាប់។

**ការឆ្លើយតបខ្លះៗ ពីស្ថាប័នពាក់ព័ន្ធចំពោះលិខិតនានារបស់អ្នកតំណាងរាស្ត្រ៖**

- ការឆ្លើយតបចំពោះអ្នកតំណាងរាស្ត្រ ហូរ វ៉ាន់៖ ថ្ងៃទី២១ ខែមេសា ឆ្នាំ២០១១ អ្នកតំណាងរាស្ត្រ ហូរ វ៉ាន់ មណ្ឌលភ្នំពេញ បានចេញលិខិតជម្រាបជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដោយស្នើសុំអន្តរាគមន៍ឲ្យអាជីវករផ្សារមាន់អាំងជាង១០០នាក់ បានលក់ដូរលើចិញ្ចើមផ្លូវ៣១៥ដូចធម្មតាវិញ។ នៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១១ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង ឯកឧត្តម កែប ជុតិមា អភិបាលរាជធានីភ្នំពេញ បានឆ្លើយតបមកសំណើរបស់អ្នកតំណាងរាស្ត្រ ហូរ វ៉ាន់ ថា អនុវត្តតាមសារាចរលេខ ០៣សរ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ របស់រាជរដ្ឋាភិបាល ស្តីពីការដោះស្រាយសំណង់បណ្តោះអាសន្ន លើដីរបស់រដ្ឋដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់ តាមរាជធានី ទីក្រុង និងទីប្រជុំជន អាជ្ញាធរមូលដ្ឋានបានរៀបចំសណ្តាប់ធ្នាប់សាធារណៈ ដោយណែនាំឲ្យអាជីវករដែលលក់ដូរលើចិញ្ចើមផ្លូវលេខ១៣៥ ចំណុចផ្សារមាន់អាំងឲ្យទៅលក់នៅដីឡូត៍ដែលបានរៀបចំថ្មី ដោយម្ចាស់ដីឡូត៍យល់ព្រមទទួលយកទាំងអស់ ប៉ុន្តែអាជីវករមួយចំនួននៅមិនព្រមអនុវត្តតាមការជូនដំណឹងរបស់អាជ្ញាធរមូលដ្ឋាន ដោយសំអាងថា ធ្លាប់បានលក់ដូរអស់រយៈពេលជាង២០ឆ្នាំមកហើយ។ ដើម្បីរៀបចំសណ្តាប់ធ្នាប់រៀបរយសាធារណៈ សាលាខ័ណ្ឌទួលគោកបានចុះអនុវត្តវិធានការរដ្ឋបាល រុះរើការលក់ដូរលើចិញ្ចើមផ្លូវលេខ៣១៥ ចំណុចមុខផ្សារមាន់អាំងបានរួចរាល់ជាស្ថាពរ ដោយមិនអនុញ្ញាតឱ្យលក់ដូរបន្តទៀតបានឡើយ។
- ការឆ្លើយតបនឹងអ្នកតំណាងរាស្ត្រ សុន ឆ័យ៖ នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១១ អ្នកតំណាងរស្ត្រ សុន ឆ័យ មណ្ឌលភ្នំពេញគណបក្សសម រង្ស៊ី បានចេញលិខិតជូនឯកឧត្តម ឯក សំអុល ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ដោយស្នើចាត់វិធានការចំពោះនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្នុងរាជរដ្ឋាភិបាល ដែលបានបំពានមាត្រា៩៦នៃរដ្ឋធម្មនុញ្ញ ដោយមិនឆ្លើយនឹងសំណួររបស់អ្នកតំណាងរាស្ត្រ ដើម្បីជានាការពារគោរពរដ្ឋធម្មនុញ្ញ។
- ប្រធានក្រុមប្រឹក្សាធម្មនុញ្ញបានតបនឹងលិខិតរបស់អ្នកតំណាងរាស្ត្រ សុន ឆ័យ បានឆ្លើយបំភ្លឺថា ខ្ញុំសូមជម្រាបឯកឧត្តម លោកជំទាវមេត្តាជ្រាបថា ក្នុងកិច្ចប្រជុំនាថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១១ ក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យសំណើរបស់ឯកឧត្តម លោកជំទាវរួចហើយ។ ក្រុមប្រឹក្សាធម្មនុញ្ញយល់ឃើញថា សំណើសុំចាត់វិធានការចំពោះនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្នុងរដ្ឋាភិបាលដែលមិនបានឆ្លើយនឹងសំណួររបស់អ្នកតំណាងរាស្ត្រ មិនចូលក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញទេ។

# ព្រឹត្តិការណ៍សំខាន់ៗទាក់ទងសភា និងតំណាងរាស្ត្រ

បន្តការអនុវត្តន៍ការលើក និងការប្រគល់អភ័យឯកសិទ្ធិសភា ដែលមិនស៊ីសង្វាក់តាមច្បាប់ដែលមានស្រាប់

ការសង្កេតសភានីតិកាលទី៣ និងទី៤ ជាពិសេសក្នុង២ឆ្នាំដំបូងនៃនីតិកាលទី៤ នេះបង្ហាញថា ការលើក និងការប្រគល់អភ័យឯកសិទ្ធិសភាដល់តំណាងរាស្ត្រ មានភាពខុសគ្នាទៅតាមការសំរេចរបស់ថ្នាក់ដឹកនាំស្ថាប័ននេះ។

ការលើក និងការប្រគល់អភ័យឯកសិទ្ធិសភារបស់អ្នកតំណាងរាស្ត្រមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ និងបទបញ្ជាផ្ទៃក្នុងរដ្ឋសភា។

រដ្ឋធម្មនុញ្ញមាត្រា៨០ បានលើកឡើងពីអភ័យឯកសិទ្ធិសភារបស់អ្នកតំណាងរាស្ត្រដោយកំណត់ថា ការចោទប្រកាន់ ការចាប់ខ្លួន...អាចធ្វើទៅបាន លុះត្រាតែមានការយល់ព្រមពីរដ្ឋសភា ឬពីគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាក្នុងចន្លោះសម័យប្រជុំនៃរដ្ឋសភា...។

មាត្រានេះ ក៏បានបន្តទៀតដែរថា ការសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា (នៅចន្លោះសម័យប្រជុំ) ត្រូវដាក់ជូនសម័យប្រជុំរដ្ឋសភាខាងមុខ ដើម្បីអនុម័ត តាមមតិភាគច្រើនពីរភាគបីនៃសមាជិករដ្ឋសភាទាំងមូល។ របៀបនៃការលើកអភ័យឯកសិទ្ធសភា ពីអ្នកតំណាងរាស្ត្របានលើកឡើងពិស្តារថែមទៀតនៅក្នុងច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ ពីមាត្រា៧ ដល់មាត្រា១៦ ជាពិសេសផ្តោតទៅលើបទល្មើសព្រហ្មទណ្ឌ ដែលក្នុងនោះតម្រូវឲ្យមានលិខិតស្នើសុំពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ ទោះបីយ៉ាងណា ការអនុវត្តន៍ក្នុងនីតិកាលទី៤នេះ មានភាពមិនស៊ីសង្វាក់គ្នាទៅនឹងនីតិវិធីដែលកំណត់ដោយច្បាប់នេះ ជាពិសេស ការអនុវត្តន៍ការលើកអភ័យឯកសិទ្ធិនៅចន្លោះសម័យប្រជុំរដ្ឋសភា។

មាត្រា១០នៃច្បាប់ ស្តីពីលក្ខន្តិកៈតំណាងរាស្ត្របានលើកឡើងថា ការលើកអភ័យឯកសិទ្ធិសភានៅក្នុងចន្លោះសម័យប្រជុំរដ្ឋសភា គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ត្រូវប្រជុំ និងអនុម័តស្របតាមបទបញ្ជាផ្ទៃក្នុងរដ្ឋសភា។ ទោះបីយ៉ាងណា បទបញ្ជាផ្ទៃក្នុងរដ្ឋសភា មិនបានលើកឡើងពីរបៀបទាក់ទងនឹងការអនុម័តនេះទេ។

មាត្រា១១បានបន្តថា សេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ត្រូវដាក់ជូនសម័យប្រជុំរដ្ឋសភាខាងមុខ ដើម្បីអនុម័តតាមមតិភាគច្រើន ពីរភាគបីនៃចំនួនសមាជិករដ្ឋសភាទាំងមូល។ ទោះបីយ៉ាងណា ច្បាប់នេះក៏មិនមានចែងដែរថា តើការសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា គឺត្រូវចូលជាធរមាននៅពេលសម្រេចនោះ ឬក៏ត្រូវចូលជាធរមាននៅពេលមានការសម្រេចរបស់សមាជិកសភា ភាគច្រើនពីរភាគបីនៃចំនួនសមាជិកសភាទាំងមូល។

ការសង្កេតឃើញថា ក្នុងនីតិកាលទី៤នេះ រដ្ឋសភាធ្លាប់បានលើកអភ័យឯកសិទ្ធិសភា ត្រឹមតែគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាប៉ុណ្ណោះ ហើយការសម្រេចនោះមិនបានដាក់ជូនសម័យប្រជុំរដ្ឋសភា ដើម្បីអនុម័តតាមមាត្រា១១ នៃច្បាប់ ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រឡើយ។

ការអនុវត្តន៍នេះបានធ្វើឡើង ចំពោះការលើកអភ័យឯកសិទ្ធិអ្នកតំណាងរាស្ត្រ **សម រង្ស៊ី**។ គណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា បានសំរេចលើកអភ័យឯកសិទ្ធិសភារបស់អ្នកតំណាងរាស្ត្រសម រង្ស៊ី ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៩ ក្នុងចន្លោះសម័យប្រជុំលើកទី១ និងទី២ ដើម្បីបើកផ្លូវឱ្យតុលាការអាចធ្វើការចោទប្រកាន់ពីបទជេរប្រមាថថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជា ក្នុងអំឡុងពេលយុទ្ធនាការឃោសនារបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០០៨។

ក្រោយពីការសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ការលើកអភ័យឯកសិទ្ធិនេះ ក៏បានចូលជាធរមាន

ហើយតុលាការក៏បានធ្វើការចោទប្រកាន់ភ្លាមៗដែរ ដោយមិនចាំបាច់រង់ចាំការអនុម័តយល់ព្រមពីសមាជិកសភាដូចចែងក្នុងមាត្រា១១នៃច្បាប់ ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រនោះទេ។

សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា អ្នកតំណាងរាស្ត្រ**ឈាង វុន** ធ្លាប់ត្រូវបានប្រព័ន្ធផ្សព្វផ្សាយស្រង់សម្តីការពារការសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ថា «*...សភាឈប់សម្រាកហើយ គណៈកម្មាធិការអចិន្ត្រៃយ៍មានអំណាចព្យួរអភ័យឯកសិទ្ធរបស់លោកសម រង្ស៊ី ដោយគ្មានតម្រូវការសម្លេងឆ្នោតរបស់សភាទាំងមូលតាមរដ្ឋធម្មនុញ្ញឡើយ*»។

ជាងនេះទៅទៀត នៅពេលសម័យប្រជុំរដ្ឋសភាទី២ចាប់ផ្តើម គណៈកម្មាធិការអចិន្ត្រៃយ៍ មិនបានដាក់ជូនសម័យប្រជុំរដ្ឋសភា ដើម្បីអនុម័តការសម្រេចទៅលើការព្យួរនោះទេ។

ការអនុវត្តន៍បែបនេះ បានចោទជាសំណួរថា តើគណៈកម្មាធិការអចិន្ត្រៃយ៍ដែលមានសមាជិក១២រូប កំពុងតែដើរតួនាទីជំនួសសមាជិកសភា ពីរភាគបី(៨២រូប) ក្នុងការលើកអភ័យឯកសិទ្ធិសភាដែលសម្លេងនេះ គឺមានច្រើនជាងតម្រូវការអនុម័តច្បាប់ និងបោះឆ្នោតផ្តល់សេចក្តីទុកចិត្តដល់រាជរដ្ឋាភិបាលទៅទៀត ដែលត្រូវការសម្លេងសមាជិកសភាច្រើនដាច់ខាតតែ៦៣រូបប៉ុណ្ណោះ។

អ្នកវិភាគខ្លះលើកឡើងថា «*គណៈកម្មាធិការអចិន្ត្រៃយ៍ធ្វើហួសមាឌរបស់គាត់ ព្រោះខ្លួនគ្រាន់តែជាអ្នកសំរេចលើកយករបៀបវារៈដកអភ័យឯកសិទ្ធិទៅដាក់ក្នុងសម័យប្រជុំពេញអង្គប៉ុណ្ណោះ មិនមែនមានសិទ្ធិសំរេចដកតែម្តងទេ។ គណៈកម្មាធិការអចិន្ត្រៃយ៍គ្រាន់តែជារដ្ឋបាលសំរាប់ទាក់ទងនៅសម័យរដ្ឋសភាវិស្សមកាលប៉ុណ្ណោះ*»។

បើមើលក្នុងទិដ្ឋភាពនយោបាយ ប្រសិនបើការអនុវត្តន៍បែបនេះ នៅតែបន្តទៀតដោយការលើកអភ័យឯកសិទ្ធិសភា ត្រឹមគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា នោះអភ័យឯកសិទ្ធិសភាដែលចាត់ទុកថា ជាអាវក្រោះសម្រាប់ការពារតំណាងរាស្ត្រនឹងងាយត្រូវដកចេញ ដោយគណបក្សណាដែលមានសម្លេងគ្របដណ្តប់ក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ដោយមិនត្រូវការការអនុម័តពីតំណាងរាស្ត្រយ៉ាងតិច៨២រូប ដែលអាចមកពីគណបក្សចម្រោះនោះទេ។

ប្រការនេះ នឹងធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំងដល់ការបំពេញការងាររបស់អ្នកតំណាងរាស្ត្រ ដែលមិនកាន់អំណាចក្នុងការឃ្លាំមើល ដែលរួមទាំងការបញ្ចេញមតិរិះគន់ការងាររបស់រាជរដ្ឋាភិបាលផងដែរ ដែលជួនកាលត្រូវបានចោទពីបទបរិហារកេរ្តិ៍។ល។

ទន្ទឹមនឹងនេះ ការប្រគល់អភ័យឯកសិទ្ធិសភាដល់តំណាងរាស្ត្រវិញ ក៏មានការអនុវត្តន៍ពុំទាន់ច្បាស់ដែរ ហើយមាននិយាយតិចតួចប៉ុណ្ណោះ នៅក្នុងច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ មាត្រា១៥ ដែលថាអ្នកតំណាងរាស្ត្រណាមួយជាទណ្ឌិត ត្រូវបានព្រះមហាក្សត្រលើកលែងទោស នោះតំណាងរាស្ត្រនោះនឹងបានអភ័យឯកសិទ្ធិឡើងវិញ និងមាត្រា១៦ដែលថា តំណាងរាស្ត្រដែលមានសាលក្រមស្ថាពរ ឬសាលដីកាសម្រេចថា ជាជនគ្មានទោស តំណាងរាស្ត្រនោះបានទទួលជាស្វ័យប្រវត្តិនូវអភ័យឯកសិទ្ធិ...ពេញលេញឡើងវិញ។

ទោះបីយ៉ាងណា ការអនុវត្តន៍ជាក់ស្តែងដើម្បីបានអភ័យឯកសិទ្ធិមកវិញ គឺទាមទារនៅនីតិវិធីដែលបកស្រាយខុសៗគ្នា ទៅលើមាត្រា១៥ និង១៦ នេះ ហើយជាទូទៅអ្នកសម្រេច គឺគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា។

ក្នុងនីតិកាលទី៤ ការសង្កេតឃើញថា ការប្រគល់អភ័យឯកសិទ្ធិសភា គឺដើរតាមនីតិវិធីដូចការ «លើក» ដែរ ហើយនីតិវិធីបែបនេះ ត្រូវបានការពារដោយសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា។ បានន័យថា ប្រសិនបើតុលាការជាអ្នកស្នើលើកអភ័យឯកសិទ្ធិ ហើយការលើកអភ័យឯកសិទ្ធិ តាមរយៈការបោះឆ្នោតដោយ

សមាជិករដ្ឋសភា នោះការប្រគល់អភ័យឯកសិទ្ធសភាវិញ លុះត្រាតែមានលិខិតពីតុលាការ តាមរយៈក្រសួងយុត្តិធម៌ ហើយត្រូវធ្វើការបោះឆ្នោតផ្តល់អភ័យឯកសិទ្ធិដោយសមាជិកសភាវិញផងដែរ។

សំណួរថា ប្រសិនបើតំណាងរាស្ត្រដែលត្រូវបានលើកអភ័យឯកសិទ្ធិ ត្រូវបានតុលាការរកឃើញថា គ្មានទោស ក៏ប៉ុន្តែតុលាការ ឬក្រសួងមិនបានបញ្ជូនលិខិតមករដ្ឋសភាទេនោះ (ព្រោះមិនមានច្បាប់ ឬឯកសារណាឲ្យក្រសួងយុត្តិធម៌បញ្ជូនលិខិតមកវិញ ដូចកាលស្នើលើកអភ័យឯកសិទ្ធិនោះទេ) នោះតំណាងរាស្ត្រនោះនឹងមិនបានទទួលអភ័យឯកសិទ្ធិរបស់ខ្លួនវិញនោះទេ។

បញ្ហាក៏អាចចោទដែរថា ប្រសិនបើត្រូវបោះឆ្នោតតាមសម្លេង ពីរភាគបី ដើម្បីបានអភ័យឯកសិទ្ធិមកវិញ ចុះបើសិនជាសមាជិកសភាមិនបោះឆ្នោតឲ្យ នោះថាតើអភ័យឯកសិទ្ធិសភារបស់អ្នកតំណាងរាស្ត្រនោះក៏នៅតែនឹងមិនបានវិញទេឬ? គ្មានច្បាប់ណាដែលកំណត់ថា អភ័យឯកសិទ្ធិរបស់តំណាងរាស្ត្រត្រូវបានប្រគល់វិញ តាមរយៈការបោះឆ្នោតគាំទ្រពីអ្នកតំណាងរាស្ត្រនោះទេ។

ការបកស្រាយ ក៏ដូចជាការអនុវត្តន៍បែបនេះ មិនមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ ឬបទបញ្ជាផ្ទៃក្នុងរដ្ឋសភានោះទេ។ ហើយវាហាក់ដូចជាមានភាពចម្រូងចម្រាស់ទៅនឹងមាត្រា១៥ និង១៦នៃច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ ដែលធានាដល់ការបានអភ័យឯកសិទ្ធិជាស្វ័យប្រវត្តិនៅពេលគ្មានទោស ឬត្រូវបានលើកលែងទោស។

ភាពមិនរលូននូវការអនុវត្តន៍បែបនេះ បានកើតមាននៅក្នុងឆ្នាំសង្កេតនេះនៅក្នុងករណីអ្នកតំណាងរាស្ត្រ **ហូ វ៉ាន់** មណ្ឌលភ្នំពេញ មកពីគណបក្សសម រង្ស៊ី ដែលត្រូវបានលើកអភ័យឯកសិទ្ធិ ដើម្បីឲ្យតុលាការធ្វើការចោទប្រកាន់ ក៏ប៉ុន្តែត្រូវបានតុលាការលើកលែងការចោទប្រកាន់វិញ នៅចុងខែកញ្ញា ឆ្នាំ២០០៩។ ទោះបីយ៉ាងណា អភ័យឯកសិទ្ធិសភារបស់អ្នកតំណាងរាស្ត្ររូបនេះ ត្រូវបានផ្តល់មកឲ្យវិញនៅដើមខែមីនា ឆ្នាំ២០១០ គឺរយៈពេលប្រមាណ៦ខែ បន្ទាប់ពីការលើកលែងការចោទប្រកាន់។

ជាមួយគ្នានេះ បើមើលតាមទិដ្ឋភាពនយោបាយវិញ ការផ្តល់អភ័យឯកសិទ្ធិវិញ តាមរយៈការបោះឆ្នោតសំលេងភាគច្រើនពីរភាគបីក៏អាចជាបញ្ហាផងដែរ នៅពេលដែលបុគ្គលមានអំណាចក្នុងគណបក្សឈ្នះឆ្នោតចង់ធ្វើបាបគូប្រឆាំងរបស់ខ្លួន តាមរយៈមិនបោះឆ្នោតផ្តល់អភ័យឯកសិទ្ធសភាឲ្យវិញ។

អនុប្រធានគណបក្សប្រជាជនកម្ពុជា សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ធ្លាប់បាននិយាយជាសាធារណៈនៅខែមិថុនា ឆ្នាំ២០០៩ ទៅដល់ការលើកអភ័យឯកសិទ្ធិសភារបស់អ្នកតំណាងរាស្ត្រចំនួនពីររូប ដោយមិនបញ្ចេញឈ្មោះថា *«ខ្ញុំករុណាព្រួយណាស់ ព្រួយថា ដកមួយហ្នឹង៩១អ្នក [សម្លេង][តំណាងរាស្ត្រមណ្ឌល] នៅភ្នំពេញ [និងតំណាងរាស្ត្រ] កំពត៩០ [សម្លេង] ដល់ឲ្យទៅវិញ ឲ្យវាមិនកើត»*។

ដូចនេះ ការអនុវត្តន៍បែបនេះ តាមរយៈ **«ការលើកតាមណា ផ្តល់តាមហ្នឹង»** គឺកំពុងតែអាចរំលោភទៅលើល័ក្ខខ័ណ្ឌទទួលបានអភ័យឯកសិទ្ធិដោយស្វ័យប្រវត្តិវិញ ហើយវានឹងក្លាយជាឧបករណ៍នយោបាយមួយ នៅពេលណាដែលមានអំណាចចង់ប្រើប្រាស់វា។

ជាក់ស្តែង ការសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ក្នុងនីតិកាលទី៤នេះ ក៏មិនស៊ីសង្វាក់គ្នាដែរ ដែលថាអភ័យឯកសិទ្ធិលើកតាមណា ត្រូវប្រគល់ឲ្យវិញតាមនោះដែរ។

អ្នកតំណាងរាស្ត្រ **ហូ វ៉ាន់** ត្រូវបានសភាដកអភ័យឯកសិទ្ធិ តាមរយៈការបោះឆ្នោត ក៏ប៉ុន្តែនៅពេលប្រគល់អភ័យឯកសិទ្ធិវិញ គឺគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាជាអ្នកសម្រេចប្រគល់ឲ្យ ដោយគ្មានការបោះឆ្នោតពី

សមាជិករដ្ឋសភានោះទេ។

គណៈកម្មាធិការខុមហ្វ្រែលយល់ឃើញថា នីតិវិធីនៃការលើកអភ័យឯកសិទ្ធិមានចែងពិស្តារនៅក្នុងច្បាប់ ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ ក៏ប៉ុន្តែ គឺកង្វះខាតការអនុវត្តន៍ឲ្យបានពេញលេញទៅតាមមាត្រា ក៏ដូចជាអត្ថន័យនៅក្នុងច្បាប់នេះ ទាក់ទងនឹងការលើកអភ័យឯកសិទ្ធិតំណាងរាស្ត្រ នៅចន្លោះសម័យប្រជុំដែលតម្រូវឲ្យការសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាទាក់ទងនឹងការលើកអភ័យឯកសិទ្ធិ ត្រូវតែទទួលបានការអនុម័តពីសមាជិកសភាពីរភាគបី ហើយគណៈកម្មាធិការខុមហ្វ្រែលស្នើសុំបញ្ឈប់ការអនុវត្តន៍ការលើកអភ័យឯកសិទ្ធិសភា ត្រឹមតែគណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា។

ជាមួយគ្នានេះដែរ គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ក៏គួរបញ្ឈប់ការអនុវត្តន៍ការប្រគល់អភ័យឯកសិទ្ធិតាមការបកស្រាយដោយខ្លួនឯងថា ការប្រគល់អភ័យឯកសិទ្ធិវិញ គឺធ្វើតាមនីតិវិធីនៃការដក។ តែត្រូវពង្រឹងការអនុវត្តន៍មាត្រា១៥ និង១៦នៃច្បាប់ ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រដែលធានាដល់ការបានអភ័យឯកសិទ្ធិសភាមកវិញ ដោយស្វ័យប្រវត្តិចំពោះតំណាងរាស្ត្រណាដែលគ្មានទោស ឬព្រះមហាក្សត្រលើកលែងទោស។

## អ្នកតំណាងរាស្ត្រស្ត្រី ចង់បង្កើតក្រុមតំណាងរាស្ត្រស្ត្រី

នៅចុងឆ្នាំសង្កេតនេះ (ខែកញ្ញា២០១០) មានការជួបជុំគ្នា រវាងស្ត្រីជាថ្នាក់ដឹកនាំក្នុងប្រទេស និងក្រៅប្រទេសមួយចំនួននៅក្នុងសិក្ខាសាលា ស្តីពីគោលការណ៍សហស្សវត្សរ៍ ស្តីពីការសម្រេចឱ្យបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ទី៣នៅឆ្នាំ២០១៥ ដើម្បីសំរេចឱ្យមានស្ត្រីចូលរួមនៅក្នុងវិស័យនយោបាយឱ្យបានច្រើន ដោយក្នុងនោះមានការជំរុញឱ្យមានការបង្កើតក្រុមតំណាងរាស្ត្រស្ត្រីផងដែរ ដែលទទួលស្គាល់ដោយរដ្ឋសភាខ្លួនឯងផ្ទាល់ ដើម្បីលើកកម្ពស់ការងារ និងការពារផលប្រយោជន៍ស្ត្រី។

អ្នកតំណាងរាស្ត្រស្ត្រី មកពីគណបក្សកាន់អំណាច និងគណបក្សជំទាស់ ហាក់បង្ហាញការគាំទ្រចំពោះការបង្កើតក្រុមតំណាងរាស្ត្រស្ត្រី ក្នុងគោលបំណងការពារផលប្រយោជន៍ស្ត្រី ក៏ប៉ុន្តែការសង្កេតឃើញថា និន្នាការនយោបាយ ហាក់ធ្វើឲ្យតំណាងរាស្ត្រក្នុងគណបក្សទាំងពីរនេះពិបាកធ្វើការជាមួយគ្នា។

អ្នកតំណាងរាស្ត្រស្ត្រី គណបក្សកាន់អំណាចលើកឡើងថា តំណាងរាស្ត្រស្ត្រីគណបក្សប្រឆាំង មិនសហការធ្វើការជាមួយខ្លួន ខណៈដែលតំណាងរាស្ត្រស្ត្រីគណបក្សប្រឆាំងថា មានការរើសអើងចំពោះខ្លួន នៅពេលចុះអនុវត្តការងាររួមគ្នា។

អ្នកតំណាងរាស្ត្រ **ឡោក ខេង** មណ្ឌលភ្នំពេញ មកពីគណបក្សកាន់អំណាចប្រជាជនកម្ពុជា បានលើកឡើងក្នុងឱកាសសិក្ខាសាលាខាងលើថា *«សភានាងខ្ញុំបច្ចុប្បន្នមានការលំបាកណាស់ ចំពោះការចូលរួមរបស់ស្ត្រី ដោយយើងស្ថិតនៅក្នុងគណបក្សកាន់អំណាចជាស្ត្រី មានមតិភាគច្រើនក្នុងសភាធ្វើអ្វីមួយៗ ចង់ឱ្យគេចូលរួមទាំងអស់គ្នា តែកម្រឃើញគេចូលរួមណាស់ ពីគណបក្សដែលមានសំលេងភាគតិចនៅក្នុងសភា ព្រោះខ្ញុំមានបញ្ហាថា អញ្ជើញគេមកអត់ដែលគេចូលរួមផង។»*

ទោះបីយ៉ាងណា អ្នកតំណាងរាស្ត្រគណបក្សសម រង្ស៊ី មណ្ឌលសៀមរាប **កែ សុវណ្ណរ័តន៍** បានលើកឡើងពីការមិនឲ្យតម្លៃដល់តំណាងរាស្ត្រស្ត្រី មកពីគណបក្សសម្លេងភាគតិចថា *«គ្មានតម្លាភាព។ ខ្ញុំធ្លាប់បានចូលរួមជាមួយក្រុមស្ត្រីគណៈកម្មការតាមខេត្តមួយចំនួនទៅចែកអំណោយ។ធ្វើ សន្ទរកថាឱ្យប្រធានក្រុមមានសិទ្ធិនិយាយ។ ប្រធានមកពីគណបក្សកាន់អំណាចទៀត ហើយយើងទៅបានអង្គុយល្អ មើលការចាត់ចែងមិនស្មើភាព។»*

អ្នកតំណាងរាស្ត្ររូបនេះ មិនមានជំនឿចិត្តថា ក្រុមតំណាងរាស្ត្រស្ត្រី បើទោះបីជាត្រូវបានបង្កើតនឹងមិនជោគ

ជ័យក្នុងការធ្វើការសហការ ដើម្បីការពារផលប្រយោជន៍ស្ត្រីបាននោះដែរ ដោយបង្ហាញថា *«កន្លងមក ស្ត្រីគ្នាឯងធ្លាប់លើកដៃដកអភ័យឯកសិទ្ធិគ្នាឯង។ ម្យ៉ាងទៀត ស្ត្រីនៅក្នុងគណបក្សកាន់អំណាច មិនហ៊ានចេញមុខអន្តរាគមន៍ជួយស្ត្រីគ្នាឯង ដូចករណីលោកជំទាវ មូរ សុខហួរផង។»*

ក្រុមតំណាងរាស្ត្រស្ត្រីបង្កើតឡើង ដើម្បីជំរុញឱ្យស្ត្រីមានអំណាច និងលើកទឹកចិត្តដើម្បីចូលរួមក្នុងការសំរេចចិត្តថ្នាក់ជាតិ ថ្នាក់តំបន់ និងជំរុញឱ្យស្ត្រីកាន់តែមានភាពក្លាហាន ក្នុងការសំដែងមតិរបស់ខ្លួន ដោយមិនមានការកៀបសង្កត់ ហើយរដ្ឋសភា គួរមានចំណែកថវិកា និងយន្តការដើម្បីសំរួលក្នុងការធ្វើយ៉ាងណា ដើម្បីបំផុសឱ្យស្ត្រីធ្វើសកម្មភាពធំៗថ្នាក់ជាតិ។

ក៏ប៉ុន្តែ ការប្រកាន់និន្នាការនយោបាយរៀងៗខ្លួន ហាក់ជាឧបសគ្គក្នុងការបង្កើតក្រុមនេះឡើង ឲ្យមានប្រសិទ្ធិភាព។

## គណបក្សរំលាយ អាសនៈតំណាងរាស្ត្របាត់បង់

ក្នុងឆ្នាំអង្កតនេះដែរ ក្នុងខែសីហា ឆ្នាំ២០១០ ក្រុមប្រឹក្សាធម្មនុញ្ញដែលជាស្ថាប័នបកស្រាយច្បាប់កំពូល បានកំណត់ភាពជា តំណាងប្រជាពលរដ្ឋរបស់អ្នកតំណាងរាស្ត្រកាន់តែខ្សោយថែមទៀត បន្ទាប់ពីក្រុមប្រឹក្សាធម្មនុញ្ញបានបកស្រាយសំណួររបស់អ្នកតំណាងរាស្ត្រ ទាក់ទងនឹងភាពតំណាងនេះថា សមាជិកភាពសភានឹងត្រូវបាត់បង់បើសិនជា គណបក្សនយោបាយដែលអ្នកតំណាងរាស្ត្រជាសមាជិកនោះត្រូវបានរំលាយ។

ការបកស្រាយនេះ ជាការឆ្លើយតបទៅនឹងសំណួររបស់អ្នកតំណាងរាស្ត្រ សៅ រ៉ានី មកពីគណបក្សជាតិនិយមដែលចង់ច្របាច់បញ្ចូលគ្នាជាមួយគណបក្សហ្វ៊ុនស៊ិនប៉ិច ទៅក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា៣៦នៃច្បាប់ ស្តីពីគណបក្សនយោបាយ នៅពេលគណបក្សនយោបាយរួមបញ្ចូលគ្នា តើសមាជិកសភានឹងបាត់បង់អាសនៈដែរឬទេ?

ម្យ៉ាងទៀត ច្បាប់បោះឆ្នោតក៏បានចងសមាជិកភាពអ្នកតំណាងរាស្ត្រ ទៅនឹងគណបក្សនយោបាយ ដែលបានន័យថា តំណាងរាស្ត្រណាដែលបាត់សមាជិកភាពពីគណបក្សនយោបាយនោះ សមាជិកសភាក៏ត្រូវបាត់បង់ផងដែរ។

ការបកស្រាយរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ក៏មិនបានឆ្លុះបញ្ចាំងក្នុងក្របខ័ណ្ឌធម្មនុញ្ញភាព និងគោលការណ៍សំខាន់ ភាពជាតំណាងរបស់អ្នកតំណាងរាស្ត្រ ព្រោះថា រដ្ឋធម្មនុញ្ញមិនបាននិយាយថា តំណាងរាស្ត្រ គឺស្មើតំណាងគណបក្សនោះទេ។

ការបកស្រាយរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ទៅលើមាត្រា៣៦នេះ ដែលតម្រូវឲ្យអាសនៈរបស់គណបក្សនយោបាយជាប់ឆ្នោតត្រូវរលាយនៅពេល១) គណបក្សនយោបាយណា ដែលបញ្ចូលខ្លួនជាមួយគណបក្សផ្សេងទៀត តំណាងរាស្ត្រគណបក្សដែលទៅចូលរួមជាមួយគេ នឹងត្រូវបាត់បង់អាសនៈដែលបានមកពីការជាប់ឆ្នោតទាំងអស់ ឬ ២) ប្រសិនបើគណបក្សបញ្ចូលគ្នាហើយ បង្កើតជាគណបក្សថ្មី នោះគណបក្សដើមបានប្រកាសរំលាយ នោះអ្នកតំណាងរាស្ត្ររបស់ខ្លួន ត្រូវបាត់បង់អាសនៈដែលបានមកពីការបោះឆ្នោតទាំងអស់។

ការបកស្រាយនេះ ត្រូវបានអ្នកវិភាគខ្លះយល់ថា ហាក់ចង់ព្រមានដល់គណបក្សជំទាស់ទាំងឡាយដែលមានបំណងរួមបញ្ចូលគ្នា បង្កើតគណបក្សផ្សេង ដើម្បីប្រកួតប្រជែងការបោះឆ្នោតពីគណបក្សកាន់អំណាច ឬគណបក្សនោះត្រូវបានរំលាយដោយសាលក្រម ឬសាលដីការបស់តុលាការ អាចនឹងឈានដល់ការបាត់បង់អាសនៈនៅរដ្ឋសភា ព្រឹទ្ធសភា និងក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ហើយក៏បានបង្ហាញឲ្យឃើញយ៉ាងច្បាស់នូវចេតនាប្រហែស ឬចន្លោះសម្រាប់បកស្រាយ ពីភាពមិនប្រក្រតីនៃបញ្ញត្តិទាំងឡាយ ដែលបានតាក់តែង និងអនុម័តឡើង ដើម្បីដាក់

គំនាប រឹតបន្តឹងភាពជាតំណាង។

ខុមហ្វ្រែលយល់ឃើញថា ដើម្បីធានាដល់គោលការណ៍របស់រដ្ឋធម្មនុញ្ញ ជាពិសេសគោរពដល់មាត្រា៧៧ ដែលកំណត់ថា អ្នកតំណាងរាស្ត្រជាតំណាងប្រជាពលរដ្ឋទូទាំងប្រទេស សមាជិកសភា គួរធ្វើវិសោធនកម្មច្បាប់បោះឆ្នោត ដោយមិនត្រូវចងសមាជិកសភាពអ្នកតំណាងរាស្ត្រទៅនឹងគណបក្សនយោបាយ និងធ្វើវិសោធនកម្មមាត្រា៣៦នៃច្បាប់ ស្តីពីគណបក្សនយោបាយដោយបញ្ជាក់ឲ្យច្បាស់ថា គណបក្សដែលរំលាយ ឬបញ្ចូលជាមួយគណបក្សដទៃទៀត នឹងមិនត្រូវបាត់បង់អាសនៈរបស់ខ្លួននោះទេ រហូតដល់ចប់អាណត្តិរបស់ខ្លួន។

## អ្នកតំណាងរាស្ត្រសម រង្ស៊ី ត្រូវតុលាការកាត់ទោសឲ្យជាប់ពន្ធនាគារ១២ឆ្នាំ

អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ចាម សម រង្ស៊ី និងជាប្រធានគណបក្សសម រង្ស៊ី ត្រូវបានតុលាការកាត់ទោសឲ្យជាប់ពន្ធនាគារសរុប១២ឆ្នាំ នៅក្នុងសំណុំរឿងពីរផ្សេងគ្នា ជាមួយរាជរដ្ឋាភិបាលដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា។

ការកាត់ទោសនេះ បានធ្វើឡើង បន្ទាប់ពីសមាជិកសភាមកពីគណបក្សកាន់អំណាចបោះឆ្នោតព្យួរអភ័យឯកសិទ្ធិសភាជាលើកទី២នៅក្នុងខែវិច្ឆិកា ឆ្នាំ២០០៩ ដើម្បីបើកផ្លូវឱ្យតុលាការខេត្តស្វាយរៀងធ្វើការស៊ើបសង្កេត និងចោទប្រកាន់អ្នកតំណាងរាស្ត្ររូបនេះ ពីបទប្រព្រឹត្តអំពើដកបំផ្លាញតម្រុយបង្គោលព្រំដែនកម្ពុជាវៀតណាម និងញុះញង់ឱ្យប្រព្រឹត្តបទល្មើសឧក្រិដ្ឋ និងមជ្ឈឹម ដោយពុំបានសំរេចផលនៅស្រុកចន្ទ្រា ខេត្តស្វាយរៀង ហើយនៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០១០ តុលាការខេត្តស្វាយរៀង ក៏បានកាត់ទោសឲ្យអ្នកតំណាងរាស្ត្ររូបនេះ ជាប់ពន្ធនាគាររយៈពេល២ឆ្នាំ និងផាកពិន័យជាប្រាក់ជាង៦០លានរៀល។

ថែមទៀត ដោយសារបញ្ហាព្រំដែន រាជរដ្ឋាភិបាលបានដាក់ពាក្យបណ្តឹងនេះទៅតុលាការ ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១០ ដោយចោទប្រកាន់ពីបទក្លែងបន្លំឯកសារសាធារណៈ និងផ្សព្វផ្សាយពត៌មានមិនពិត ដែលអ្នកតំណាងរាស្ត្ររូបនេះ បានបង្ហោះឯកសារទាក់ទងនឹងព្រំដែនកម្ពុជា វៀតណាមតាមអ៊ីនធឺណែត។

នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១០ តុលាការរាជធានីភ្នំពេញ ក៏បានកាត់ទោសឲ្យអ្នកតំណាងរាស្ត្រសម រង្ស៊ី ជាប់ពន្ធនាគារ១០ឆ្នាំទៀត ពីបទផ្សាយព័ត៌មានមិនពិត និងក្លែងបន្លំឯកសារសាធារណៈ តាមការប្តឹងរបស់រាជរដ្ឋាភិបាល។

ដូចនេះ ក្នុងឆ្នាំសង្កេតនេះ អ្នកតំណាងរាស្ត្ររូបនេះ ត្រូវបានតុលាការកាត់ទោសសរុបរយៈពេល១២ឆ្នាំ។ ទោះបីយ៉ាងណា អ្នកតំណាំងរាស្ត្ររូបនេះបាននិរទេសខ្លួននៅក្រៅប្រទេស ហើយសំណុំរឿងនេះ ក៏កំពុងប្តឹងឧទ្ធរណ៍បន្តទៀត។

ខុមហ្វ្រែលយល់ថា បញ្ហាជម្លោះព្រំដែន រវាងតំណាងរាស្ត្រជាមួយនឹងរាជរដ្ឋាភិបាលនេះ គួរមានដំណោះស្រាយបែបនយោបាយ ព្រោះអ្នកតំណាងរាស្ត្រ គឺជាបុគ្គលដែលតំណាងឱ្យប្រជាពលរដ្ឋទាំងមូល ហើយដែលមានតួនាទីត្រួតពិនិត្យការងាររបស់រាជរដ្ឋាភិបាល ហើយសមាជិកសភាសហគមន៍អឺរុបខ្លះ ក៏បានអំពាវនាវឱ្យមានដំណោះស្រាយបែបនយោបាយនេះដែរ។

## ឱកាសអតីតអ្នកតំណាងរាស្ត្រ សម រង្ស៊ី និងការចូលស្រុកវិញ

អតីតតំណាងរាស្ត្រ សម រង្ស៊ី ដែលបានភៀសខ្លួននៅក្រៅប្រទេសជិត២ឆ្នាំ ព្រោះគេចពីការផ្តន្ទាទោសរបស់តុលាការក្រុងភ្នំពេញនឹងត្រូវជាប់ពន្ធនាគារចំនួន១២ឆ្នាំនោះ អាចមានសង្ឃឹមថា អាចចូលស្រុកវិញបាន ប្រសិនបើងាកមកបន្ធន់ឥរិយាបថទន់ភ្លន់ចំពោះរាជរដ្ឋាភិបាល និងមានការជួយអន្តរាគមន៍ពីខាងសហគមន៍អន្តរជាតិ ដែល

មានឥទ្ធិពលមិនឈប់ឈរមកលើរដ្ឋសភា និងរាជរដ្ឋាភិបាល។

ហើយការអវត្តមានរបស់អ្នកតំណាងរាស្ត្រ សូម្បីតែ១រូប ក្នុងចំណោមអ្នកតំណាងរាស្ត្រ១២៣រូប ក៏មិនមែនជាសារល្អ ចំពោះស្ថាប័នរដ្ឋសភាក្នុងការត្រួតពិនិត្យស្ថាប័នប្រតិបត្តិរបស់រាជរដ្ឋាភិបាល ការចុះជួប និងអន្តរាគមន៍ចំពោះម្ចាស់ឆ្នោត ដែលជួបបញ្ហាប្រឈម ដូចជារឿងដីធ្លីជាដើម ហើយម្ចាស់ឆ្នោតក៏មិនសប្បាយចិត្ត នៅពេលឃើញអ្នកនយោបាយមិនសហការគ្នាដែរ។

កន្លងមក ការសម្របសម្រួលនយោបាយធ្លាប់កើតមាន ដើម្បីអាចឲ្យអ្នកនយោបាយដែលមានទោស អាចនឹងរួចទោសវិញ តាមរយៈការស្នើរបស់រាជរដ្ឋាភិបាលទៅព្រះមហាក្សត្រ ដើម្បីប្រើព្រះរាជសិទ្ធិលើកលែងទោស តាមជំពូក២ មាត្រាទី២៧នៃរដ្ឋធម្មនុញ្ញ «ព្រះមហាក្សត្រទ្រង់មានព្រះរាជសិទ្ធិបន្ធូរបន្ថយទោស និងលើកលែងទោស» ប៉ុន្តែក្នុងនោះ ត្រូវមានការដោះដូរ ជាថ្នូរនឹងកត្តាផ្សេងៗជាមួយនឹងរាជរដ្ឋាភិបាល។

ថ្មីៗនេះ សញ្ញាវិជ្ជមានដែលអ្នកតំណាងរាស្ត្រ ជាម យៀប ជាប្រធានគណៈកម្មការទី២នៃរដ្ឋសភា និងជាអ្នកនាំពាក្យរបស់គណបក្សប្រជាជនកម្ពុជា បានផ្ដល់ឲ្យអតីតតំណាងរាស្ត្រ សម រង្ស៊ី ក៏ដូចជាសមាជិកសភាមកពីគណបក្សសម រង្ស៊ី តាមប្រព័ន្ធផ្សព្វផ្សាយថា អតីតតំណាងរាស្ត្រ សម រង្ស៊ី អាចនឹងមានដំណោះស្រាយ ដើម្បីឲ្យអតីតតំណាងរាស្ត្ររូបនេះ អាចនឹងចូលស្រុកវិញបាន ដោយមិនចាំបាច់ផ្ដន្ទាទោស ប្រសិនបើអតីតតំណាងរាស្ត្រឈប់រិះគន់ វាយប្រហារ ហើយងាកមកសម្របឥរិយាបថជាមួយនឹងរាជរដ្ឋាភិបាល «*ប្រកពីរ ដែលគាត់ចេញពីពេលខាងមុខ ដែលគាត់សុំបាន។ ដូចមុន សម រង្ស៊ី ធ្លាប់បានគេដកអភ័យឯកសិទ្ធិធ្លាប់ជាប់គុកប៉ុន្មានដង។ ប៉ុន្តែរួចខ្លួន ដោយសារតែព្រះករុណាអនុវត្តតាមជំពូក២ ព្រះមហាក្សត្រមានព្រះរាជសិទ្ធិលើកលែងទោស និងបន្ធូរបន្ថយទោស ឬក៏រដ្ឋសភាមានសិទ្ធិធ្វើច្បាប់លើកលែងទោស*»។

ជាការបើកផ្លូវ សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី និងជាតំណាងរាស្ត្រកណ្ដាលរបស់គណបក្សប្រជាជនកម្ពុជា បានថ្លែងបញ្ជាក់ពីជំហរជាអ្នកចាស់ទុំផ្នែកនយោបាយ ដោយចង់ឲ្យមានការដោះស្រាយអហឹង្សា រវាងអ្នកនយោបាយខ្មែរ និងបណ្ដុះឲ្យមានសាមគ្គីភាពរវាងគ្នានិងគ្នា ដែលនេះជាការបញ្ជាក់ប្រាប់អតីតអ្នកតំណាងរាស្ត្រគណបក្សសម រង្ស៊ី ថា ដំណោះស្រាយ តាមរយៈការចរចាបែបសន្តិភាព និងការបន្ទន់ឥរិយាបថ ជារបៀបអ្នកចាស់ទុំផ្នែកនយោបាយ គួរប្រើដាក់គ្នាទៅវិញទៅមក «*យើងគាំទ្រចំពោះអ្នកនយោបាយដែលមានឆន្ទៈនយោបាយបង្រួបបង្រួមគ្នា សាមគ្គីភាពគ្នា ឯកភាពគ្នា ក្នុងចំណុចដែលបម្រើផលប្រយោជន៍ជាតិរបស់យើង ពីព្រោះយើងមិនចង់បង្កឲ្យមានភាពតានតឹងអ្វីទាំងអស់*»។ លោកនាយករដ្ឋមន្ត្រីហ៊ុន សែន បានថ្លែងដូចនេះ កាលពីថ្ងៃច័ន្ទ ទី១៣ ខែមិថុនា ឆ្នាំ២០១១ ក្នុងពិធីប្រគល់សញ្ញាប័ត្រដល់មន្ត្រីរាជការនៅសាលាភូមិន្ទរដ្ឋបាល។

នេះស្របពេលដែលសមាជិកសភាសហភាពអឺរ៉ុប លោកស្រី សេស៊ីល្យា វីកស្ត្រម បានស្នើរាជរដ្ឋាភិបាលកម្ពុជា ក្នុងការសំរួលឲ្យអតីតអ្នកតំណាងរាស្ត្រ សម រង្ស៊ី អាចនឹងចូលប្រទេសវិញ ដើម្បីចូលរួមក្នុងយុទ្ធនាការបោះឆ្នោតឆ្នាំ២០១២ និងឆ្នាំ២០១៣ខាងមុខនេះ ដើម្បីបង្ហាញពីភាពឈានឡើងនៃលទ្ធិប្រជាធិបតេយ្យរបស់កម្ពុជា។ មិនតែប៉ុណ្ណោះ ថែមទាំងបានសន្យាថា នឹងនាំលោក សម រង្ស៊ី ចូលមកក្នុងប្រទេសកម្ពុជាវិញ អំឡុងពេលឆាប់ៗមុនការបោះឆ្នោតសកលរបស់ប្រទេសនេះ «*វាប្រាកដច្បាស់ហើយថា ខ្ញុំនឹងធ្វើរបាយការណ៍ប្រាប់អង្គសភា ស្ដីពីគ្រោះថ្នាក់ចំពោះដំណើរការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យក្នុងប្រទេសកម្ពុជា។ ហើយនៅពេលឃោសនាបោះឆ្នោតសកល វត្តមានរបស់លោក សម រង្ស៊ី នឹងនៅក្នុងប្រទេសកម្ពុជា*»។ អ្វីដែលជាគន្លឹះនោះ គឺការដាក់សម្ពាធ ជាការយកពន្ធថ្លៃ និងព្យួរលើការនាំផលិតផលរបស់កម្ពុជាចូលទៅប្រទេសសហគមន៍អឺរុប ផ្អែកលើការរាយការណ៍ពីការ

រំលោភសិទ្ធិមនុស្ស បញ្ហាដីធ្លីនៅកម្ពុជា។

ដូចគ្នានេះដែរ អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា លោក សុរិយា ស៊ូប៊េឌី (Surya Subedi) ក្នុងបេសកកម្មរបស់គាត់រយៈពេល៥ថ្ងៃ នៅចុងខែឧសភា ឆ្នាំ២០១១ ខណៈដែលមានឱកាសសំដែងការគួរសមជាមួយនឹងប្រធានរដ្ឋសភាកម្ពុជា និងសមាជិករដ្ឋសភា បានស្នើសុំឲ្យមានការចាត់វិធានការ ធ្វើយ៉ាងណាផ្តល់ និងការពារចំពោះប្រើប្រាស់សិទ្ធិបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រឲ្យបានគ្រប់រូប និងរួមទាំងនីតិវិធីនៃការដកអភ័យឯកសិទ្ធិអ្នកតំណាងរាស្ត្រ *«វិសាលភាពសម្រាប់សមាជិកសភា ក្នុងការចូលរួមជជែកដេញដោល ត្រូវបានកម្រិត និងមានសមាជិកសភាមួយចំនួនត្រូវបានដកអភ័យឯកសិទ្ធិ សូម្បីតែការបញ្ចេញមតិអំពីបញ្ហានានាដែលជាផលប្រយោជន៍ជាតិក្តី»*។

ក្រៅពីនេះ ក៏មានសមាជិកសភាតំណាងរាស្ត្រឯករាជ្យមួយរូប ដែលមិននៅក្នុងគណបក្ស ឬក្រុមនយោបាយណាមួយ គឺលោក នីកូឡា ឌុបប៉ង់ អាង៉ាន់ (Nicolas Dupont-Aignan) បានសរសេរលិខិតទៅរដ្ឋមន្ត្រីការបរទេសបារាំង និងកិច្ចការអឺរ៉ុប លោក Alain Juppe សុំឲ្យធ្វើអន្តរាគមន៍ អតីតតំណាងរាស្ត្រ សម រង្ស៊ី ដែលកំពុងនិរទេសខ្លួនក្នុងប្រទេសបារាំងបានចូលស្រុកវិញដោយសុវត្ថិភាព *«សុំឲ្យសហភាពអឺរ៉ុប កុំព្រងើយកន្តើយចំពោះការកៀបសង្កត់ជនរងគ្រោះ ដែលជាតំណាងរាស្ត្របក្សជំទាស់ និងសុំឲ្យគេមានសិទ្ធិបំពេញការងារ ហើយមានសិទ្ធិនិយាយស្តីដូចដើម»*។

កន្លងមក សភាអឺរ៉ុបធ្លាប់បានធ្វើសេចក្តីសម្រេចចិត្តនៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០១០ ថ្កោលទោសការធ្វើទុក្ខបុកម្នេញទៅលើអតីតតំណាងរាស្ត្រ សម រង្ស៊ី និងក្រុមអ្នកជំទាស់ជាទូទៅ ហើយថា សាលក្រមរបស់តុលាការ គឺបានរារាំងដល់អតីតតំណាងរាស្ត្រនេះ មិនបានចូលរួមក្នុងការឃោសនាបោះឆ្នោតឆ្នាំ២០១៣ ហើយករណីអតីតតំណាងរាស្ត្រសម រង្ស៊ី ក៏ធ្វើឲ្យប៉ះពាល់ដល់អ្នកតំណាងរាស្ត្រប្រឆាំងដ៏ទៃទៀតក្នុងការបញ្ចេញមតិ និងធ្វើសកម្មភាពដើម្បីការពារប្រយោជន៍ប្រជាជនផងដែរ ព្រោះតែសព្វថ្ងៃនេះ ការកាត់ទោសលើការបញ្ចេញមតិរបស់តំណាងរាស្ត្រប្រឆាំង បានធ្វើឲ្យលំហនយោបាយកាន់តែតូចទៅ និងនាំទៅដល់ការធ្វើឲ្យខូចប្រយោជន៍ដល់ដំណើរលទ្ធិប្រជាធិបតេយ្យនៅកម្ពុជាផងដែរ។

## ម្ចាស់ឆ្នោតសាទរ និងការសន្យារបស់តំណាងរាស្ត្រគណបក្សកាន់អំណាច ក្នុងការដោះស្រាយបញ្ហាមគ្គុទេសក៍ជនជាតិកូរ៉េនៅស្រុកខ្មែរ

ម្ចាស់ឆ្នោត ជាមគ្គុទេសក៍ភាសាកូរ៉េ (អ្នកនាំភ្ញៀវទេសចរណ៍ដើរកំសាន្តនិយាយភាសាកូរ៉េ) បានសាទរចំពោះការសន្យារបស់អ្នកតំណាងរាស្ត្រ ដែលថានឹងធ្វើអន្តរាគមន៍ទៅក្រសួងទេសចរណ៍ ចំពោះរឿងដែលអ្នកទេសចរជនជាតិកូរ៉េយកមគ្គុទេសក៍ជនជាតិកូរ៉េខ្លួនឯង ដែលដណ្តើមការងារមគ្គុទេសក៍ជនជាតិខ្មែរ។ ទោះបីយ៉ាងណា ម្ចាស់ឆ្នោតទាំងនេះក៏កំពុងតែតាមដានការអនុវត្តន៍ការសន្យានេះដែរ។

អ្នកតំណាងរាស្ត្រ **ជាម យៀប** មកពីគណបក្សប្រជាជនកម្ពុជា មណ្ឌលព្រៃវែងថា គ្រោងនឹងកោះហៅរដ្ឋមន្ត្រីក្រសួងទេសចរណ៍មកបំភ្លឺនៅរដ្ឋសភា ពីបញ្ហាដោយសារតែជនជាតិកូរ៉េជាមគ្គុទេសក៍ភាសារកូរ៉េ បានដណ្តើមការងារមគ្គុទេសក៍ខ្មែរនិយាយភាសាកូរ៉េ ធ្វើឲ្យមគ្គុទេសក៍ខ្មែរអត់ការងារធ្វើនោះ ខាងក្រុមមគ្គុទេសក៍ខ្មែរចេះភាសាកូរ៉េបានសាទរព័ត៌មានដែលតំណាងរាស្ត្របានមើលឃើញពី ការលំបាករបស់ខ្លួន និងការជួយអន្តរាគមន៍ ខណៈក្រុមនេះកំពុងរងគ្រោះអត់ការងារធ្វើ ដែលគេមិនឲ្យតំលៃ ហើយបាក់ទឹកចិត្ត និងធ្លាក់ខ្លួនជាអ្នកកាន់ឆ័ត្រ និងស្បែកជើងឲ្យអ្នកទេសចរណ៍កូរ៉េដើរអមពីក្រោយមគ្គុទេសក៍ជនជាតិកូរ៉េទៅវិញ។ ខាងមគ្គុទេសក៍កូរ៉េជនជាតិខ្មែរ ក៏រំពឹង

ចាំមើលពីកិច្ចអន្តរាគមន៍ និងចំណាត់ការបន្តបន្ទាប់ ដើម្បីជួយសំរួលឲ្យគាត់មានការងារធ្វើ និងប្រកបដោយសេចក្តីថ្លៃថ្នូរវិញ។

អ្នកមគ្គុទេសក៍ជនជាតិខ្មែរផ្នែកភាសាកូរ៉េម្នាក់ សុំមិនបញ្ចេញឈ្មោះ បានឆ្លើយទាំងសម្លេងសប្បាយចិត្តលាយឡំនឹងការបារម្ភថា គាត់ពិតជាសប្បាយចិត្ត និងមានមោទនភាពជាខ្លាំង ដែលតំណាងរាស្ត្របានមើលឃើញពីការលំបាករបស់ពួកគាត់ ដែលកប់ជ្រៅក្នុងចិត្តអស់សង្ឃឹមយូរមកហើយ បែរជាត្រូវគាស់កកាយ រំលេចដោយតំណាងរាស្ត្រ ដើម្បីឲ្យសាធារណជនទូទៅបានដឹងឮផងដែរ «*ខ្ញុំសប្បាយចិត្តមែនទែននៅពេលឯកឧត្តមជាម យៀបមានប្រតិកម្មទៅរដ្ឋមន្ត្រី ឲ្យជួយគិតគូរដល់ពួកខ្ញុំ។ ខ្ញុំសរសើរគាត់បានដឹងពីការលំបាករបស់ប្រជាជន មានមោទនភាពពេលឃើញអ្នកដឹកនាំ(អ្នកតំណាងរាស្ត្រ)ចេះជួយសម្រាលទុក្ខលំបាករបស់ប្រជាជន។ យើងខំរៀនបានច្រើនតែគ្មានទីផ្សារនេះជាបញ្ហា។ យើងមិនសប្បាយចិត្ត ដែលមានមគ្គុទេសក៍ជនជាតិកូរ៉េ មកបកប្រែឲ្យភ្ញៀវទេសចរណ៍ជនជាតិកូរ៉េ ដែលវាធ្វើឲ្យចំណេះដឹងរបស់យើងថយចុះទៅពីមួយថ្ងៃទៅមួយថ្ងៃ។ បើផ្តល់ឱកាសឲ្យពួកយើងវិញយើងអាចនឹងព្យាយាមបកប្រែបន្តិចម្តងៗ យើងនឹងអាចប្រាប់ភ្ញៀវទេសចរណ៍ ពីអ្វីដែលប្រទេសយើងមានច្រើនជាងជនជាតិកូរ៉េ បើទោះជាភាសារ យើងនៅមានកំរិតពិសេស ជនជាតិបរទេសគេចង់ឮផ្ទាល់ពីសំដីរបស់ម្ចាស់ទឹកដីផ្ទាល់*»។

មគ្គុទេសក៍ស្រ្តី ជៀបវណ្ណារ៉ាត់ ក៏បានពោលទាំងសម្លេងសើចតិចៗបែបរំភើបថា «*សប្បាយចិត្តណាស់ និងសូមអរគុណគាត់ ចេះគិតគូរដល់ប្រជាជន ដឹងពីផលវិបាកកន្លងមក ក្រសួងធ្លាប់ប្រាប់ថា ខ្វះអ្នកចេះភាសាកូរ៉េ ត្រូវទ្រាំសិន*»។ កញ្ញាបានបន្ថែមទៀតថា កញ្ញាមានក្តីសង្ឃឹមថា តំណាងរាស្ត្រនឹងអាចជួយក្រុមមគ្គុទេសក៍ខ្មែរភាសាកូរ៉េបាន *ខ្ញុំគិតថា គាត់អាចជួយបានខ្ញុំនឹងចាំមើលលទ្ធផលនេះ*»។

ទន្ទឹមនឹងនេះ លោកសារឿម ជាមគ្គុទេសក៍មួយរូប ក៏បានលើកឡើងដែរថា ជាការប្រសើរណាស់ចំពោះការលើកឡើងរបស់អ្នកតំណាងរាស្ត្រយើង ប៉ុន្តែជាក់ស្តែងវាពិបាកនឹងធ្វើចំណាត់ការ ព្រោះដោយសារខ្មែរយើង មិនមានក្រុមហ៊ុនទេសចរណ៍ទទួលភ្ញៀវកូរ៉េធ្វើដំណើរកំសាន្តមកកម្ពុជា ទើបយើងពិបាកបញ្ជ្រាបមគ្គុទេសក៍ជនជាតិខ្មែរយើងក្នុងការនាំភ្ញៀវ «*គឺល្អថា ជនជាតិខ្មែរមានការងារធ្វើ តែជារឿងពិបាក ព្រោះថាជនជាតិកូរ៉េ គេមានក្រុមហ៊ុនគេផ្ទាល់ មានលុយច្រើនអាចទាក់ទាញទេសចរណ៍កូរ៉េបានច្រើន យើងមិនមានថូរខ្មែរផ្ទាល់ធ្វើការរឿងហ្នឹង*»។

ជាមួយគ្នានេះដែរ អ្នកមគ្គុទេសក៍បានសំណូមពរជារួមថា សូមជួយពង្រឹងវិជ្ជាជីវៈបន្ថែមដល់មគ្គុទេសក៍ខ្មែរជាមគ្គុទេសក៍ភាសាកូរ៉េ សូមបង្កើតសាលាផ្តល់ចំណេះដឹងភាសាកូរ៉េបានច្រើន និងមានបទដ្ឋានត្រឹមត្រូវ ហើយគួរមានវិជ្ជាជីវៈច្បាស់លាស់ និងសូមរាជរដ្ឋាភិបាលជួយរៀបចំយ៉ាងណាឲ្យក្រុមមគ្គុទេសក៍ខ្មែរ មានសិទ្ធិបានដើរផ្ទាល់មិនបាច់អមគេ។

ទោះបីយ៉ាងណា ខាងរដ្ឋមន្ត្រីក្រសួងទេសចរណ៍ឯកឧត្តម ថោង ខុន ធ្លាប់បានឆ្លើយតបតាមប្រព័ន្ធផ្សព្វផ្សាយថាកម្ពុជាមិនរើសអើងចំពោះជនជាតិណាមកធ្វើការរកស៊ីនៅកម្ពុជាទេ ហើយម្យ៉ាងទៀតកម្ពុជា ពិតជាខ្វះមគ្គុទេសក៍ភាសាកូរ៉េមែន ដូចនេះទើបយើងសម្រេចចិត្តឲ្យមគ្គុទេសក៍ជនជាតិកូរ៉េធ្វើការសហការជាមួយមគ្គុទេសក៍ជនជាតិខ្មែរ គឺដើម្បីធ្វើយ៉ាងណារក្សាឲ្យភ្ញៀវទេសចរកូរ៉េមកទស្សនាកម្ពុជាបានច្រើនបន្តទៀត។

## វិវាទបដិវាទក្នុងការផ្តល់អភ័យឯកសិទ្ធិ

នៅដើមឆ្នាំ២០១១នេះ មានព្រឹត្តិការណ៍សំខាន់ចំនួន២ ដែលបានកើតឡើង និងអាចមានឥទ្ធិពលអវិជ្ជមានដល់ការបំពេញតួនាទីរបស់អ្នកតំណាងរាស្ត្រ គឺការបាត់បង់អភ័យឯកសិទ្ធជាង២ឆ្នាំ (ជិតពាក់កណ្តាលអាណត្តិ) និង

ការបាត់បង់សមាជិកភាពសភា ដោយសារការបញ្ចេញមតិ និងការបំពេញតួនាទី។

អ្នកតំណាងរាស្ត្រ មូរ សុខហួរ ដែលត្រូវតុលាការកាត់ក្តីឲ្យចាញ់នាយករដ្ឋមន្ត្រី ហ៊ុន សែន ក្នុងបណ្តឹងបរិហារកេរ្តិ៍ ដែលកើតឡើងដោយការបញ្ចេញមតិបានបំពេញទោសរបស់ខ្លួន ដោយសងជម្ងឺចិត្តជាទឹកប្រាក់ប្រមាណ១៦លានរៀលដល់លោកនាយករដ្ឋមន្ត្រី និងរដ្ឋាភិបាលកាលពីចុងខែតុលា ឆ្នាំ២០១០។

អ្នកតំណាងរាស្ត្ររូបនេះ រំពឹងថាខ្លួននឹងបានអភ័យឯកសិទ្ធិសភារបស់ខ្លួនវិញ ដែលបានព្យួរជាង១ឆ្នាំ (តាំងពីខែមិថុនា ឆ្នាំ២០០៩) បន្ទាប់ពីខ្លួនបានអនុវត្តទោសរួច។

នៅដើមខែមករា ឆ្នាំ២០១១ អ្នកតំណាងរាស្ត្រ មូរ សុខហួរ បានទាមទារសភាឲ្យផ្តល់អភ័យឯកសិទ្ធសភារបស់ខ្លួនឡើងវិញ។ មុននឹងមានការឆ្លើយតបជាផ្លូវការ ថ្នាក់ដឹកនាំរដ្ឋសភា និងស្ថាប័នតុលាការ និងក្រសួងយុត្តិធម៌របស់រាជរដ្ឋាភិបាលបានថ្លែងជាសាធារណៈតាមប្រព័ន្ធផ្សព្វផ្សាយលើកដាក់គ្នា ពីអ្នកទទួលខុសត្រូវក្នុងបែបបទផ្តល់អភ័យឯកសិទ្ធិ ដល់អ្នកតំណារាស្ត្រនេះវិញ។

សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ដែលជាស្ថាប័នដឹកនាំរដ្ឋសភា អ្នកតំណាងរាស្ត្រ ជាម យៀប ត្រូវបានប្រព័ន្ធផ្សព្វផ្សាយស្រង់សម្តីថា រដ្ឋសភាជាតិត្រូវការសំណើរបស់ចៅក្រម និងក្រសួងយុត្តិធម៌ ទើបអាចរដ្ឋសភាផ្តល់អភ័យឯកសិទ្ធិឲ្យលោកស្រី មូរ សុខហួរ ហើយសាមីខ្លួនគាត់ទៅសួរតុលាការ។

ដោយឡែក រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឯកឧត្តម អង្គ វង្សវឌ្ឍនា ត្រូវបានប្រព័ន្ធផ្សព្វផ្សាយស្រង់សម្តីដែរថា «រដ្ឋសភាត្រូវសរសេរលិខិតមកក្រសួងយុត្តិធម៌ ហើយក្រសួងយុត្តិធម៌កំពុងរង់ចាំលិខិតពីរដ្ឋសភា»។

ទោះបីយ៉ាងណា លោក សុក សំអឿន ប្រធានអង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា បានត្រូវប្រព័ន្ធផ្សព្វផ្សាយស្រង់សម្តីថា «ក្រសួងយុត្តិធម៌មានសិទ្ធិ និងសមត្ថកិច្ចធ្វើលិខិតជូនដំណឹងទៅរដ្ឋសភា អំពីករណីរបស់លោកស្រីមូរ សុខហួរ»។

អ្នកតំណាងរាស្ត្រជាម យៀប ក៏បានថ្លែងដែរថា កន្លងមកដូចករណីអ្នកតំណាងរាស្ត្រ ហូរ វ៉ាន់ គឺរង់ចាំលិខិតពីក្រសួងយុត្តិធម៌។ ក្រោយមកទៀត រដ្ឋសភាក៏បានធ្វើការឆ្លើយតបជាផ្លូវការ បដិសេធសំណើផ្តល់អភ័យឯកសិទ្ធិក្រោមហេតុផលថា អ្នកតំណាងរាស្ត្រពុំទាន់បានទទួលនីតិសម្បទាពេញលេញពីតុលាការនៅឡើយ ដែលត្រូវការរយៈពេល១ឆ្នាំ បន្ទាប់ពីការអនុវត្តន៍ទោសរួចហើយ គឺនៅចុងឆ្នាំ២០១១។

អ្នកតំណាងរាស្ត្រ មូរ សុខហួរ ត្រូវបានដកអភ័យឯកសិទ្ធិកាលពីខែ មិថុនា ឆ្នាំ២០០៩ ដូច្នេះអ្នកតំណាងរាស្ត្ររូបនេះ ត្រូវបាត់បង់អភ័យឯកសិទ្ធិសភារបស់ខ្លួនជាង២ឆ្នាំ ដោយសារតែការបញ្ចេញមតិ ដែលធានាដោយរដ្ឋធម្មនុញ្ញ។

## តំណាងរាស្ត្រគណបក្សប្រឆាំង ត្រូវបានបញ្ចប់សមាជិកភាព និងបុព្វសិទ្ធិ

អ្នកតំណាងរាស្ត្រសម រង្ស៊ី បានបាត់បង់សមាជិកភាព និងបុព្វសិទ្ធិ បន្ទាប់ពីការសម្រេចរបស់តុលាការកំពូលនៅថ្ងៃទី១ ខែមីនា ឆ្នាំ២០១១ថា ឲ្យមានទោស និងឲ្យជាប់ពន្ធនាគារ ក្នុងបណ្តឹងដែលធ្វើឡើងដោយរាជរដ្ឋាភិបាលប្រឆាំងអ្នកតំណាងរាស្ត្ររូបនេះ (នៅពេលអ្នកតំណាងរាស្ត្ររូបនេះបានចុះអន្តរាគមន៍ជួយប្រជាពលរដ្ឋដែលអះអាងថា បាត់បង់ដីដោយសារការបោះបង្គោលព្រំដែនជាមួយវៀតណាម ហើយឈានទៅដល់ការដកបង្គោលតំរុយព្រំដែន) និងលិខិតរបស់ប្រធានរដ្ឋសភាចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១១ ស្តីពីការបញ្ចប់សិទ្ធិបុព្វសិទ្ធិ និងសមាជិកភាពរបស់អ្នកតំណាងរាស្ត្ររូបនេះ។

បើគ្មានការដោះស្រាយនយោបាយ ឯកឧត្តម សម រង្ស៊ីនឹងមិនមានសិទ្ធិបោះឆ្នោត និងឈរឈ្មោះឲ្យគេបោះ

ឆ្នោតឲ្យបានទេ នៅឆ្នាំបោះឆ្នោត២០១៣ខាងមុខ។

ករណីនេះនាំមកនូវវាទប្បដិវាទក្នុងនីតិកាល និងដំណើរការតាំងពីការដកអភ័យឯកសិទ្ធិការរកភស្តុតាង និងដំណើរការកាត់សេចក្ដីរបស់តុលាការ។

ការប្រើប្រាស់យន្តការតុលាការដែលត្រូវបានគេចាត់ទុកថា នៅមិនទាន់មានឯករាជ្យទាំងស្រុងប្រឆាំងនឹងអ្នកតំណាងរាស្ត្រ ដោយសារតែការបញ្ចេញមតិនឹងនាំឲ្យតួនាទីស្ថាប័នសភាក្នុងការឃ្លាំមើលរាជរដ្ឋាភិបាលនិងភាពជាតំណាង ក្នុងការការពារ ផ្ដល់ប្រយោជន៍ដល់ម្ចាស់ឆ្នោតកាន់តែខ្សោយថែមទៀត។

ក្នុងនីតិកាលទី៤នេះ អភ័យឯកសទ្ធិសភាដែលត្រូវបានផ្ដល់ឲ្យសមាជិករដ្ឋសភា ដើម្បីការពារខ្លួនក្នុងការបំពេញភារកិច្ចរបស់ខ្លួន ជាពិសេសការបញ្ចេញមតិពីការគំរាមកំហែងដោយផ្លូវច្បាប់នោះត្រូវបានមើលឃើញថា មិនមានប្រយោជន៍ទាល់តែសោះក្នុងការការពារតំណាងរាស្ត្រ។ នេះក៏ដោយសារតែមានភាពងាយស្រួលខ្លាំងពេក ក្នុងការដកអភ័យឯកសិទ្ធិសភាពីអ្នកតំណាងរាស្ត្រ។

ចាប់ពីដើមនីតិកាលទី៤ រដ្ឋសភាបានធ្វើការដកអភ័យឯកសិទ្ធិសភាពីអ្នកតំណាងរាស្ត្រចំនួន៤លើក តាមការស្នើសុំរបស់តុលាការចំនួន៤ដង ឬមានន័យថា ឲ្យតែមានការស្នើសុំដកអភ័យឯកសិទ្ធិពីតុលាការ គឺរដ្ឋសភាបានយល់ព្រមទាំងអស់។ សមាជិករដ្ឋសភានៅសល់១២២រូប តែការអនុម័តផ្សេងៗ នៅតែធៀបនឹងសមាជិកសភា ១២៣ បន្ទាប់ពីអតីតអ្នកតំណាង **សម រង្ស៊ី** ត្រូវបានដកសមាជិកភាពសភា ដោយសារប្រធានរដ្ឋសភាមកពីសមាជិកសភាសរុបកម្ពុជានៅសល់តែ១២២រូប ដោយគណបក្សសម រង្ស៊ី មិនព្រមបញ្ចូលសមាជិកថ្មីជំនួស ដែលធ្វើឲ្យអាសនៈ១ ដែលជារបស់គណបក្សសម រង្ស៊ី ត្រូវនៅទំនេរ។ ប្រការនេះ បានធ្វើឲ្យម្ចាស់ឆ្នោតខ្លះមិនច្បាស់ថា ដោយសារតែសមាជិករដ្ឋសភានៅសល់តែ១២២រូប តើការអនុម័តច្បាប់ និងពិភាក្សាធ្វើសេចក្ដីសម្រេចលើករណីផ្សេងៗ ត្រូវកំណត់ចំនួនសម្លេងអនុម័តនៃចំនួនសមាជិកសភាសរុប១២២ ឬ១២៣រូប? ក្នុងន័យនេះ គឺថាសម្លេងសំរាប់ការអនុម័តដែលត្រូវការ៥០%+១ តើថា៥០%+១នៃ១២២រូប ឬ១២៣រូប? បើបញ្ហាមិនបានពិភាក្សាដោះស្រាយឲ្យច្បាស់លាស់ វាអាចបន្តការបកស្រាយមិនច្បាស់លាស់មួយ ក្នុងករណីអ្នកតំណាងរាស្ត្រតិចជាង១២០នាក់ ដែលមាត្រា៧៦នៃរដ្ឋធម្មនុញ្ញបានចែងថា រដ្ឋសភាមានសមាជិកតំណាងរាស្ត្រយ៉ាងតិច១២០រូប។

រដ្ឋធម្មនុញ្ញកម្ពុជា មាត្រា៤៨ថ្មីបានកំណត់ចំនួនជាភាគរយច្បាស់លាស់សម្រាប់ដំណើរការប្រជុំនិងការអនុម័តផ្សេងៗនៃរដ្ឋសភា។ ដូចជាការកំណត់កូរ៉ុមប្រជុំ (ចំនួនអ្នកមានវត្តមានក្នុងពេលប្រជុំសរុប) លើសពីពាក់កណ្ដាល និងពេលខ្លះលើសពី២/៣នៃសមាជិករដ្ឋសភាសរុប។ សម្រាប់ការអនុម័តក៏ដូចគ្នាដែរ ការអនុម័តខ្លះត្រូវការ៥០%+១ ខ្លះទៀត២/៣នៃចំនួនសមាជិកសភាសរុប។

ដូចនេះបញ្ហាថា ចំនួនសមាជិកសភាសរុបត្រូវយក១២៣ កំណត់ដោយច្បាប់ ស្ដីពីការកំណត់ចំនួនអាសនៈរដ្ឋសភានីតិកាលទី៤ យកចំនួនជាក់ស្ដែងដែលសភាកំពុងមាន(១២២រូប) ព្រោះការកំណត់ចំនួនសមាជិកសភាសរុប គឺប៉ះពាល់ដល់ចំនួនកូរ៉ុម និងសម្លេងសម្រាប់ការអនុម័តផ្សេងៗ ដូចជាបើចំនួនសមាជិកសភាសរុប១២៣រូប ការអនុម័តដែលត្រូវការចំនួនមតិច្រើនដាច់ខាតនៃ៥០ភាគរយបូកមួយ គឺ៦៣សម្លេង។ ប៉ុន្តែប្រសិនបើ រដ្ឋសភាយកចំនួនគោល១២២ (ខណៈដែលអ្នកតំណាងរាស្ត្រ សម រង្ស៊ី បាត់បង់សមាជិកភាព) នោះមតិភាគច្រើនដាច់ខាតមាននៃ៥០%+១ មានចំនួនត្រឹម៦២សម្លេង។ នេះជាលក្ខខណ្ឌមួយដែលនឹងអាចប្រឈម នៅពេលដែលមតិគាំទ្រ (របៀបវារៈ) ភាគច្រើនដាច់ខាតមានចំនួនត្រឹម៦២សម្លេង។

ការសង្កេតកន្លងមកបង្ហាញថា រដ្ឋសភានៅតែរក្សាសម្លេងអនុម័ត និងចំនួនកូរ៉ុមធៀបនឹងចំនួន១២៣រូប ដែល

កំណត់ ដោយច្បាប់ស្តីពីការកំណត់ចំនួនអាសនៈរដ្ឋសភានីតិកាលទី៤ ដែលមាត្រា១បានចែងថា ចំនួនអាសនៈរដ្ឋសភានីតិកាលទី៤ ត្រូវកំណត់ត្រឹមមួយរយម្ភៃបី (១២៣)។

អ្នកតំណាងរាស្ត្រ **ជាម យៀប** ជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា និងជាតំណាងរាស្ត្រមណ្ឌលព្រៃវែងរបស់គណបក្សប្រជាជនកម្ពុជា បានពន្យល់នូវនីតិវិធីនេះថា រដ្ឋសភានៅយកកូរ៉ុម១២៣ ជាគោលនៃមតិច្រើនដាច់ខាតក្នុងការអនុម័តផ្សេងៗ ព្រោះចំនួននេះ ត្រូវបានកំណត់ពីដំបូងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនៅកម្ពុជា(គ.ជ.ប) មិនកែប្រែទេ «*ត្រូវយក១២៣ ព្រោះត្រូវយក៦៣ឡើងទៅ សមាជិករដ្ឋសភាមានចំនួនប៉ុណ្ណឹង... ព្រោះកាលបោះឆ្នោត គ.ជ.ប ទទួលស្គាល់១២៣រូបហើយ*។»

អ្នកតំណាងរាស្ត្រ **យឹម សុវណ្ណ** តំណាងរាស្ត្រមកពីមណ្ឌលភ្នំពេញគណបក្សសម រង្ស៊ី យល់ថា រដ្ឋសភាកំណត់យកចំនួនកូរ៉ុមសរុប១២៣ ដោយសារតែនេះជាចំនួនកំណត់យកតាំងពីដើមអាណត្តិដំបូងមក «*ធម្មតាគេយក១២៣ យើងយកចំនួនដែលគេប្រកាសសុពលភាពតាំងពីដើមអញ្ចឹង*»។

គណបក្សសម រង្ស៊ី ប្រកាន់ជំហរមិនដោះដូរសមាសភាពតំណាងរាស្ត្រ ជំនួសអតីតអ្នកតំណាងរាស្ត្រមណ្ឌលកំពង់ចាម លោក **សម រង្ស៊ី** ទេ ព្រោះថា គណបក្សសម រង្ស៊ី មិនទទួលស្គាល់ការកាត់ទោសរបស់តុលាការនេះទេ ដោយយល់ថា នេះជារឿងនយោបាយ មិនមែនជារឿងព្រហ្មទណ្ឌនោះទេ ហើយលោក សម រង្ស៊ី ក៏នៅតែជាតំណាងរាស្ត្រសំរាប់គណបក្សសម រង្ស៊ី និងសំរាប់ប្រជាពលរដ្ឋដែលបានបោះឆ្នោតឲ្យគាត់។ តាមមាត្រា១២០ថ្មីនៃច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បានផ្តល់សិទ្ធិដល់គណបក្សនយោបាយ អាចស្នើជ្រើសតាំងសមាជិកថ្មីជំនួសសមាជិកសភាណាដែលបាត់បង់សមាជិកភាពសភា។

## តំណាងរាស្ត្រជាស្ត្រីមិនទាន់មានក្រុមតែងតែជួបឧបសគ្គ

ការលើកកម្ពស់ស្ត្រីចូលរួមក្នុងនយោបាយ បានក្លាយជាសកម្មភាពមួយដ៏សំខាន់របស់ប្រទេសកម្ពុជា ដែលរួមមានកំណត់នៅក្នុងគោលដៅសហវត្សរ៍ការផ្តល់កូតាក្រៅផ្លូវការ ដោយរាជរដ្ឋាភិបាលសំរាប់តួនាទីរដ្ឋ និងគណបក្សមួយចំនួនមាន ចលនាស្ត្រីរបស់ខ្លួនទៀត។ តំណាងរាស្ត្រ គឺជាតួនាទីដ៏កំពូលមួយនៅក្នុងប្រទេសកម្ពុជា។ ទោះបីយ៉ាងណាអ្នកតំណាងរាស្ត្រស្ត្រីមានតិចតួចចំនួន២៦រូប (២១% នៃតំណាងរាស្ត្រសរុប១២៣រូប) បើប្រៀបធៀបនឹងចំនួនប្រជាជនជាស្ត្រីកម្ពុជាសរុបប្រមាណ៥២%។

នៅខណៈចំនួនតំណាងរាស្ត្រស្ត្រីនៅតិចតួច អ្នកតំណាងរាស្ត្រខ្លះនៅតែជួបឧបសគ្គក្នុងការបំពេញភារកិច្ចត្រូវគេគំរាមមិនឲ្យធ្វើសកម្មភាព មិនត្រូវបានលើកទឹកចិត្តដោយផ្តល់ភាពងាយស្រួល ជាពិសេសមន្ត្រីនៅមូលដ្ឋានដែលបានធ្វើការរើសអើងចំពោះអ្នកនយោបាយមកពីគណបក្សផ្សេងៗ។ ហើយអ្នកតំណាងរាស្ត្រស្ត្រីកម្ពុជានៅតែមិនអាចបង្កើតក្រុមស្ត្រី ដើម្បីការពារ និងលើកទឹកចិត្តផលប្រយោជន៍ស្ត្រីដែលពេលនេះសភាមានរយៈពេលជាង១៩ឆ្នាំហើយ ទោះបីជាថ្មីៗនេះ មានការជ្រោមជ្រែង និងលើកទឹកចិត្តពីស្ថាប័នអន្តរជាតិក៏ដោយ។ ដែលប្រទេសក្នុងតំបន់នេះ ដូចជាប្រទេសវៀតណាមបានបង្កើតឲ្យមានក្រុមស្ត្រីនេះរួមទៅហើយ។

នៅខណៈដែលខ្លួនមានចំនួនតិច ហើយមិនអាចចងជាក្រុមបាន នោះតំណាងរាស្ត្រស្ត្រីនឹងពិបាកសម្រេចការងារដើម្បីផលប្រយោជន៍របស់ខ្លួន ជាពិសេសស្ត្រី ហើយការបំពេញតួនាទីរបស់ខ្លួននឹងនៅតែបន្តជួបឧបសគ្គដោយគ្មានការដោះស្រាយ ដែលអាចបង្កឲ្យជាការបន្ទុចបង្អាក់ដល់តួនាទីស្ត្រីជាគណបក្សប្រឆាំង រារែក ភ័យខ្លាចក្នុងការបំពេញតួនាទីរបស់តំណាងរាស្ត្រស្ត្រី ជាអ្នកឃ្លាំមើលសកម្មភាពអនុវត្តច្បាប់របស់រាជរដ្ឋាភិបាល ហើយជាសញ្ញាអវិជ្ជមានសំរាប់កម្ពុជាក្នុងការលើកកំពស់សិទ្ធិស្ត្រីក្នុងវិស័យនយោបាយ។

នៅក្នុងរដ្ឋសភាកម្ពុជា បច្ចុប្បន្នមានគណបក្សតែ២ប៉ុណ្ណោះ ដែលមានតំណាងរាស្ត្រស្ត្រីតែនិន្នាការនយោបាយនៅតែជាឧបសគ្គ ដើម្បីបង្កើតក្រុមតំណាងរាស្ត្រស្ត្រីកើតឡើង។ ជាងនេះទៅទៀត អ្នកតំណាងរាស្ត្រស្ត្រីដែលមកពីបក្សផ្សេងគ្នាហាក់មិនជួយគ្នាទៅវិញទៅមក នៅពេលអ្នកតំណាងរាស្ត្រស្ត្រីជួបឧបសគ្គ។

អ្នកតំណាងរាស្ត្រ **មូរ សុខហួរ** មកពីគណបក្សសម រង្ស៊ីមណ្ឌលកំពត គឺជាអ្នកតំណាងរាស្ត្រសកម្មមួយរូបទាំងការចុះមូលដ្ឋាន និងបញ្ចេញមតិ ទោះបីយ៉ាងណា អ្នកតំណាងរាស្ត្ររូបនេះជារឿយៗត្រូវបានរើសអើងពីពេលខ្លះអ្នកតំណាងរាស្ត្រស្ត្រីមកពីគណបក្សផ្សេងៗ។ សកម្មភាពអ្នកតំណាងរាស្ត្ររូបនេះ ពេលខ្លះក៏ត្រូវបានរារាំង និងគំរាមគំហែពីអាជ្ញាធរមូលដ្ឋានដែរ។

ឧបសគ្គថ្មីៗដែលអ្នកតំណាងរាស្ត្ររូបនេះជួប គឺការប៉ុនប៉ង រារាំងការងារចុះអប់រំប្រជាពលរដ្ឋពីការពិនិត្យបញ្ជីឈ្មោះនិង ការចុះឈ្មោះបោះឆ្នោតរបស់អ្នកតំណាងរាស្ត្រ **មូរ សុខហួរ** នៅសង្កាត់ក្បាលកោះ រាជធានីភ្នំពេញ ពីសំណាក់មន្ត្រីប៉ូលិស និងចៅសង្កាត់ដោយចោទថា បានធ្វើឃោសនានយោបាយ។ ហើយកន្លងមកថ្មីៗដែរ អ្នកតំណាងរាស្ត្ររូបនេះ ក៏ត្រូវបានអាជ្ញាធរនៅតាមមូលដ្ឋាន និងជាសមាជិកគណបក្សប្រជាជនបំភិតបំភ័យដោយប្រើពាក្យសំដីគំរាម តាមយាយីអ្នករួមដំណើរជាមួយនឹងអ្នកតំណាងរាស្ត្ររូបនេះ ខណៈដែលអ្នកតំណាងរាស្ត្ររូបនេះបានចុះជួបប្រជាពលរដ្ឋក្នុងការអប់រំអ្នកស្រុកពីសិទ្ធិទទួលបានការថែរក្សាសុខភាព នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១១នៅក្រុងបាត់ដំបង។

អ្នកតំណាងរាស្ត្រ **មូរ សុខហួរ** មានប្រសាសន៍ថា វាប៉ះពាល់សិទ្ធិជាតំណាងរាស្ត្រក្នុងការបំពេញតួនាទី និងសុវត្ថិភាព ហើយជារឿងបង្កដោយចេតនានយោបាយ «*វារំលោភដល់សិទ្ធិជាតំណាងរាស្ត្រ វាជារឿងគណបក្សប្រជាជនគាត់ថា ជាមន្ត្រីមកពីគណបក្សប្រជាជន...ប្រជាជននឹងមិនហ៊ានមកជួបមីង ប៉ះពាល់សិទ្ធិប្រជាជន ប៉ះពាល់ដល់សុវត្ថិភាពរបស់មីង*» ។

ទោះបីយ៉ាងណា ផលវិបាកទាំងនេះហាក់បីដូចជា មិនត្រូវបានទទួលស្គាល់ដោយតំណាងរាស្ត្រស្ត្រីមកពីគណបក្សកាន់អំណាច អ្នកតំណាងរាស្ត្រ **ឃួន សុដារី** ជាតំណារាស្ត្រស្ត្រីមណ្ឌលកណ្តាល មកពីគណបក្សប្រជាជនកម្ពុជាបានមានប្រសាសន៍ថា រឿងដែលបានកើតឡើងខាងលើចំពោះអ្នកតំណាងរាស្ត្រ មូរ សុខហួរ នេះជារឿងមិនពិត។

ក្រៅពីកត្តានិន្នាការនយោបាយ អាចមានកត្តានៃការបែងចែកតួនាទីឲ្យមានសមធម៌ នៅក្នុងក្រុមតំណាងរាស្ត្រស្ត្រីដែលត្រូវបង្កើត។ មិនមែនមិនមានករណីដែលអ្នកតំណាងរាស្ត្រស្ត្រីមកពីគណបក្សផ្សេងៗគ្នា ចុះមូលដ្ឋានរួមគ្នានោះទេ វាមាន ក៏ប៉ុន្តែ គឺមានតិចតួច។ អ្នកតំណាងរាស្ត្រស្ត្រី **ឃួន សុដារី** បានចាប់អារម្មណ៍ចំពោះការបង្កើតក្រុមស្ត្រីនៅរដ្ឋសភាកម្ពុជាថា ជាការលំបាកក្នុងការបង្កើតឲ្យមានក្រុមស្ត្រីនេះណាស់ ព្រោះទាមទារឲ្យមានឆន្ទៈចូលរួមពីក្រុមស្ត្រីមកពីគណបក្សប្រឆាំងផងដែរ «*ចង់ចងក្រងក្រុមស្ត្រីដែរ តែអត់មានស្ត្រីគណបក្សប្រឆាំងចូលរួម ពិបាកហៅចូលណាស់...ហើយក៏មិនអាចអត្តនោម័តទេ [ដើម្បីបង្កើតក្រុមស្ត្រីរបស់រដ្ឋសភានេះ] ព្រោះត្រូវការប្រជុំអនុម័តពិភាក្សា*»។

ជាមួយនេះដែរ អ្នកតំណាងរាស្ត្រ **កែ សុវណ្ណរតន៍** មកពីគណបក្សសម រង្ស៊ី ធ្លាប់បានលើកឡើងថា «*គ្មានតម្លាភាព [ក្នុងការបែងចែកតួនាទីក្នុងក្រុមស្ត្រីរបស់រដ្ឋសភា]។ [ឧទាហរណ៍] ខ្ញុំធ្លាប់បានចូលរួមជាមួយក្រុមស្ត្រីគណៈកម្មការតាមខេត្តមួយចំនួនទៅចែកអំណោយ។ ធ្វើសន្ទរកថាឱ្យប្រធានក្រុមមានសិទ្ធិនិយាយ។ ប្រធានមកពីគណបក្សកាន់អំណាចទៀត ហើយយើងទៅបានអង្គុយល្ហមើលការចាត់ចែងមិនស្មើភាព។*»

ទាំងអ្នកតំណាងរាស្ត្រស្ត្រីកាន់អំណាច និងប្រឆាំង សុទ្ធតែចង់បង្កើតក្រុមស្ត្រី ក៏ប៉ុន្តែសុទ្ធតែមើលឃើញថា និន្នាការខុសគ្នា គឺជាឧបសគ្គដ៏ធំ។ ដូចនេះការចង់បង្កើតក្រុមតំណាងរាស្ត្រស្ត្រីបាន គឺវាពឹងផ្អែកទៅលើឆន្ទៈរបស់តំណាងរាស្ត្រស្ត្រីផ្ទាល់ ដែលយកបញ្ហាស្ត្រីដាក់លើនិន្នាការនយោបាយរបស់គណបក្សដែលគ្រប់គ្រងដោយបុរសៗ។ ជាមួយគ្នាដែរ ច្បាប់បោះឆ្នោតដែលកំណត់សមាជិកភាពតំណាងរាស្ត្រ ត្រូវបាត់បង់នៅពេលបាត់បង់សមាជិកភាពពីគណបក្ស គួរលុបដើម្បីផ្តល់អំណាចតំណាងរាស្ត្រក្នុងការតស៊ូមតិជាមួយនគណបក្ស។

## សង្ខេបព្រឹត្តិការណ៍ប្រជុំសភាអាស៊ាន (AIPA)ដែលរដ្ឋសភាកម្ពុជាជាម្ចាស់ផ្ទះ

កិច្ចប្រជុំសភាអាស៊ាន ដែលធ្វើឡើងក្នុងប្រធានបទ «តួនាទីអាយប៉ា ក្នុងការកសាងសហគមន៍អាស៊ានមួយប្រកបដោយវិបុលភាព» បានធ្វើឡើងក្នុងរយៈ៧ថ្ងៃ នៅវិមានសន្តិភាពនៃគណៈរដ្ឋមន្ត្រី។ ការប្រជុំនេះដើម្បីដោះស្រាយបញ្ហាផ្សេងៗ ក្នុងតំបន់រួមគ្នារបស់ប្រទេសជាសមាជិកអាស៊ាន និងគោលដៅដើម្បីបង្កើតសហគមន៍អាស៊ានដើម្បីរកឲ្យបាននូវដោះស្រាយដែលមានស្ថេរភាពមួយ។ សន្និបាតនេះ មានការចូលរួមពីសមាជិកសភាមកពីប្រទេសជាសមាជិកអាស៊ាន និងប្រទេសអង្កេតផ្សេងៗទៀត ដូចជាជប៉ុន សភាអឺរ៉ុប ប្រទេសអូស្ត្រាលី កាណាដា ចិន ឥណ្ឌា និងរុស្ស៊ី ហើយក្នុងនោះដែរ កម្ពុជាជាប្រធានអាយប៉ាលើទី៣២។ ក្នុងនោះសង្កេតឃើញដែរថា មានតំណាងរាស្ត្រមកតែ៣គណបក្សប៉ុណ្ណោះ ដែលបានចូលរួមក្នុងការប្រជុំសភាអាស៊ាន គឺគណបក្សប្រជាជនកម្ពុជា គណបក្សសម រង្ស៊ី និងគណបក្សសិទ្ធិមនុស្សជាសមាជិក និងប្រធានគណៈកម្មការនៃកិច្ចប្រជុំអាយប៉ា។

លទ្ធផលនៃការប្រជុំសភាអាយប៉ាលើកទី៣២នេះ គឺបានសំរេចលើការព្រាងលើដំណោះស្រាយប្រកបដោយចេរភាពនូវបញ្ហាប្រឈមថ្មី និងបានឯកភាពលើរបាយការណ៍មួយចំនួន ដែលបំពេញរយៈពេលមួយឆ្នាំដែលកម្ពុជាជាប្រធានអាយប៉ា និងបានអនុម័តសេចក្តីសំរេចចំនួន២៥ចំណុច ដែលមានដូចជាសន្តិសុខ នយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌ បញ្ហាប្រជាជន និងការអភិវឌ្ឍន៍ដោយចេរភាព បញ្ហាបរិស្ថាន ការគ្រប់គ្រងធនធានទឹក ការគ្រប់គ្រងគ្រោះមហន្តរាយ ជំងឺឆ្លងនានា គ្រោះថ្នាក់ដោយសារគ្រាប់មីន និងផ្លាស់ប្តូរបទពិសោធន៍ ព្រមទាំងកិច្ចសហប្រតិបត្តិការជាមួយប្រទេសសង្កេតការណ៍ និងសេចក្តីថ្លែងការណ៍រួម។

តាមសំដីអ្នកតំណាងរាស្ត្រ **ឈាង វុន** ជាប្រធាននៃកិច្ចពិភាក្សាគណៈកម្មការ បានមានប្រសាសន៍ថា កិច្ចពិភាក្សានេះនឹងជំរុញធ្វើឲ្យកម្ពុជាកសាងសមត្ថភាព ដើម្បីធ្វើសមាហរណកម្មសេចក្តីចូលអាស៊ាន និងពិភាក្សាពីការត្រៀមខ្លួនរបស់អាស៊ានសំរាប់សំរបនឹងបំរែបំរួលបរិស្ថាន *«ដើម្បីឲ្យអាស៊ានថ្មី គឺវៀតណាម ឡាវ កម្ពុជា អាចធ្វើសមាហរណកម្មសេចក្តីខ្លួនទៅក្នុងអាស៊ានបាន ដើម្បីត្រៀមខ្លួនរៀបចំរួមចំណែកកសាងសហគមន៍អាស៊ាននៅឆ្នាំ២០១៥។ ចំណុចមួយទៀតឲ្យយល់ថា បរិស្ថានវាខូចខាតទាំងមូល ពិសេសមូលហេតុមកពីប្រទេសឧស្សាហកម្មធំៗ កុំឲ្យមានការចោទគ្នាមកពីប្រទេសតូច កាប់ព្រៃឈើ ឬប្រទេសធំៗបញ្ចេញឧស្ម័ន ហើយបញ្ហានេះជាបញ្ហាធំ យើងទទួលស្គាល់បញ្ហា យើងត្រូវយកចិត្តទុកដាក់ថា តើបរិស្ថានខូចហើយនេះ តើយើងត្រូវបន្សាំខ្លួនយើងដែលជាពលរដ្ឋរបស់អាស៊ានត្រូវធ្វើយ៉ាងមេច។»*

ថវិកាសំរាប់ចំណាយលើការចំណាយទូទៅ លើការរៀបចំធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំអាយប៉ានេះចំនួន១,៣លានដុល្លារអាមេរិកផ្តល់ដោយរាជរដ្ឋាភិបាល ដែលគម្រោងស្នើរបស់រដ្ឋសភាមានចំនួន១,៩លានដុល្លារ។ កន្លងមកមានការរិះគន់ពីតំណាងរាស្ត្រមកពីគណបក្សប្រឆាំងថា ការចំណាយនេះមានលក្ខណៈខ្ជះខ្ជាយ និងសកម្មភាពជំរុញឲ្យមានដោះស្រាយបញ្ហាមួយចំនួន អាយប៉ានៅមិនទាន់បានបំពេញតួនាទីឲ្យប្រសិទ្ធិភាពនៅឡើយទេ និងថា ការរៀបចំនេះ គឺគ្រាន់តែដើម្បីលើកំពស់មុខមាត់គណបក្សកាន់អំណាចប៉ុណ្ណោះ។ អ្នកតំណាងរាស្ត្រ **សុន ឆ័យ** បាន

មានប្រសាន៍ថា *«កិច្ចប្រជុំ AIPAនេះ តាមកម្មវិធីរៀបចំ គឺគ្រាន់តែជាការរៀបចំដើម្បីឲ្យអ្នកមកចូលរួមទទួលបានការធ្វើដំណើរកម្សាន្ត គឺអស់ទឹកប្រាក់ច្រើនណាស់។»*

សភាអាយប៉ា (AIPA) ដែលមានប្រទេសចំនួន១០នោះ បានវិវត្តពីឈ្មោះសម្ព័ន្ធភាពរបស់សមាគមអន្តរសភា (AIPO) បានបង្កើតឡើងតាំងពីឆ្នាំ១៩៧០ ដែលមានប្រទេសសមាជិកអាស៊ានចំនួន៥ ដូចជាប្រទេសឥណ្ឌូនេស៊ី ហ្វីលីពីន ម៉ាឡេស៊ី សិង្ហបុរី ថៃជាស្ថាបនិក ដែលក្នុងនោះសភាប្រទេសឥណ្ឌូនេស៊ី ជាប្រទេសផ្តួចផ្តើមគំនិត។ ហើយកម្ពុជាចូលជាសមាជិកអន្តរសភា(អាយប៉ា) តាំងពី១៩៩៩។ គោលបំណងនៃអន្តរសភាអាស៊ាននេះ គឺដើម្បីប្រតិបត្តិការលើការអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ក្នុងតំបន់ តាមរយៈកម្មវិធីនៃការសហប្រតិបត្តិការផ្សេងៗ ដើម្បីការពារស្ថេរភាពនយោបាយ និងសេដ្ឋកិច្ចក្នុងតំបន់ ប្រឆាំងនឹងការប្រកួតប្រជែងពីមហាអំណាច ហើយក៏ជាវេទិកាមួយដើម្បីធ្វើសេចក្តីសំរេចចិត្តចំពោះបញ្ហាផ្សេងៗក្នុងតំបន់។ រាល់ការប្រជុំរបស់អន្តរសភាអាស៊ានហៅកាត់ថា អាយប៉ានេះ គឺតែងតែមានការចូលរួមពីខាងគណៈប្រតិភូអង្កេតការណ៍ជាប្រទេសជាដៃគូផងដែរ។

## តំណាងរាស្ត្រគណបក្សប្រឆាំង នៅតែពិបាកសួរដេញដោល ក្នុងការឆ្លើយបំភ្លឺក្នុងសភា

នៅថ្ងៃព្រហស្បតិ៍ទី០៩ ខែសីហា ឆ្នាំ២០១២នេះ រដ្ឋសភាបានបន្តសម័យប្រជុំរបស់ខ្លួនដែលបានអញ្ជើញលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន មកឆ្លើយបំភ្លឺអំពីការងារបោះបង្គោលព្រំដែន រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលជាការឆ្លើយតបនឹងលិខិតរបស់លោក សុន ឆ័យ អ្នកតំណាងរាស្ត្រគណបក្សសម រង្ស៊ីមណ្ឌលភ្នំពេញ។

ក្នុងការមកឆ្លើយបំភ្លឺរបស់លោកនាយករដ្ឋមន្ត្រីនៅក្នុងរដ្ឋសភា ត្រូវបានប្រធានរដ្ឋសភាបានប្រកាសក្នុងអង្គប្រជុំ ដោយមិនអនុញ្ញាតឲ្យអ្នកតំណាងរាស្ត្រមានការសួរដេញដោល ជាសំណួរទៅប្រមុខរាជរដ្ឋាភិបាល ដោយគ្រាន់តែអនុញ្ញាតឲ្យប្រមុខរាជរដ្ឋាភិបាលនិយាយឆ្លើយតបនឹងសំណួរ ដែលអ្នកតំណាងរាស្ត្របានសួរនៅពេលដាក់លិខិតប៉ុណ្ណោះ ពីបញ្ហាបោះបង្គោលព្រំដែន រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម។

ការមិនឲ្យសួរដេញដោលនេះ មិនមែនជាលើកទីមួយទេ ដែលរដ្ឋសភាមិនឱ្យអ្នកតំណាងរាស្ត្រគណបក្សប្រឆាំង ក្នុងការសួរដេញដោលកន្លងទៅអ្នកតំណាងរាស្ត្រ សុន ឆ័យ គណបក្សសម រង្ស៊ីបានដាក់លិខិតទៅរដ្ឋមន្ត្រីក្រសួងការងារឲ្យមកឆ្លើយបំភ្លឺនៅក្នុងរដ្ឋសភា ពីបញ្ហាមួយចំនួនពាក់ពន្ធ័នឹងការតំលើងប្រាក់ខែរបស់កម្មករ ក៏ត្រូវបានប្រធានអង្គប្រជុំរដ្ឋសភាប្រកាសហាមមិនឱ្យមានការដាក់ជាសំណួរ ឬសួរដេញដោលពីសំណាក់តំណាងរាស្ត្រគណបក្សប្រឆាំងដែលជាម្ចាស់សំណួរ។

តាមប្រការ៣២ បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាបានចែងថា *«ចំពោះចម្លើយផ្ទាល់មាត់ ប្រធានរដ្ឋសភាអាចសម្រេចបើកឲ្យមាន ឬមិនឲ្យមានការជជែកដេញដោល។ បើគ្មានការបើកឲ្យជជែកដេញដោលទេ នោះចម្លើយរបស់រដ្ឋមន្ត្រី ឬរបស់នាយករដ្ឋមន្ត្រីនឹងបញ្ចប់សំណួរតែម្តង។»*

បើមើលក្នុងមាត្រា៩៦នៃរដ្ឋធម្មនុញ្ញ ក៏ដូចគ្នាទៅនឹងប្រការ៣២ បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ដែលបានចែងខាងលើថា ចំពោះចម្លើយផ្ទាល់មាត់ប្រធានរដ្ឋសភាអាចសម្រេចបើកឲ្យមាន ឬមិនឲ្យមានការជជែកសួរដេញដោលចំពោះក្នុងប្រការនេះដែរ យើងឃើញថា វាហាក់ដូចជាអយុត្តិធម៌ចំពោះអ្នកតំណាងរាស្ត្រគណបក្សប្រឆាំងដែលជាម្ចាស់សំណួរ បែរជាមិនអាចសួរដេញដោលបាន ដោយរដ្ឋសភាគួរតែផ្តល់សិទ្ធិទៅឲ្យអ្នកតំណាងរាស្ត្រដែលជាម្ចាស់សំណួរអាចអានសំណួររបស់ខ្លួន ដោយអាចឲ្យប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោតដឹងពីសំណួរដែលសួរទៅរាជរដ្ឋាភិបាល និងដើម្បីឱ្យដឹងថា ការឆ្លើយរបស់រាជរដ្ឋាភិបាលត្រូវនឹងអ្វីដែលម្ចាស់សំណួរសួរដែរឬទេ?។

អ្នកតំណាងរាស្ត្រ សុន ឆ័យ គណបក្សសម រង្ស៊ី មណ្ឌលភ្នំពេញបានមានប្រសាសន៍ថា *«រដ្ឋាភិបាលហាក់ដូចជាមិនមានសេចក្តីក្លាហាន ក្នុងការបំភ្លឺពីបញ្ហាជាតិដ៏សំខាន់នេះទេ បើសិនគាត់បង្ហាញការពិតចំពោះបញ្ហាព្រំដែនជាសំណួរហ្នឹង គាត់មិនត្រូវហាមគេមិនឱ្យសួរទេ ដើម្បីបញ្ជាក់ថាចម្លើយរបស់គាត់ហ្នឹងវាត្រូវមិនត្រូវអី ត្រូវមានការសួរបញ្ជាក់អីថែមឃើញថា រដ្ឋាភិបាលដូចមានល័ក្ខខ័ណ្ឌកំបាំងអីដូចមិនមានច្បាស់លាស់ខ្លួនឯងទេ ក្នុងការឆ្លើយបំភ្លឺជាមួយនឹងអ្នកតំណាងរាស្ត្រ»*។

អ្នកតំណាងរាស្ត្រ ជាម យៀប គណបក្សប្រជាជនកម្ពុជាមណ្ឌលព្រៃវែង បានមានប្រសាសន៍ក្នុងអង្គប្រជុំរដ្ឋសភាថា *«...យោងតាមជំពូកទី៧មាត្រា៩៦ ក៏ដូចប្រការ៣២នៃបទបញ្ជាផ្ទៃក្នុង គឺបានបញ្ជាក់ច្បាស់ណាស់ ឯកឧត្តមយកទៅមើលឡើងវិញ អ្វីក្នុងនោះខ្ញុំលើកក្នុងវាក្យខ័ណ្ឌចុងក្រោយ ចំពោះចម្លើយផ្ទាល់មាត់ ប្រធានរដ្ឋសភាអាចសម្រេចបើកអោយមាន ឬមិនអោយមានការជជែកដេញដោល បើគ្មានការជជែកដេញដោលទេ នោះចម្លើយរបស់រដ្ឋមន្ត្រី ឬរបស់នាយករដ្ឋមន្ត្រីនឹងបញ្ចប់សំណួរតែម្តង មិនមានអ្វីក្រៅពីហ្នឹងទេ និងជាឆន្ទានុសិទ្ធិរបស់ប្រធានរដ្ឋសភាមិនមែនការបិទសិទ្ធិទាំងអស់ទេ»*។

## រដ្ឋសភាផ្តល់អភ័យឯកសិទ្ធិជូនលោកស្រី មូរ សុខហួរ អ្នកតំណាងរាស្ត្រគណបក្សសម រង្ស៊ី

ក្នុងថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១២នេះ រដ្ឋសភាជាតិបានសម្រេចផ្តល់អភ័យឯកសិទ្ធិជូនអ្នកតំណាងរាស្ត្រ មូរ សុខហួរ គណបក្សសម រង្ស៊ី មណ្ឌលកំពត ឲ្យមានអភ័យឯកសិទ្ធិជាអ្នកតំណាងរាស្ត្រពេញលេញ បន្ទាប់ពីសាលាឧទ្ធរណ៍រាជធានីភ្នំពេញបានផ្តល់នីតិសម្បទារួចមក។ ដែលសម្រេចថា លោកស្រីបានបំពេញកាតព្វកិច្ចចប់សព្វគ្រប់តាមការបង្គាប់ដីកាតុលាការ។

តាមមាត្រា១៦ នៃច្បាប់ ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ *«តំណាងរាស្ត្រណាដែលមានសាលក្រមស្ថាពរ ឬសាលដីកាស្ថាពរសម្រេចថា ជាជនគ្មានទោសតំណាងរាស្ត្រនោះត្រូវបានទទួលជាស្វ័យប្រវត្តិនូវអភ័យឯកសិទ្ធិ និងបុព្វសិទ្ធិពេញលេញឡើងវិញ»*។

គួរបញ្ជាក់ផងដែរថា អ្នកតំណាងរាស្ត្រមូរ សុខហួរ មណ្ឌលកំពតគណបក្សសម រង្ស៊ី កន្លងទៅ ត្រូវបានសមាជិករដ្ឋសភាសម្រេចបោះឆ្នោតអនុម័តដោយមានសំលេង៩១/៩១ ដើម្បីដកអភ័យឯកសិទ្ធិសភាជាអ្នកតំណាងរាស្ត្រ កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩។ ក្នុងករណីដែលលោកស្រីមានការប្តឹងផ្តល់ជាមួយលោកនាយករដ្ឋមន្ត្រីហ៊ុន សែន ពីបទបរិហារកេរ្តិ៍ ដែលកើតចេញពីការអត្ថាធិប្បាយដោយប្រយោលរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅខេត្តកំពត កាលពីដើមខែមេសា ឆ្នាំ២០០៩កន្លងទៅ ទាក់ទងទៅនឹងពាក្យថា «ស្ត្រីម្នាក់ជើងខ្លាំងហើយ លោកស្រី មូរ សុខហួរ បានចាត់ទុកថា គឺសំដៅមកលើលោកស្រី។ អ្នកតំណាងរាស្ត្រ មូរ សុខហួរ ត្រូវបានតុលាការកាត់ក្តីសម្រេចឲ្យលោកស្រីចាញ់ក្តីលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដោយតំរូវឲ្យបង់ប្រាក់ចំនួន៨,០០០ដុល្លារ។

តាមការលើកឡើងរបស់អ្នកតំណាងរាស្ត្រ មូរ សុខហួរ គណបក្សសម រង្ស៊ី បានបញ្ជាក់ថា រដ្ឋសភាបានផ្តល់អភ័យឯកសិទ្ធិជូនលោកស្រី ហើយការផ្តល់អភ័យឯកសិទ្ធិនោះ រដ្ឋសភាមិនបានជម្រាបប្រាប់លោកស្រីជាមុនទេ ដោយរដ្ឋសភាមានការប្រជុំគណៈកម្មការអចិន្ត្រៃយ៍ជាសម្ងាត់។ លោកស្រីបានបន្តទៀតថា រដ្ឋសភាបានផ្តល់លិខិតមួយច្បាប់ដែលចុះហត្ថលេខាពីសម្តេច ហេង សំរិន ប្រធានរដ្ឋសភា។

## អ្នកតំណាងរាស្ត្រតែងជួបផលវិបាកក្នុងការទទួលអភ័យឯកសិទ្ធិពីប្រព័ន្ធតុលាការ

អ្នកតំណាងរាស្ត្រ **មូរ សុខហួរ** មកពីមណ្ឌលកំពតគណបក្ស សម រង្ស៊ី ត្រូវបានរដ្ឋសភាដកអភ័យឯកសិទ្ធិកាលពីពាក់កណ្តាលខែមេសា ឆ្នាំ២០០៩ នៅពេលលោកស្រី មានរឿងប្តឹងផ្តល់ជាមួយសម្តេច នាយករដ្ឋមន្ត្រី ហ៊ុន

សែន។ នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០១២ អ្នកតំណាងរាស្ត្រគណបក្សប្រឆាំងមកពីមណ្ឌលកំពត លោកស្រី មូរ សុខហួរ បានដាក់ឯកសារពាក់ព័ន្ធនានាទៅកាន់សាលាដំបូងរាជធានីភ្នំពេញ សុំឲ្យតុលាការផ្តល់នូវនីតិសម្បទា ដើម្បីទទួលអភ័យឯកសិទ្ធិជាអ្នកតំណាងរាស្ត្រមកវិញ។ ប៉ុន្តែក្នុងករណីសុំនីតិសម្បទានេះ ត្រូវបានតុលាការក្រុងភ្នំពេញបានបដិសេធ មិនព្រមទទួលយកលិខិតស្នើសុំរបស់អ្នកតំណាងរាស្ត្រ មូរ សុខហួរ។

លោក **សុខ រឿន** ព្រះរាជអាជ្ញារងនៃតុលាការក្រុងភ្នំពេញបាននិយាយថា ពាក្យស្នើសុំពុំមានឯកសារគ្រប់គ្រាន់ទេ ទើបតុលាការសម្រេចមិនទទួលយក។ លោកសុខរឿនបន្តទៀតថា *«ក្នុងពាក្យសុំហ្នឹង គាត់ដាក់មានយោង ហើយនិងមានឯកសារពាក់ព័ន្ធ ហើយដល់អញ្ចឹងខាងរដ្ឋបាលគាត់ថា លិខិតដែលដាក់នោះ មានឯកសារយោងនិងមានឯកសារពាក់ព័ន្ធហ្នឹងតែវាឥតឃើញ។ មន្ត្រីដែលកាន់មកហ្នឹងថា ឥតបានដាក់មកអញ្ចឹងគេសុំយកបណ្តឹងនោះទៅវិញ ដើម្បីប្រមូលឯកសារយោងពាក់ព័ន្ធនឹងលិខិតពាក្យសុំហ្នឹងណា»*។

អ្នកតំណាងរាស្ត្រ **មូរ សុខហួរ** នៅមិនទាន់បានអភ័យឯកសិទ្ធិពីរដ្ឋសភានៅឡើយទេ មកដល់ពេលនេះ ដោយរដ្ឋសភាមិនទាន់ទទួលលិខិតពីតុលាការក្នុងការឲ្យរដ្ឋសភាផ្តល់អភ័យឯកសិទ្ធិ។

ចំណែកអ្នកតំណាងរាស្ត្រ **ជាម យៀប** មណ្ឌលព្រៃវែង មកពីគណបក្សប្រជាជនកម្ពុជាមានប្រសាសន៍ថា « *តាមកន្លងទៅយើងឃើញថា បើគេអនុវត្តហើយ ហើយគេស្នើសុំដូចនេះ តុលាការគួរតែជម្រាបប្រាប់មករដ្ឋសភាវិញ ដើម្បីឲ្យសភាហ្នឹងបានដឹងថា គេអនុវត្ត ហើយគេមាននីតិសម្បទាគ្រប់គ្រាន់ឡើងវិញ»*។

## អ្នកតំណាងរាស្ត្រគណបក្សសម រង្ស៊ី ចោទនាយករដ្ឋមន្ត្រី និងនីតិប្រតិបត្តិរំលោភរដ្ឋធម្មនុញ្ញ

នៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១២ អ្នកតំណាងរាស្ត្រគណបក្សសម រង្ស៊ី បានចោទប្រកាន់ថា នាយករដ្ឋមន្ត្រី ហ៊ុន សែន បានរំលោភរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា គេចមិនចូលខ្លួនមកឆ្លើយបំភ្លឺចំពោះមុខរដ្ឋសភា។ អ្នកតំណាងរាស្ត្រគណបក្សសម រង្ស៊ី ក៏បានចោទប្រកាន់ទៅលើ ប្រធានរដ្ឋសភាថា មិនបានបញ្ជូនសំណួរសមាជិកសភារបស់ខ្លួន ដែលស្នើកោះហៅនាយករដ្ឋមន្ត្រី និងនីតិប្រតិបត្តិទៅឆ្លើយបំភ្លឺក្នុងរដ្ឋសភា។

អ្នកតំណាងរាស្ត្រ សុន ឆ័យ មណ្ឌលភ្នំពេញគណបក្សសម រង្ស៊ី បានចោទប្រកាន់នាយករដ្ឋមន្ត្រីថា បានរំលោភរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដោយមូលហេតុមិនចូលខ្លួនមកបំភ្លឺនៅក្នុងរដ្ឋសភា។ អ្នកតំណាងរាស្ត្រ សុន ឆ័យ បានដាក់លិខិតជាផ្លូវការទៅប្រមុខរាជរដ្ឋាភិបាល ស្នើសុំឱ្យមកបំភ្លឺពន្យល់ពីកិច្ចប្រជុំអាស៊ាន ស្តីអំពីវិនាសកម្មព្រៃឈើ និងបញ្ហាផ្សេងៗទៀតដែលមានកើតឡើងក្នុងប្រទេសកម្ពុជា។

អ្នកតំណាងរាស្ត្រ សុន ឆ័យ មណ្ឌលភ្នំពេញគណបក្សសម រង្ស៊ី បានមានប្រសាសន៍ថា *«តួនាទីរបស់រដ្ឋាភិបាល គឺត្រូវតែមកឆ្លើយចំពោះសំណួររបស់អ្នកតំណាងរាស្ត្រ ហើយពេលអ្នកតំណាងរាស្ត្រហៅមកឆ្លើយនៅសភា ត្រូវមកឆ្លើយ ហើយមាត្រា៩៦ ដែលបានចែងហ្នឹង ហើយឥឡូវហ្នឹងយើងហៅគាត់ៗអត់មក ហើយយើងសួរសំណួរគាត់ក៏គេមិនឆ្លើយ អាហ្នឹង គឺរំលោភរដ្ឋធម្មនុញ្ញ »*។

បើតាមការសម្ភាសន៍របស់វិទ្យុអាស៊ីសេរី ទៅអ្នកតំណាងរាស្ត្រ សុន ឆ័យ បានឱ្យដឹងថា ក្នុងអំឡុងឆ្នាំ២០១១ ក្នុងចំណោមលិខិត ឬសំណើរបស់សមាជិកបក្សប្រឆាំង ដែលបានស្នើឲ្យនាយករដ្ឋមន្ត្រី ហ៊ុន សែនឆ្លើយបំភ្លឺលើបញ្ហាជាតិធំៗជាង១៥០ករណី ដែលមានការឆ្លើយបំភ្លឺមិនបាន៥០ភាគរយផង ជាពិសេសការឆ្លើយតបមានការយឺតយ៉ាវ មិនស្របតាមរដ្ឋធម្មនុញ្ញនោះទេ។

អ្នកតំណាងរាស្ត្រ ជាម យៀប មណ្ឌលព្រៃវែង មកពីគណបក្សប្រជាជនកម្ពុជាបានប្រសាសន៍ថា « *តាមច្បាប់*

*រដ្ឋធម្មនុញ្ញបានចែងថា តំណាងរាស្ត្រដាក់សំណួរទៅរដ្ឋាភិបាលត្រូវសរសេរជាលាយលក្ខណ៍អក្សរ ប្រគល់ជូនតាមរយៈប្រធានរដ្ឋសភា ហើយតាមបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ចម្លើយរបស់រដ្ឋមន្ត្រី ឬរបស់នាយករដ្ឋមន្ត្រីអាចធ្វើដោយផ្ទាល់មាត់ ឬសរសេរជាលាយលក្ខណ៍អក្សរ នៅពេលដែលនាយករដ្ឋមន្ត្រីមានការមមាញឹក និងជាប់រវល់ អាចពន្យារពេលក្នុងការឆ្លើយតប ហើយអ្វីដែលលោក សុន ឆ័យ លើកឡើងនោះ គឺវប្បធម៌របស់គណបក្សនាំងដែលតែងតែប្រឆាំងនឹងរដ្ឋាភិបាល»។*

ចំណែកលោក ផៃ ស៊ីផាន រដ្ឋលេខាធិការ និងជាមន្ត្រីនាំពាក្យទីស្ដីការគណៈរដ្ឋមន្ត្រី បានឆ្លើយតបក្នុងវិទ្យុអាស៊ីសេរីថា ប្រមុខដឹកនាំរដ្ឋាភិបាលសព្វថ្ងៃមិនធ្វេសប្រហែសចំពោះលិខិត ឬសំណើបក្សប្រឆាំងទេ។ លោកបន្តថាមានសំណើមន្ត្រីបក្សប្រឆាំងជាង៩០ភាគរយ ត្រូវបានប្រមុខដឹកនាំបកស្រាយក្នុងអាណត្តិទី៤នៃរដ្ឋសភា។

តាមមាត្រា៩៦នៃច្បាប់រដ្ឋធម្មនុញ្ញបានចែងថា «តំណាងរាស្ត្រមានសិទ្ធិដាក់សំណួរដល់រាជរដ្ឋាភិបាល។ សំណួរនេះត្រូវសរសេរជាលាយលក្ខណ៍អក្សរប្រគល់ជូន តាមរយៈប្រធានរដ្ឋសភា»។

ប្រសិនបើមើលក្នុងប្រកា៣២ បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាបានចែងថា «ចម្លើយរបស់រដ្ឋមន្ត្រី ឬរបស់នាយករដ្ឋមន្ត្រី អាចធ្វើដោយផ្ទាល់មាត់ ឬសរសេរជាលាយលក្ខណ៍អក្សរ។» ក្នុងប្រការ៣២ បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាបានកំណត់ទៀតថា «ចម្លើយខាងលើនេះ ត្រូវធ្វើឡើងក្នុងរយៈពេលប្រាំពីរថ្ងៃ បន្ទាប់ពីបានទទួលសំណួរ»។

ជាមួយគ្នានេះដែរ អ្នកតំណាងរាស្ត្រ សុន ឆ័យ មណ្ឌលភ្នំពេញបានបន្តទៀតថា លោកនឹងចាត់វិធានការប្ដឹងទៅក្រុមប្រឹក្សារដ្ឋធម្មនុញ្ញ ដែលជានីតិវិធីសភា និងទៅព្រះមហាក្សត្រ ព្រោះជាគោលការណ៍រាជរដ្ឋាភិបាលក៏ត្រូវជួបព្រះមហាក្សត្រពីរអាទិត្យម្ដង ដើម្បីរាយការណ៍ស្នើឲ្យព្រះមហាក្សត្ររំលឹករដ្ឋាភិបាល ត្រូវតែគោរពរដ្ឋធម្មនុញ្ញ ត្រូវឆ្លើយរាល់សំណួរអ្នកតំណាងរាស្ត្រ ហើយនឹងចូលឆ្លើយផ្ទាល់មាត់នៅក្នុងរដ្ឋសភា តាមការកំណត់តាមរដ្ឋធម្មនុញ្ញ។

តាមការសង្កេតរបស់ខុមហ្វ្រែល តាំងពីអាណត្តិរដ្ឋសភានីតិកាលទីពីរមក នាយករដ្ឋមន្ត្រីមិនបានចូលឆ្លើយផ្ទាល់មាត់នៅក្នុងរដ្ឋសភានៅឡើយ។

## សភានៅតែមិនទាន់មាននីតិវិធីច្បាស់លាស់ក្នុងការព្យួរអភ័យឯកសិទ្ធិអ្នកតំណាងរាស្ត្រ

រដ្ឋសភាដែលតែងតែសំរួលដល់ការស្នើសុំរបស់ក្រសួងយុត្តិធម៌ ក្នុងការស្នើសុំព្យួរអភ័យឯកសិទ្ធិរបស់អ្នកតំណាងរាស្ត្រ ដើម្បីអាចឲ្យតុលាការកោះហៅតំណាងរាស្ត្រទៅសាកសួរទាក់ទងនឹងបណ្ដឹងបាននោះ នៅតែមិនទាន់មាននីតីវិធីណាមួយច្បាស់លាស់ ក្នុងការព្យួរអភ័យឯកសិទ្ធិសមាជិកសភារបស់ខ្លួន ចែងឲ្យច្បាស់ពីការព្យួរ និងការប្រគល់អភ័យឯកសិទ្ធិមកវិញ។ ការព្យួរអភ័យឯកសិទ្ធិនេះ តែងតែធ្វើឡើងដោយមិនមានការពិភាក្សា សាកសួរ ផ្ដល់ឱកាសដល់តំណាងរាស្ត្រដែលនឹងត្រូវដកអភ័យឯកសិទ្ធិ បានបកស្រាយពាក់ព័ន្ធនឹងបណ្ដឹង មុនឲ្យសមាជិកសភាផ្សេងៗទៀតបានយល់ មុននឹងធ្វើការសំរេចចិត្តព្យួរអភ័យឯកសិទ្ធិ។

នៅក្នុងការច្បាប់លក្ខន្តិកៈស្ដីពីតំណាងរាស្ត្របានចែងថា សេចក្ដីសុំលើកអភ័យឯកសិទ្ធិសភារបស់តំណាងរាស្ត្ររូបណាមួយ ត្រូវធ្វើឡើងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដោយមានភ្ជាប់សេចក្ដីថ្លែងហេតុមកជាមួយផង ផ្ញើជូនប្រធានរដ្ឋសភា។

ការព្យួរអភ័យឯកសិទ្ធិនេះ ទាមទារឲ្យមានសម្លេងភាគច្រើនយ៉ាងតិច២/៣នៃសមាជិករដ្ឋសភាទាំងមូល។ នេះក៏មានន័យថា សមាជិករដ្ឋសភាទាំងអស់អាចមានសិទ្ធិមិនលើកដៃ ត្រូវតែយល់ព្រមព្យួរអភ័យឯកសិទ្ធិនេះដែរ បើទោះជាមានការស្នើសុំពីក្រសួងយុត្តិធម៌ក៏ដោយ។

ទោះបីយ៉ាងណាក៏អ្នកតំណាងរាស្ត្រ **ជាម យៀប** មានប្រសាសន៍ពាក់ពន្ធនឹងនីតិវិធីនៃការដកអភ័យឯកសិទ្ធិនេះថា រដ្ឋសភាត្រូវតែព្យួរអភ័យឯកសិទ្ធិតាមការស្នើរសុំរបស់ក្រសួងយុត្តិធម៌ ដើម្បីបើកផ្លូវឲ្យតុលាការចោទសួរអ្នកតំណាងរាស្ត្របាន *«គណៈកម្មាធិការអចិន្ត្រៃយ៍ បានឯកភាពចាំបាច់ ត្រូវតែលើកអភ័យឯកសិទ្ធិសភារបស់លោក ចាន់ ចេង ដើម្បីអាចឲ្យតុលាការសាកសួរព័ត៌មាន ឬបំភ្លឺអំពីសំណួររបស់ព្រះរាជអាជ្ញា ឬរបស់ចៅក្រមស៊ើបអង្កេតទៅតាមអ្វីដែលមានចែងនៅក្នុងប្រធានបទនៃពាក្យបណ្តឹង។»*

អ្នកតំណាងរាស្ត្រ **ចាន់ ចេង** ត្រូវបានរដ្ឋសភាដកអភ័យឯកសិទ្ធិកាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១១ កន្លងទៅនេះក្រោមសម្លេង៨៨/៩៧ ដោយសាមីខ្លួនមិនបានទទួលលិខិតជាផ្លូវការណាមួយពាក់ពន្ធនឹងការព្យួរអភ័យឯកសិទ្ធិនេះ។ *«ខ្ញុំមិនបានដឹងសោះថា មានគេប្តឹងខ្ញុំហើយ ខ្ញុំក៏មិនបានទទួលឯកសារជាផ្លូវការណាមួយពីក្រសួងថា គេចោទខ្ញុំ និងលិខិតសូមព្យួរអភ័យឯកសិទ្ធិខ្ញុំទេ។»*

សរុបមកមានន័យថា មិនថាទោះជារឿងរ៉ាវកើតឡើងយ៉ាងណា យុត្តិធម៌ ឬមិនយុត្តិធម៌ សមហេតុផល ឬមិនសមហេតុផលយ៉ាងណា គឺរដ្ឋសភាត្រូវតែសម្រេចព្យួរអភ័យឯកសិទ្ធិរបស់សមាជិកខ្លួន ទៅតាមរាល់ការស្នើសុំរបស់តុលាការ ដោយរដ្ឋសភាមិនចាំបាច់ពិចារណាលើហេតុផលនៃដើមចមនៃបណ្តឹងដែរ។

តែប្រសិនបើមើលនៅក្នុងមាត្រា១៣នៃច្បាប់ ស្តីពីលក្ខន្តិកៈតំណាងរាស្ត្របានចែងផងដែរថា ការឃុំខ្លួន ឬការចោទប្រកាន់តំណាងរាស្ត្រណាត្រូវផ្អាក ប្រសិនបើរដ្ឋសភាបញ្ចេញមតិឲ្យផ្អាកតាមមតិភាគច្រើន ៣ភាគ៤នៃចំនួនសមាជិករដ្ឋសភាទាំងមូល។

រដ្ឋសភាមិនប្រាកដថា នឹងត្រូវតែព្យួរអភ័យឯកសិទ្ធិរាល់គ្រប់ការស្នើរបស់ក្រសួងយុត្តិធម៌ដែរ គឺពួកគាត់អាចមានសិទ្ធិបដិសេធ និងចាត់វិធានការឲ្យផ្អាកចំពោះការស្នើនេះ។

អ្នកតំណាងរាស្ត្រមកពីគណបក្សផ្សេងៗទៀតក៏យល់ថា ការព្យួរអភ័យឯកសិទ្ធិនេះ គឺមិនបានផ្តល់សិទ្ធិដល់សាមីខ្លួនបានបញ្ចេញមតិក្នុងការការពារខ្លួន មុននឹងសភាពេញអង្គលើកដៃដកអភ័យឯកសិទ្ធិរបស់គាត់ ពិសេសធ្វើឲ្យតំណាងរាស្ត្រផ្សេងៗបានជ្រាបជាព័ត៌មានជាក់លាក់ផង និងដើម្បីឲ្យតំណាងរាស្ត្រដែលត្រូវគេព្យួរអភ័យឯកសិទ្ធិនោះបានអស់ចិត្ត។

អ្នកតំណាងរាស្ត្រ **យ៉ែម បុញ្ញឫទ្ធិ** មកពីគណបក្សសិទ្ធិមនុស្សមណ្ឌលព្រៃវែង បានមានប្រសាសន៍ថា វាមានភាពអយុត្តិធម៌ហួសហេតុ មិនមែនការឯកភាពគ្នា *«មុននឹងសម្រេចព្យួរអភ័យឯកសិទ្ធិរបស់អ្នកតំណាងរាស្ត្រយ៉ាងហោចណាស់ ត្រូវមានការពិភាក្សាដែរចំពោះអ្នកដែលរងគ្រោះ អ្នកដែលត្រូវដកអភ័យសិទ្ធិកន្លងមក យើងសង្កេតឃើញថា មិនមានឲ្យមានការពិភាក្សា និងសួរដេញដោលនូវជុំវិញការព្យួរអភ័យឯកសិទ្ធិ។»*

អ្នកតំណាងរាស្ត្រ **គុជ ម៉ូលី** មកពីគណបក្សហ្វ៊ុនស៊ិនប៉ិចនៅមណ្ឌលកំពង់ធំ បានមានប្រសាសន៍ស្រដៀងនេះផងដែរថា *«គួរដែរ គួរតែម្ចាស់គ្នាអស់ចិត្ត មុននឹងដកអភ័យគាត់ត្រូវធ្វើយ៉ាងមេច ត្រូវបាននិយាយឲ្យគ្នាអស់ចិត្ត ដើម្បីឲ្យតំណាងរាស្ត្រ១២២បានយល់ថា គាត់ខុសអីបានតុលាការគេធ្វើពាក្យសុំចោទគាត់ទៅបំភ្លឺក្នុងតុលាការ... ម្ចាស់ខ្លួនដែលត្រូវគេដកអភ័យឯកសិទ្ធិបានបំភ្លឺនៅមុខតំណាងរាស្ត្រទាំងអស់ឲ្យគាត់ដឹង ជួនកាលតំណាងរាស្ត្រខ្លះគាត់មិនបានដឹងផង គាត់ដឹងតែគណៈអចិន្ត្រៃយ៍ប៉ុន្មានរូបក្នុងរដ្ឋសភា»*។

អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ីចំនួន៤រូប ធ្លាប់ត្រូវបានរដ្ឋសភាដកអភ័យឯកសិទ្ធិ ក្នុងអណត្តិទី៤នេះ គឺអតីតអ្នកតំណាងរាស្ត្រ សម រង្ស៊ី អ្នកតំណាងរាស្ត្រ ហូរ វ៉ាន់ អ្នកតំណាងរាស្ត្រ មូរ សុខហួរ និងចុងក្រោយនេះ គឺអ្នកតំណាងរាស្ត្រ ចាន់ ចេង។ រាល់ករណីព្យួរអភ័យឯកសិទ្ធិកន្លងមក ម្ចាស់សាមីខ្លួនមិនដែលបានឡើងបំភ្លឺនៅមុខ

សមាជិករដ្ឋសភាទេ ហើយក៏មិនធ្លាប់មានការជជែក ពិភាក្សា ដេញដោលក្នុងកិច្ចប្រជុំពេញអង្គទេ។

## តើអ្វីជាតំលៃរបស់រដ្ឋសភា ប្រសិនបើគណបក្សសម រង្ស៊ី និងគណបក្សសិទ្ធិមនុស្សធ្វើពហិការមិនចូលប្រជុំសភា

រដ្ឋសភាអាចប្រឈមនឹងការគំរាមពីខាងគណបក្សប្រឆាំងទាំងពីរ ប្រសិនបើក្នុងករណីគណបក្សទាំងពីរនេះ មិនចូលរួមប្រជុំពេញអង្គរដ្ឋសភា នោះចំនួនសមាជិករដ្ឋសភាសរុបមានចំនួនតែ៩៤ប៉ុណ្ណោះ ហើយប្រសិនបើ មិនរាប់បញ្ចូលអ្នកតំណាងរាស្ត្រទាំង១១រូប ដែលមានឋានៈជានាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីផងដែរនោះ ចំនួនសភា សមាជិកសភាសរុបមានតែ៨៣នោះ សម្លេងនេះវាប្រថុតប្រថោយនឹងការអនុម័តណាដែលគេយកសម្លេងអនុម័ត ២ភាគ៣ (ត្រូវការកូរ៉ុំ ៨២សម្លេងយ៉ាងតិច)។ នេះមិនរាប់បញ្ចូលអវត្តមានរបស់តំណាងរាស្ត្រ ដែលគាត់មានធុរៈ និងជំងឺ។ មុខមាត់របស់រដ្ឋសភា នឹងអាចប្រឈមនឹងភាពអាប់ឱនឆាកអន្តរជាតិ នៅខណៈដែលរដ្ឋសភាមានតែសម្លេងរបស់គណបក្សកាន់អំណាច និងគណបក្សមានសម្លេងតិចប្រហែល៣% ដោយបាត់អស់សម្លេងប្រមាណ២៤%នៃចំនួនអាសនៈសរុប (តំណាងរាស្ត្រគណបក្សសម រង្ស៊ី២៦រូប និង៣រូប មកពីគណបក្សសិទ្ធិមនុស្ស)។

ជារឿយៗ គណបក្សប្រឆាំងទាំងពីរនេះ តែងតែធ្វើពហិការមិនចូលរួមកិច្ចប្រជុំពេញអង្គរដ្ឋសភា ដើម្បីពិភាក្សា និងអនុម័តលើសេចក្តីព្រាងច្បាប់មួយចំនួន គឺក្នុងគោលបំណងបញ្ជាក់ប្រាប់ប្រជាពលរដ្ឋ និងសាធារណជនជាតិ និងអន្តរជាតិថា ខ្លួនមិនគាំទ្រសេចក្តីព្រាងច្បាប់ទាំងនោះទេ។ តែទោះបីជាយ៉ាងណា ក៏អវត្តមានរបស់អ្នកតំណាងរាស្ត្រគណបក្សប្រឆាំងពីរកន្លងមក នៅមិនទាន់បង្កជាបញ្ហារាំងស្ទះដល់ការប្រជុំពេញអង្គរដ្ឋសភានៅឡើយទេ ព្រោះរាល់ពេលធ្វើពហិការ តែងតែប្រកាសជាសាធារណៈដែលជាការប្រាប់ឲ្យមានការត្រៀមលក្ខណៈជាមុនសំរាប់គណបក្សកាន់អំណាចដែលមានសម្លេងលើសលុបដល់ទៅ៩០កៅអី អាចអនុម័ត និងសំរេចលើការអនុម័តដោយយកសម្លេង៥០%+១ ឬ២/៣ ក៏បាន នេះមិនទាន់រាប់បញ្ចូលពីសម្លេងមកពីគណបក្សហ៊្វុនស៊ិនប៉ិច (២រូប) និងគណបក្សនរោត្តម រណឫទ្ធិ (២រូប)ផង។

ក៏ប៉ុន្តែសំណួរសួរថា តើអ្វីអាចបង្កឲ្យរដ្ឋសភាជួបបញ្ហារាំងស្ទះ ចំពោះកង្វះកូរ៉ុមនៃការអនុម័តនោះ (រាល់ការអនុម័តណា ត្រូវការសម្លេង២/៣យ៉ាងតិច)? គឺអាចក្នុងករណីដែលការធ្វើពហិការរបស់គណបក្សប្រឆាំងទាំង២នោះ មិនត្រូវប្រកាសជាសាធារណៈ ដើម្បីកុំមានការត្រៀមទុកប្រយ័ត្នប្រយែងពីសំណាក់គណបក្សដែលមានសម្លេងច្រើន ក៏ព្រោះតែដោយសាររាល់ការប្រជុំពេញអង្គសភាម្តងៗ អ្នកតំណាងរាស្ត្រមកពីគណបក្សកាន់អំណាច មានវត្តមានក្នុងប្រជុំជាមធ្យមចំនួន៧០រូប។ ប្រសិនបើមានហេតុការណ៍នោះកើតឡើងមែន នោះការអនុម័តណាដែលត្រូវការសម្លេង២/៣នោះ មិនអាចប្រព្រឹត្តទៅបានទេ។ ហើយម្យ៉ាងទៀត តើតំលៃរដ្ឋសភានៅត្រង់ណា ប្រសិនបើរដ្ឋសភាអនុម័តរាល់សេចក្តីព្រាងច្បាប់ មិនមានការចូលរួមពីគណបក្សប្រឆាំងទាំងពីរនេះ។

អ្នកតំណាងរាស្ត្រ **មូរ សុខហួរ** មកពីកំពតរបស់គណបក្សសម រង្ស៊ី បានមានប្រសាសន៍ថា រដ្ឋសភាមិនមានលក្ខណៈប្រជាធិបតេយ្យទេ រដ្ឋសភាអព្យាក្រឹត្យ និងមិនមានមុខមាត់ពេញលេញទេ នៅពេលដែលរដ្ឋសភាគ្មានសម្លេងពីគណបក្សប្រឆាំង ឬការជជែក បញ្ចេញយោបល់ពីគណបក្សប្រឆាំង «*នៅពេលណាគ្មានតំណាងរាស្ត្រមកពីគណបក្សប្រឆាំងហ្នឹង គឺអនុម័តដោយគ្មានការជជែកមួយមាត់សោះ មិនដែលមានសភាប្រជាធិបតេយ្យណា ដាក់ច្បាប់ឲ្យអនុម័ត ដោយគ្មានការជជែកគ្នា គឺគិតពីលើកដៃយកៗ បង្ហាញឱ្យឃើញថា សភាកម្ពុជាមិនមែនជាសភាប្រជាធិបតេយ្យទេ។*»

ស្របគ្នានេះដែរ អ្នកតំណាងរាស្ត្រ **យ៉ែម បុញ្ញឫទ្ធិ** មណ្ឌលព្រៃវែងមកពីគណបក្សសិទ្ធិមនុស្ស ក៏មានគំនិតយល់ស្របនឹងទៅនឹងអ្នកតំណាងរាស្ត្រ មូរ សុខហួរ ដែរថា វាជាការប៉ះពាល់ធ្ងន់ធ្ងរសំរាប់រដ្ឋសភា ប្រសិនបើមិនមានសម្លេងភាគតិចចូលរួមអនុម័តច្បាប់នានា *«យើងយល់ឃើញថា មានការប៉ះពាល់ធ្ងន់ណាស់ ព្រោះរដ្ឋសភាជាស្ថាប័ននីតិបញ្ញត្តិ ជាស្ថាប័នកំពូលរបស់ជាតិ ហើយនៅពេលប្រជុំពេញអង្គរបស់រដ្ឋសភា គួរណាស់តែមានសម្លេងភាគតិចចូលរួម ជាពិសេសសម្លេងគណបក្សប្រឆាំង នៅពេលដែលគណបក្សសម្លេងភាគតិចក្រៅរដ្ឋាភិបាលទាំង២គណបក្សមិនចូលរួម គឺជាការប៉ះពាល់មួយ គួរតែស្ថាប័ននីតិបញ្ញត្តិគិតគូរឡើងវិញ មុននឹងសម្រេចកិច្ចការអ្វីមួយ»*។

ចំណែកអ្នកតំណាងរាស្ត្រ **គុជ ម៉ូលី** មកពីគណបក្សហ៊្វុនស៊ិនប៊ិចមណ្ឌលកំពង់ធំ មានប្រសាសន៍ប្រហាក់ប្រហែលនឹងតំណាងរាស្ត្រខាងលើដែរ គឺមិនមានអ្វីគួរឲ្យបារម្ភ និងមិនមានអ្វីប៉ះពាល់ចំពោះមុខមាត់របស់រដ្ឋសភាក្នុងការធ្វើពហិការរបស់គណបក្សប្រឆាំង ដែលធ្វើឲ្យការប្រជុំរបស់រដ្ឋសភាគ្មានវត្តមានរបស់តំណាងរាស្ត្រគណបក្សប្រឆាំង *«គេមិនមានបញ្ហាអី មុខមាត់សភាទេ នេះជារឿងសិទ្ធិរបស់គេ ការអនុម័តអីក៏មិនបញ្ហាទេ ព្រោះគេគ្រប់កូរ៉ុមរបស់គេហើយ គ្មានបញ្ហាទេ ក្នុងនាមបក្សប្រឆាំងមិនពេញចិត្តអី គេអាចពហិកាហើយ។»*

ខាងខុមហ្វ្រែលក៏យល់ឃើញដែរថា រដ្ឋសភាគួរតែទទួលស្គាល់នូវរាល់ការកែប្រែចំណុចផ្សេងៗ ដែលជាកខ្វះខាតក្នុងសេចក្តីព្រាងច្បាប់មួយចំនួន ហើយក៏ជាសេចក្តីស្នើសុំកែតំរូវពីសំណាក់តំណាងរាស្ត្រមកពីគណបក្សប្រឆាំងផង ដើម្បីសម្លេងគណបក្សប្រឆាំងបានចូលរួម ដោយចាំបាច់ពហិការ បង្កឲ្យរដ្ឋសភាមិនមានការចូលរួមជាពហុបក្ស និងមានពេលវេលា ផ្តោតការចាប់អារម្មណ៍លើការគិតគូរពិនិត្យពិច័យបានច្រើន ក្នុងការជជែកដេញដោលលើសេចក្តីព្រាងច្បាប់។

កន្លងមកថ្មីៗនេះ ប្រធានរដ្ឋសភាបានកោះហៅសមាជិករបស់ខ្លួន ដើម្បីចូលសាលប្រជុំវិញ ដើម្បីអនុម័តរបៀបវារៈរបស់សម័យប្រជុំពេញអង្គ ខណៈដែលកូរ៉ុមរបស់រដ្ឋសភានៅសល់តែ៦៥រូប (រាប់បញ្ចូលទាំងអ្នកតំណាងរាស្ត្រមកពីគណបក្សសិទ្ធិមនុស្ស៣ផង) ព្រោះសមាជិកខ្លះរបស់គណបក្សប្រជាជនកម្ពុជាមួយចំនួន បានចេញក្រៅអង្គប្រជុំ។ នៅវេលាម៉ោង៨ ព្រឹកថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ រដ្ឋសភាបានបន្តការប្រជុំលើករបៀបវារៈទី១២ និង១៣យកមកពិភាក្សា ក្នុងការពិភាក្សាលើរបៀបវារៈទី១២ ត្រូវបានពិភាក្សា និងអនុម័តលើច្បាប់នេះចប់រួច ឯកឧត្តម ងួន ញ៉ិល អនុប្រធានទី១នៃរដ្ឋសភា ដែលទទួលភារកិច្ចជាប្រធានស្តីទី បានប្រកាសឱ្យលេខារដ្ឋសភាចេញទៅអញ្ជើញឯកឧត្តម លោកជំទាវដែលជាសមាជិក សមាជិការដ្ឋសភាមកចូលរួមក្នុងអង្គប្រជុំវិញ ដើម្បីពិនិត្យកូរ៉ុមឡើងវិញ ដើម្បីបន្តការពិភាក្សា និងអនុម័តលើរបៀបវារៈទី១៣ ស្តីពីការកំណត់ចំនួនអាសនៈរបស់រដ្ឋសភានៅនីតិកាលទី៥ ក្រោមសម្លេងអនុម័ត៧៦/៧៩។ នេះជាសកម្មភាពដ៏កំរមួយ ដែលប្រធានអង្គប្រជុំបានកោះហៅសមាជិកខ្លួន ដើម្បីចូលរួមមកសាលប្រជុំវិញ ដើម្បីឲ្យគ្រប់ចំនួនកូរ៉ុមអនុម័តសេចក្តីព្រាងច្បាប់។